ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# អក្ខរកម្មហិរញ្ញវត្ថុ



## បឋមសិក្សា

សម្រាប់គ្រូបង្រៀន

WOORI BANK
ChildFund Korea
ChildFund Cambodia
Teach For Cambodia

# អក្ខរកម្មហិរញ្ញវត្ថុ

## បឋមសិក្សា

សម្រាប់គ្រូបង្រៀន

ឆ្នាំ២០២៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ១៥៤០ អយក.ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅអក្ខរកម្មហិរញ្ញវត្ថុ បឋមសិក្សា សម្រាប់គ្រូបង្រៀន

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការអប់រំ
- បានឃើញ អនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យ លេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងលិខិតលេខ ១១៨៩-២៤ ចុះថ្ងៃព្រហស្បតិ៍ ៧កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៤ របស់អង្គការឆោលហ្វានកម្ពុជា
- យោងលិខិតលេខ ៣៦៦ អគ.អរ ចុះថ្ងៃអង្គារ ១២កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

## **សម្រេច**

**ប្រការ១.**_ អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ **«អក្ខរកម្មហិរញ្ញវត្ថុ បឋមសិក្សា សម្រាប់គ្រូបង្រៀន»** ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា ក្រោមកិច្ចសហការពីអង្គការឆាលហ្វានកម្ពុជា អង្គការឆាលហ្វានកូរ៉េ និងអង្គការបង្រៀនដើម្បីកម្ពុជា តាមរយៈជំនួយឧបត្ថម្ភពីមូលនិធិធនាគារអ៊ូរី(ខេមបូឌា) ដើម្បីប្រើប្រាស់ជាឯកសារជំនួយការបង្រៀននិងរៀន កម្រិតបឋមសិក្សា នៅតាមសាលារៀនបឋមសិក្សាទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.**_ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នាយកដ្ឋានអប់រំក្រៅប្រព័ន្ធនិងបរិយាបន្ន នាយកដ្ឋានបរិវត្តកម្មឌីជីថល នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សាលារៀនបឋមសិក្សា និងអង្គការឆាលហ្វានកម្ពុជា មានភារកិច្ចអនុវត្តប្រកាសនេះ។ ទ.ន

ថ្ងៃ ចន្ទ ៧រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៤

**កន្លែងទទួល៖**
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- អគ្គលេខាធិការដ្ឋាន
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី «ដើម្បីជ្រាបជាព័ត៌មាន»
- ដូចប្រការ២ «ដើម្បីអនុវត្ត»
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

ក្រសួងអប់រំ យុវជន និងកីឡា

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# អារម្ភកថា

ការសិក្សាស្រាវជ្រាវស្ដីពីអក្ខរកម្មហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាបានបង្ហាញថា មនុស្សភាគច្រើនមិនទាន់មានចំណេះដឹងផ្នែកហិរញ្ញវត្ថុទូលំទូលាយនៅឡើយ ដោយសារអក្ខរកម្មហិរញ្ញវត្ថុមាននិយមន័យផ្សេងៗគ្នាច្រើន ប៉ុន្តែគោលគំនិតរួមគឺមានលក្ខណៈចម្រុះ ដែលឆ្លុះបញ្ចាំងមិនត្រឹមតែចំណេះដឹងប៉ុណ្ណោះទេ ថែមទាំងឆ្លុះបញ្ចាំងនូវជំនាញ អាកប្បកិរិយា និងឥរិយាបថជាក់ស្ដែងផងដែរ។ ដូច្នេះអក្ខរកម្មហិរញ្ញវត្ថុមានគោលបំណងអភិវឌ្ឍចំណេះដឹង និងជំនាញហិរញ្ញវត្ថុ ដែលអាចឱ្យសិស្សប្រើប្រាស់ធនធានបានឱ្យល្អប្រសើរបំផុត។

ឯកសារណែនាំនេះ អភិវឌ្ឍឡើងដើម្បីណែនាំសិស្សានុសិស្សបានត្រៀមខ្លួនរួចជាស្រេចក្នុងការប្រឈមមុខនឹងបញ្ហាហិរញ្ញវត្ថុនាពេលអនាគតដែលពួកគេអាចនឹងជួបប្រទះ ព្រមទាំងទទួលបានជំនាញក្នុងការគ្រប់គ្រងប្រាក់ ការសម្រេចចិត្ត ការគ្រប់គ្រងខ្លួនឯង និងទំនួលខុសត្រូវសង្គម រួមទាំងរៀនពីរបៀបរៀបចំថវិកា សន្សំ ចំណាយ និងបរិច្ចាគ ដែលអាចឱ្យសិស្សមានភាពវិជ្ជមានលើទម្លាប់ហិរញ្ញវត្ថុ និងបង្កើនសុខុមាលភាព។ ឯកសារនេះរួមមានសម្ភារៈសម្រាប់សិស្សដូចជាសន្លឹកកិច្ចការ ផ្ទាំងរូបភាព ព្រមទាំងគន្លឹះសំខាន់ៗនិងចំណេះដឹងផ្សេងៗសម្រាប់គ្រូ ដែលជាជំនួយក្នុងការបង្រៀនដោយប្រើវិធីសាស្ត្របង្រៀនដ៏មានប្រសិទ្ធភាពក្នុងពេលបង្រៀនក្នុងថ្នាក់។

ឯកសារណែនាំនេះបានរៀបចំឡើងជា១០មេរៀន ដែលមេរៀននីមួយៗតម្រូវឱ្យសិស្សអនុវត្តសកម្មភាពសំខាន់ដោយផ្អែកលើវិធីសាស្ត្របង្រៀនបែបគម្រោង និងយុទ្ធសាស្ត្របង្រៀនផ្សេងៗ ដើម្បីឱ្យសិស្សគ្រប់ៗគ្នាមានឱកាសចូលរួមសិក្សាឈ្វេងយល់ ចែករំលែកចំណេះដឹង និងទទួលបានលទ្ធផលត្រឹមត្រូវក្នុងការសិក្សា ហើយអាចជាបទពិសោធល្អក្នុងការយកទៅអនុវត្តជាក់ស្ដែងនៅក្នុងគ្រួសារ សហគមន៍ និងសង្គម។

យើងខ្ញុំសង្ឃឹមថា ឯកសារនេះ នឹងចូលរួមចំណែកអភិវឌ្ឍចំណេះដឹងអំពីអក្ខរកម្មហិរញ្ញវត្ថុដល់សិស្សានុសិស្សឱ្យមានបំណិនច្បាស់លាស់ក្នុងការគ្រប់គ្រងប្រាក់កាន់តែប្រសើរ។ ទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំនៅតែរង់ចាំទទួលនូវទទួលនូវមតិកែលម្អនិងស្ថាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ អ្នកសិក្សា អ្នកអាន និងអ្នកចាប់អារម្មណ៍នានា ដើម្បីធ្វើឱ្យឯកសារនេះកាន់តែសុក្រឹត៕

**គណៈកម្មការនិពន្ធ**

## គណៈកម្មការគ្រប់គ្រង

ឯកឧត្តម បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
ឯកឧត្តម **អ៊ុំ ឌិនណា** អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ
លោក **សុខ ថា** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
លោក **ស៊ុន ប៊ុណ្ណា** ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
លោក **លឹម ខណ្ឌា** ប្រធាននាយកដ្ឋានសំណង់
លោក **អ៊ិត ជេដ្ឋា** អនុប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ
លោកស្រី **អ៊ុក ណារិន** មន្ត្រីគ្រប់គ្រងកម្មវិធីនៃអង្គការឆាលហ្វានកម្ពុជា
លោក **ស៊ីម មុនីរ័ត្ន** នាយកប្រតិបត្តិនិងជាតំណាងដៃគូអភិវឌ្ឍន៍

## គណៈកម្មការនិពន្ធ

កញ្ញា **សេង ស៊ីណែត**
លោកស្រី **អឿន ចំរុង**
លោក **អ៊ិន ដាវី**
លោក **ស៊ីន ដារ៉ា**
លោក **លឹម សុត្ថារិទ្ធ**
លោកស្រី **អ៊ិត ចណ្ណា**
កញ្ញា **ឈឿង ថាលីណា**

## ជំនួយការបច្ចេកទេស

Ms. Namhee Yoon, ChildFund Korea
Ms. HEM Mary, External Consultant
Ms. Pauline, External Consultant
លោក **នៅ សំណាង** អង្គការឆាលហ្វាន កម្ពុជា

# មាតិកា


**១- សេចក្ដីផ្ដើម** ........ 1

**២- គោលបំណងនៃឯកសារណែនាំ** ........ 2

**៣- ការពន្យល់អំពីរបៀបប្រើប្រាស់ឯកសារណែនាំ** ........ 2

**៤- ទិដ្ឋភាពទូទៅនៃមេរៀន** ........ 3

**៥- ការវាយតម្លៃ** ........ 4

មេរៀនទី១ ៖ ការគោរពគ្នាទៅវិញទៅមក ........ 5

មេរៀនទី២ ៖ អក្ខរកម្មហិរញ្ញវត្ថុ ........ 10

មេរៀនទី៣ ៖ ប្រវត្តិប្រាក់រៀល ........ 17

មេរៀនទី៤ ៖ ការប៉ាន់ស្មានតម្លៃទំនិញ ........ 23

មេរៀនទី៥ ៖ ការកំណត់គោលដៅហិរញ្ញវត្ថុ ........ 28

មេរៀនទី៦ ៖ ការត្រៀមខ្លួនសន្សំ ........ 39

មេរៀនទី៧ ៖ ការរកប្រាក់ ........ 44

មេរៀនទី៨ ៖ ជម្រើសរបស់ខ្ញុំក្នុងការចំណាយ ........ 50

មេរៀនទី៩ ៖ អក្ខរកម្មហិរញ្ញវត្ថុសម្រាប់ធ្វើកិច្ចការល្អៗ ........ 58

មេរៀនទី១០៖ បញ្ចប់មេរៀនអក្ខរកម្មហិរញ្ញវត្ថុ ........ 69

**ទម្រង់វាយតម្លៃឥរិយាបថសិស្ស** ........ 72

**តារាងពិន្ទុវាយតម្លៃឥរិយាបថសិស្ស** ........ 73

**ការសង្កេតថ្នាក់រៀន - ស្វ័យវាយតម្លៃគ្រូបង្រៀន** ........ 74

# ១- សេចក្តីផ្តើម

ចំណេះដឹងផ្នែកហិរញ្ញវត្ថុ គឺជាជំនាញមួយដ៏សំខាន់សម្រាប់មនុស្សគ្រប់រូបដែលត្រូវទទួលបាន។ ការពិតវាផ្តល់ចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់មនុស្ស ដើម្បីធ្វើការសម្រេចចិត្តបានត្រឹមត្រូវ និងជៀសវាងកំហុសឆ្គងផ្នែកហិរញ្ញវត្ថុ។ វាជួយឱ្យយើងចេះរៀបចំថវិកាសម្រាប់គ្រាមានអាសន្ន សម្រេចបានស្ថិរភាពថវិកា ធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិត សម្រេចបានគោលដៅ និងបង្កើនទំនុកចិត្ត។

Standard & Poor's Ratings Services បានសិក្សាស្រាវជ្រាវជាសកលក្នុងឆ្នាំ២០១៥ ដើម្បីស្ទង់ចំណេះដឹងអំពីមូលដ្ឋានចំនួនបួននៃទស្សនៈហិរញ្ញវត្ថុ៖ ហានិភ័យផ្សេងៗ អតិផរណា អក្ខរកម្មលេខ និងការប្រាក់ បានបង្ហាញថា មនុស្សពេញវ័យមួយភាគបីនៅលើពិភពលោកមានចំណេះដឹងផ្នែកហិរញ្ញវត្ថុ។ លើសពីនេះ វាបានបង្ហាញពីការប្រែប្រួលសំខាន់ៗរវាងប្រទេស និងក្រុមមនុស្សផ្សេងគ្នា។ ស្ត្រីដែលមានជីវភាពក្រីក្រនិងការអប់រំទាបទំនងជាទទួលរងពីគម្លាតនៃចំណេះដឹងផ្នែកហិរញ្ញវត្ថុ មិនថានៅក្នុងប្រទេសដែលបានអភិវឌ្ឍ ឬកំពុងអភិវឌ្ឍ។ ទន្ទឹមនឹងនេះ ការសិក្សាបានគូសបញ្ជាក់ពីភាពស្រដៀងគ្នារវាងមនុស្សដែលមានចំណេះដឹងខ្ពស់ផ្នែកហិរញ្ញវត្ថុ។ អ្នកដែលប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុដូចជា គណនីធនាគារឬបណ្ណឥណទាន ទំនងជាមានចំណេះដឹងផ្នែកហិរញ្ញវត្ថុខ្ពស់ដោយមិនគិតពីប្រាក់ចំណូលរបស់ពួកគេ។

ការសិក្សានេះបានបង្ហាញថា "ទំនាក់ទំនងរវាងចំណេះដឹងហិរញ្ញវត្ថុនិងសេវាកម្មហិរញ្ញវត្ថុ អាចដំណើរការក្នុងទិសដៅពីរ គឺនៅពេលមានចំណេះដឹងផ្នែកហិរញ្ញវត្ថុខ្ពស់អាចនាំឱ្យមានបរិយាបន្នហិរញ្ញវត្ថុនិងមានប្រតិបត្តិការគណនីឬការប្រើប្រាស់ឥណទាន ដែលអាចឱ្យអ្នកប្រើប្រាស់មានជំនាញហិរញ្ញវត្ថុកាន់តែស៊ីជម្រៅ។[1] ការវិភាគស្ថានភាពចំណេះដឹងហិរញ្ញវត្ថុបានគូសបញ្ជាក់ថា ១៨%នៃមនុស្សពេញវ័យនៅកម្ពុជាមានចំណេះដឹងផ្នែកហិរញ្ញវត្ថុ។

បន្ថែមលើការវិភាគនេះ ការសិក្សាអំពីចំណេះដឹងផ្នែកហិរញ្ញវត្ថុដែលធ្វើឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី បានបង្ហាញថា ប្រជាជនកម្ពុជាភាគច្រើនមានអត្រាទាបនៃចំណេះដឹងផ្នែកហិរញ្ញវត្ថុ[2] បើទោះជាវាត្រូវបានទទួលស្គាល់ថាមានសារៈសំខាន់ក៏ដោយ។ ការសិក្សាមួយផ្សេងទៀតដែលធ្វើឡើងដោយក្រុមហ៊ុនព្រូដិនសលនៅទូទាំងអាស៊ីបានបង្ហាញថា ទោះបីជាឪពុកម្តាយ៩៦%ទទួលស្គាល់ពីសារៈសំខាន់នៃការរៀនជំនាញជំនាញគ្រប់គ្រងប្រាក់ក៏ដោយ ប៉ុន្តែមានឪពុកម្តាយតែ១៣%ប៉ុណ្ណោះដែលជឿថា កូនរបស់ពួកគេមានជំនាញគ្រប់គ្រងប្រាក់។ ការវាយតម្លៃទូទៅមួយ[3] ធ្វើឡើងដោយ KAPE ក្នុងខែធ្នូ ឆ្នាំ២០២២បានបង្ហាញថា ក្នុងចំណោមសាលាដែលបានស្ទង់មតិមួយចំនួនធំ(42%)[4] បានរាយការណ៍ពីការបង្រៀនវគ្គចំណេះដឹងផ្នែកហិរញ្ញវត្ថុដែលជាផ្នែកមួយនៃកម្មវិធីបំណិនជីវិតរបស់ពួកគេ ទោះបីជាទាន់មិនច្បាស់ថា វាស្ថិតក្នុងកម្រិតណានៃចំណេះដឹងហិរញ្ញវត្ថុក៏ដោយ។

សរុបមក ការស្ទង់មតិទាំងនេះបានបង្ហាញពីសារៈសំខាន់នៃការរៀនអំពីអក្ខរកម្មហិរញ្ញវត្ថុ រួមទាំងនៅក្នុងប្រទេសកម្ពុជាផងដែរ ដើម្បីលើកកម្ពស់ជំនាញហិរញ្ញវត្ថុសម្រាប់កុមារនិងយុវជន។ អក្ខរកម្មហិរញ្ញវត្ថុ មាននិយមន័យផ្សេងៗគ្នា ប៉ុន្តែបញ្ញត្តិរួមគឺមានលក្ខណៈចម្រុះដែលមិនត្រឹមតែឆ្លុះបញ្ចាំងពីចំណេះដឹងប៉ុណ្ណោះទេ ថែមទាំងជំនាញឥរិយាបថ និងអាកប្បកិរិយាជាក់ស្តែងផងដែរ។ ដូច្នេះអក្ខរកម្មហិរញ្ញវត្ថុមានគោលបំណងអភិវឌ្ឍចំណេះដឹង និងជំនាញហិរញ្ញវត្ថុដែលជួយឱ្យសិស្សអាចប្រើប្រាស់ធនធានឱ្យបានល្អបំផុត ។

[1] ចំណេះដឹងផ្នែកហិរញ្ញវត្ថុជុំវិញពិភពលោក៖ ការយល់ដឹងពីការស្ទង់មតិ S&P Global Finlit ឆ្នាំ២០១៥

[2] ការសិក្សារបស់វិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារជាតិនៃកម្ពុជា បានរកឃើញក្នុងឆ្នាំ២០១៧ថា ពិន្ទុសរុបនៃចំណេះដឹងផ្នែកហិរញ្ញវត្ថុនៅកម្ពុជា (11.5 ពិន្ទុក្នុងចំណោម 21) គឺនៅកម្រិតទាបនៃជួរដែលឃើញនៅក្នុងគំរូនៃប្រទេសចំនួន៣០ ដែលបានអនុវត្តទម្រង់ស្ទង់មតិស្តង់ដារដែលត្រូវបានបង្កើត ឡើងដោយ OECD/INFE ។

[3] អក្ខរកម្មហិរញ្ញវត្ថុចំពោះកុមារ ព្រូដិនសល ឆ្នាំ២០១១

[4] ការវាយតម្លៃទូទៅនៃចំណេះដឹងផ្នែកឌីជីថល និងហិរញ្ញវត្ថុ ដែលបង្កើតឡើងដោយ KAPE សម្រាប់មូលនិធិកុមារកម្ពុជាក្នុងខែធ្នូ ឆ្នាំ២០២២។

## ២- គោលបំណងនៃឯកសារណែនាំ

ឯកសារណែនាំនេះមានគោលបំណងបង្រៀនសិស្សអំពីសារៈសំខាន់នៃការយល់ដឹងអំពីហិរញ្ញវត្ថុ ដើម្បីត្រៀមខ្លួនជាស្រេចក្នុងការប្រឈមមុខនឹងបញ្ហាហិរញ្ញវត្ថុនាពេលអនាគតដែលពួកគេអាចជួបប្រទះ។ តាមរយៈឯកសារនេះ សិស្សនឹងទទួលបានជំនាញក្នុងការគ្រប់គ្រងប្រាក់ ការសម្រេចចិត្ត ការគ្រប់គ្រងខ្លួនឯង និងទំនួលខុសត្រូវសង្គម ព្រមទាំងរៀនពីរបៀបរៀបចំថវិកា សន្សំ ចំណាយ និងបរិច្ចាគ ដែលអាចឱ្យសិស្សមានភាពវិជ្ជមានលើទម្លាប់ហិរញ្ញវត្ថុ និងបង្កើនសុខុមាលភាព។ ឯកសារនេះ ត្រូវបានរៀបចំឡើងសម្រាប់គ្រូបង្រៀនប្រើប្រាស់ទៅតាមការពន្យល់ខាងក្រោម។ ឯកសារនេះរួមមាន សម្ភារៈសម្រាប់សិស្សដូចជា សន្លឹកកិច្ចការ និងផ្ទាំងរូបភាព។ បន្ថែមពីលើនេះ វាផ្តល់ឱ្យគ្រូនូវគន្លឹះនិងចំណេះដឹងសំខាន់ៗដើម្បីជួយក្នុងការជ្រើសរើសវិធីសាស្ត្របង្រៀនដ៏ល្អបំផុតសម្រាប់ថ្នាក់រៀន។

## ៣- ការពន្យល់អំពីរបៀបប្រើប្រាស់ឯកសារណែនាំ

នៅក្នុងឯកសារណែនាំនេះ មេរៀននីមួយៗត្រូវបានបែងចែកជាផ្នែកផ្សេងៗគ្នា។ ផ្នែកនីមួយៗមានគោលបំណងរៀងៗខ្លួន។

| | |
|---|---|
|  | **រយៈពេល៖** និមិត្តសញ្ញានេះបង្ហាញពីពេលវេលាសម្រាប់បង្រៀនមេរៀនទាំងមូល។ |
|  | **ការត្រៀមមុនបង្រៀន៖** ផ្នែកនេះប្រាប់ព័ត៌មានអំពីរបៀបរៀបចំថ្នាក់ ឬទីតាំងផ្សេងទៀតដែលត្រូវប្រើសម្រាប់សកម្មភាពសិក្សា។ វាក៏ផ្តល់ការណែនាំអំពីរបៀបរៀបចំសម្ភារៈចាំបាច់សម្រាប់សកម្មភាពផងដែរ។ |
|  | **សម្ភារៈដែលចាំបាច់៖** ផ្នែកនេះបង្ហាញទិដ្ឋភាពទូទៅនៃសម្ភារៈដែលចាំបាច់ដូចជា ប៊ិក ក្រដាស ឬសន្លឹកកិច្ចការថតចម្លង។ |
|  | **លទ្ធផលសិក្សា៖** បង្ហាញនូវអ្វីដែលនឹងអាចសម្រេចបាន នៅចុងបញ្ចប់នៃមេរៀន។ |

### ✦ ជំហាន និងដំណើរការ

សៀវភៅនេះជាមេរៀនជាក់ស្តែង។ នៅក្នុងផ្នែកនេះមានព័ត៌មានលម្អិតអំពីវិធីសាស្ត្របង្រៀន រួមបញ្ចូលទាំងសកម្មភាពដែលអាចធ្វើបាន សំណួរជំរុញ ឧទាហរណ៍ដើម្បីពន្យល់លំហាត់ឱ្យច្បាស់ និងកិច្ចការបន្ថែមជាជម្រើស។

មេរៀននីមួយៗត្រូវបានបែងចែកជាផ្នែកផ្សេងៗ។ ផ្នែកទីមួយ គឺជាសេចក្តីផ្តើម ដែលផ្សាភ្ជាប់ទៅនឹងចំណេះដឹងដែលមានស្រាប់ឬរំឭកមេរៀនមុន។ នៅផ្នែកទីពីរ បង្រៀនសកម្មភាពសំខាន់ដោយផ្អែកលើវិធីសាស្ត្របង្រៀនបែបគម្រោង និងវិធីបង្រៀនផ្សេងៗ។ សកម្មភាពសំខាន់មួយឬច្រើនគឺ អាស្រ័យលើមេរៀននីមួយៗ។ ក្នុងផ្នែកចុងក្រោយ គឺជានានូវលទ្ធផលសិក្សារបស់សិស្សតាមរយៈវិធីផ្សេងៗគ្នា។

✦ **សន្លឹកកិច្ចការ**

បន្ទាប់ពីមេរៀននីមួយៗ មានសន្លឹកកិច្ចការសម្រាប់សិស្សភាគច្រើនត្រូវថតចម្លង និងកាត់សន្លឹកកិច្ចការទាំងនោះ ហើយនៅពេលខ្លះ លោកគ្រូ អ្នកគ្រូគ្រាន់តែបង្ហាញដល់សិស្ស។ មិនមែនគ្រប់មេរៀនទាំងអស់សុទ្ធតែមានសន្លឹកកិច្ចការនោះទេ។

## ៤- ទិដ្ឋភាពទូទៅនៃមេរៀន

| ចំណងជើងមេរៀន | រយៈពេល | លទ្ធផលសិក្សា |
|---|---|---|
| **មេរៀនទី១៖** ការគោរពគ្នាទៅវិញទៅមក | ៤០នាទី | - ចាប់ផ្តើមស្គាល់គ្នាទៅវិញទៅមក<br>- បង្កើតវិន័យក្នុងថ្នាក់រៀនប្រកបដោយបរិយាបន្ន<br>- គោរពភាពចម្រុះនៃអត្តសញ្ញាណរបស់អ្នកដទៃ។ |
| **មេរៀនទី២៖** អក្ខរកម្មហិរញ្ញវត្ថុ | ៤០នាទី | - កំណត់និយមន័យនៃពាក្យទាក់ទងនឹងអក្ខរកម្មហិរញ្ញវត្ថុ<br>- ចែករំលែកគំនិតអំពីអត្ថប្រយោជន៍នៃការសិក្សាពីអក្ខរកម្មហិរញ្ញវត្ថុ<br>- កំណត់ការរំពឹងទុកក្នុងការសិក្សាពីអក្ខរកម្មហិរញ្ញវត្ថុ<br>- បង្កើតនិយមន័យនៃអក្ខរកម្មហិរញ្ញវត្ថុ។ |
| **មេរៀនទី៣៖** ប្រវត្តិរបស់លុយ | ៤០នាទី | - ពណ៌នាអំពីវិធីផ្សេងគ្នានៃការផ្លាស់ប្តូរទំនិញ កាក់ និងប្រាក់<br>- ពន្យល់ពីការវិវត្តនៃប្រាក់នៅកម្ពុជា<br>- កាន់តែស្គាល់រូបិយប័ណ្ណរបស់ខ្មែរ។ |
| **មេរៀនទី៤៖** ការប៉ាន់ស្មានតម្លៃទំនិញ | ៤០នាទី | - ប៉ាន់ប្រមាណតម្លៃនៃវត្ថុផ្សេងៗដែលពួកគេបានឃើញ<br>- កំណត់អាទិភាពជ្រើសរើសវត្ថុទាក់ទងនឹងតម្រូវការ ឬចំណង់។ |
| **មេរៀនទី៥៖** ការកំណត់គោលដៅហិរញ្ញវត្ថុ | ៨០នាទី (២ វគ្គ) | - ស្គាល់ប្រភេទផ្សេងៗក្នុងការសន្សំ<br>- បង្កើតប្រអប់សន្សំផ្ទាល់ខ្លួន<br>- បង្កើតផែនការសន្សំសម្រាប់រយៈពេលខ្លី ឬវែង។ |
| **មេរៀនទី៦៖** ត្រៀមខ្លួនសន្សំ | ៤០នាទី | - បង្កើតសៀវភៅកត់ត្រាការសន្សំប្រចាំសប្តាហ៍/ខែ<br>- សាកល្បងប្រភេទផ្សេងៗនៃការសន្សំតាមរយៈការលេងល្បែងសិក្សា។ |
| **មេរៀនទី៧៖** ការរកលុយ | ៤០នាទី | - បង្ហាញពីវិធីផ្សេងៗក្នុងការរកលុយ<br>- រាប់ឈ្មោះការងារដែលពួកគេចូលចិត្ត និងមិនចូលចិត្ត។ |
| **មេរៀនទី៨៖** ជម្រើសរបស់ខ្ញុំក្នុង | ៨០នាទី | - ពន្យល់ពីគុណសម្បត្តិ និងគុណវិបត្តិនៃការចំណាយ |

| | | |
|---|---|---|
| ការចំណាយ | (២ វគ្គ) | - ធ្វើសេចក្តីសម្រេចចិត្តលើការចំណាយឱ្យបានត្រឹមត្រូវ និងឆ្លាតវៃដោយប្រើករណីសិក្សាដែលមានបង្ហាញក្នុងថ្នាក់។ |
| **មេរៀនទី៩៖** អក្ខរកម្មហិរញ្ញវត្ថុសម្រាប់ធ្វើកិច្ចការល្អៗ | ១២០នាទី (៣ វគ្គ) | - ពន្យល់ពីសារៈសំខាន់នៃការជួយអ្នកដទៃ<br>- ផ្តល់ឧទាហរណ៍អំពីសកម្មភាពដើម្បីគាំទ្រដល់អ្នកដទៃនៅក្នុងសាលា និងសហគមន៍<br>- ពណ៌នាអំពីមនុស្សដែលប្រហែលជាត្រូវការជំនួយ។ |
| **មេរៀនទី១០៖** បញ្ចប់ដំណើរការមេរៀនអក្ខរកម្មហិរញ្ញវត្ថុ | ៤០នាទី | - បញ្ចេញគំនិត និងអារម្មណ៍ស្តីពីអក្ខរកម្មហិរញ្ញវត្ថុ ដែលមានលក្ខណៈដើម និងពិតប្រាកដ។<br>- បង្ហាញសមត្ថភាពតាមរយៈការនិយាយខ្លីៗអំពីរបៀបដែលចំណេះដឹង និងអាកប្បកិរិយារបស់ពួកគេស្តីពីអក្ខរកម្មហិរញ្ញវត្ថុមានភាពប្រសើរឡើង។ |

## ៥- ការវាយតម្លៃ

ការវាយតម្លៃសិស្សមានពីរផ្នែក។ មួយផ្នែកជាការវាយតម្លៃមុនវគ្គ ឬក្រោយវគ្គ។ ការវាយតម្លៃសិស្សមុនវគ្គធ្វើឡើងក្នុងមេរៀនទី២ និងការវាយតម្លៃសិស្សក្រោយវគ្គនឹងអនុវត្តនៅបញ្ចប់មេរៀនទី១០។ ផ្នែកមួយទៀត ជាការវាយតម្លៃឥរិយាបថសិស្ស។ គ្រូអាចបំពេញទម្រង់សង្កេតឥរិយាបថសិស្សនៅមេរៀនទី៨ ទី៩ ឬទី១០។ ការវាយតម្លៃទាំងពីរចំណុចនេះមានសារៈសំខាន់ក្នុងការវាស់ចំណេះដឹងនិងឥរិយាបថសិស្សម្នាក់ៗ។ ចំពោះការវាយតម្លៃនេះ ពិន្ទុសរុបគឺ៥០ ដោយក្នុងនោះពិន្ទុ៣៥សម្រាប់ឥរិយាបថសិស្សនិងពិន្ទុ១៥សម្រាប់ការធ្វើតេស្តក្រោយវគ្គ។

ទម្រង់សង្កេតថ្នាក់រៀន រៀបចំឡើងដើម្បីជួយគ្រូធ្វើស្វ័យវាយតម្លៃលើការបង្រៀនរបស់គាត់ក្នុងការបង្រៀនមេរៀននេះ។ គ្រូអាចអភិវឌ្ឍការបង្រៀនរបស់ខ្លួនតាមរយៈការបំពេញទម្រង់នេះ។ នាយកសាលា ការិយាល័យ និងមន្ទីរអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធ អាចប្រើប្រាស់ទម្រង់នេះ ដើម្បីសង្កេតការបង្រៀនរបស់លោកគ្រូអ្នកគ្រូនៅក្នុងថ្នាក់រៀន។

# មេរៀនទី ១ ការគោរពគ្នាទៅវិញទៅមក

| | |
|---|---|
|  | រយៈពេល៖ ៤០នាទី |
|  | **ការត្រៀមមុនបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ថតចម្លងសន្លឹកកិច្ចការ១.១ និង១.២<br>- អានសន្លឹកកិច្ចការ១.៣៖ គន្លឹះនៃច្បាប់ប្រាមដៃទាំងប្រាំ។ |
|  | **សម្ភារៈ ធនធានដែលចាំបាច់**<br>- សន្លឹកកិច្ចការ១.១៖ នេះគឺជាខ្ញុំ<br>- សន្លឹកកិច្ចការ១.២៖ ច្បាប់ប្រាមដៃទាំងប្រាំ<br>- សន្លឹកកិច្ចការ១.៣៖ ព័ត៌មានជំនួយអំពីច្បាប់ប្រាមដៃទាំងប្រាំ<br>- ស្កុត<br>- ក្រដាស A4 (ពណ៌ស និងពណ៌ផ្សេងៗ) ផ្ទាំងក្រដាសធំ<br>- ប៊ិក និងខ្មៅដៃពណ៌ កន្ត្រៃ កាវ។ |
|  | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- ចាប់ផ្ដើមស្គាល់គ្នាទៅវិញទៅមក<br>- បង្កើតវិន័យក្នុងថ្នាក់រៀនប្រកបដោយបរិយាបន្ន<br>- គោរពភាពចម្រុះនៃអត្តសញ្ញាណរបស់អ្នកដទៃ។ |

### សេចក្ដីផ្ដើម៖ ការណែនាំខ្លួន ( ១៥នាទី )

គ្រូចាប់ផ្ដើមវគ្គដោយនិយាយថា ជាដំបូង ដើម្បីចាប់ផ្ដើមដំណើរនេះ វាជារឿងគួរឱ្យចាប់អារម្មណ៍ក្នុងការស្គាល់គ្នាទៅវិញទៅមកបន្ថែម និងស្វែងរកអ្វីដែលថ្មីអំពីមិត្តរួមថ្នាក់របស់ប្អូន។ ដើម្បីធ្វើបែបនេះ ប្អូនត្រូវសរសេរអំពីខ្លួនឯង តើប្អូនជានរណា? តើប្អូនមកពីណា?។ល។ ដោយប្រើសន្លឹកកិច្ចការ១.១៖ នេះគឺជាខ្ញុំ ដែលបានចែក ជូន។ សិស្សមានពេល ៥នាទីដើម្បីសរសេរអំពីខ្លួនឯង។

សិស្សបំពេញការណែនាំខ្លួន (សន្លឹកកិច្ចការ១.១៖ នេះគឺជាខ្ញុំ)។ នៅពេលបញ្ចប់ គ្រប់គ្នាអាចបិទក្រដាសណែនាំខ្លួននៅលើក្ដារខៀន។ សិស្សគ្រប់គ្នាអាចដើរទៅអានប្រវត្តិរូបរបស់មិត្តរួមថ្នាក់ផ្សេងទៀត។

បន្ទាប់មកគ្រូសួរថា តើប្អូនបានរៀនសូត្រអ្វីខ្លះពីសកម្មភាពនេះ? តើប្អូនចង់ដឹងបន្ថែមអំពីមិត្តភក្ដិដែរឬទេ? ហេតុអ្វី?

គ្រូសរសើរសិស្សចំពោះការចូលរួម។

✦ **សកម្មភាពសំខាន់ទី១៖** ការបង្កើតបទបញ្ញត្តិសម្រាប់ថ្នាក់រៀន - ច្បាប់ម្រាមដៃទាំងប្រាំ (២៥នាទី)

គ្រូបន្តមេរៀន ហើយនិយាយថា ប្អូនៗទាំងអស់គ្នា! ក្នុងមេរៀនអក្ខរកម្មហិរញ្ញវត្ថុ (ចំណេះដឹងហិរញ្ញវត្ថុ) នេះ យើងនឹងបង្កើតបរិយាកាសសិក្សាដែលមានសុវត្ថិភាព ដើម្បីទទួលបានការសប្បាយ ការគោរព និងការចូលរួម ដោយត្រូវបង្កើតបទបញ្ញត្តិក្នុងថ្នាក់។ តាមគំនិតរបស់ប្អូន តើយើងគួរធ្វើ ឬមិនគួរធ្វើអ្វីក្នុងថ្នាក់នេះ?

សិស្សទទួលបានក្រដាសមួយសន្លឹក (កាត VIPP) = (ក្រដាស A4 កាត់ជាបួន) ដើម្បីសរសេរពាក្យមួយ ទាក់ទងនឹងអ្វីដែលពួកគេគួរធ្វើ ឬមិនគួរធ្វើ នៅក្នុងថ្នាក់អក្ខរកម្មហិរញ្ញវត្ថុ។ បន្ទាប់មក សិស្សរាល់គ្នាបិទកាត VIPP នៅលើក្តារខៀន។

គ្រូបង្ហាញសន្លឹកកិច្ចការ១.២ (រូបភាពនៃម្រាមដៃទាំងប្រាំ) ឬគូរម្រាមដៃនីមួយៗដោយខ្លួនឯង។ បន្ទាប់មកពន្យល់ពីសញ្ញាម្រាមដៃប្រាំ ដើម្បីរៀបចំបទបញ្ញត្តិក្នុងថ្នាក់រៀន។ សិស្សគ្រប់គ្នាអាចចងចាំនិងអនុវត្តគ្រប់ទីកន្លែង។ ខាងក្រោមនេះជាអត្ថន័យតំណាងឱ្យម្រាមដៃនីមួយៗ៖

១- ម្រាមដៃកូនតំណាងឱ្យ «**សុវត្ថិភាពផ្លូវកាយ និងផ្លូវអារម្មណ៍**»។ ជាទូទៅ ម្រាមដៃកូនងាយនឹងទទួលរងការឈឺចាប់បំផុត។ ឧទាហរណ៍៖ ចូរស្រឡាញ់ខ្លួនឯង និងអ្នកដទៃ។

២- ម្រាមដៃនាង៖ គូស្វាមីភរិយាជាច្រើនពាក់ចិញ្ចៀនលើម្រាមដៃនេះ។ វាតំណាងឱ្យ «**ការចូលរួម និងការប្តេជ្ញាចិត្ត**»។ ឧទាហរណ៍៖ ត្រូវចូលរួមសកម្ម។

៣- ម្រាមដៃកណ្តាលជាធម្មតាមានន័យអវិជ្ជមាននិងអាក្រក់ ប៉ុន្តែសម្រាប់ថ្នាក់របស់យើង វាតំណាងឱ្យ «**ការគោរព**»។ ឧទាហរណ៍៖ គោរពអត្តសញ្ញាណរបស់គ្នាទៅវិញទៅមក។

៤- ម្រាមដៃចង្អុលជាធម្មតាត្រូវបានប្រើដើម្បីផ្តល់ «**ទិសដៅ**» តើប្អូននឹងធ្វើអ្វីដើម្បីទៅដល់គោលដៅរបស់ប្អូន? ឧទាហរណ៍៖ ផ្តោតអារម្មណ៍លើមេរៀន។

៥- លើកមេដៃឡើង។ ឧទាហរណ៍៖ ធ្វើបានល្អ!



សម្រាប់ព័ត៌មានបន្ថែម គ្រូអាចអានសន្លឹកកិច្ចការ១.៣៖ ព័ត៌មានជំនួយអំពីច្បាប់ម្រាមដៃទាំងប្រាំ។

គ្រូជ្រើសរើសសិស្សស្ម័គ្រចិត្តប្រាំនាក់ទៅឈរជិតក្តារខៀន ដើម្បីដាក់ចម្លើយទៅតាមប្រភេទដែលត្រឹមត្រូវស្តីពីច្បាប់ម្រាមដៃទាំងប្រាំដែលសិស្សម្នាក់តំណាងឱ្យម្រាមដៃមួយ។ ប្រសិនបើសិស្សរកឃើញពាក្យដូចគ្នា ពួកគេអាចដកវាចេញបាន។ បន្ទាប់មក គ្រូសួរ៖ តើប្អូនគិតថាពាក្យទាំងនេះត្រូវនឹងច្បាប់ម្រាមដៃទាំងប្រាំដែរឬទេ? បើមិនដូច្នោះទេ ប្អូនអាចស្វែងរកពាក្យ ឬឃ្លាបន្ថែមទៀតដែលឆ្លុះបញ្ចាំងពីម្រាមដៃទាំងនោះ។

សិស្សនឹងរចនាម្រាមដៃនៅក្នុងផ្ទាំងក្រដាសធំដ៏ស្រស់ស្អាត ដើម្បីបង្ហាញនៅលើក្តារខៀន។ សិស្សត្រូវបានលើកទឹកចិត្តឱ្យបង្កើតផ្ទាំងក្រដាសធំដោយប្រើសម្ភារៈផ្សេងគ្នាដូចជា ក្រដាសពណ៌ និងខ្មៅដៃពណ៌ជាដើម។

ដើម្បីបិទបញ្ចប់សកម្មភាពនេះ គ្រូអាចសរសើរសិស្សថា ល្អណាស់! គំនិតរបស់ប្អូនពិតជាមានប្រយោជន៍ ហើយច្បាប់ម្រាមដៃទាំងប្រាំត្រូវបានបង្កើតឡើងរួចហើយ។ យើងទាំងអស់គ្នាត្រូវគោរព និងអនុវត្តច្បាប់នេះក្នុងថ្នាក់របស់យើងជាប្រចាំ។ ប្អូននឹងក្លាយជាកូនល្អ សិស្សល្អ និងជាពលរដ្ឋល្អក្នុងសង្គមយើង។

គ្រូឱ្យសិស្សឆ្លុះបញ្ចាំងពីសកម្មភាពថ្ងៃនេះ ហើយអាចសួរថា តើប្អូនបានរៀនសូត្រអ្វីខ្លះនៅថ្ងៃនេះ? តើប្អូនចូលចិត្តអ្វីខ្លះសម្រាប់មេរៀនថ្ងៃនេះ? តើប្អូនទទួលបានចំណេះដឹងអ្វីខ្លះពីមេរៀននេះ ពេលប្អូនត្រឡប់ទៅផ្ទះវិញ?

### សន្លឹកកិច្ចការ១.១៖ នេះគឺជាខ្ញុំ



# នេះគឺជាខ្ញុំ




ខ្ញុំឈ្មោះ ______________________________

ខ្ញុំមានអាយុ __________ ឆ្នាំ។ ខ្ញុំមានបងប្អូនចំនួន ____________ នាក់។

ខ្ញុំរស់នៅក្នុងស្រុក ____________ ខេត្ត __________ ប្រទេស ____________

ខ្ញុំចូលចិត្ត៖ ______________________________

ខ្ញុំមិនចូលចិត្ត៖ ______________________________

ក្ដីសុបិនរបស់ខ្ញុំចង់ក្លាយជា៖ ______________________________

## សន្លឹកកិច្ចការទី១.២៖ ច្បាប់ម្រាមដៃទាំង៥



លើកមេដៃឡើង



ទិសដៅ ម្រាមដៃចង្អុល



ការគោរព ម្រាមដៃកណ្ដាល



ការប្ដេជ្ញាចិត្ត ម្រាមដៃនាង



សុវត្ថិភាព ម្រាមដៃកូន

## សន្លឹកកិច្ចការទី១.៣៖ ព័ត៌មានជំនួយអំពីច្បាប់ម្រាមដៃទាំងប្រាំ[5]

១- **ម្រាមដៃកូន៖** តំណាងឱ្យ «**សុវត្ថិភាពផ្លូវកាយ និងផ្លូវអារម្មណ៍**»។ ជាទូទៅ ម្រាមដៃកូនជាម្រាមដៃតូចជាងគេ និងងាយទទួលរងការឈឺចាប់បំផុត។ នេះជាឧទាហរណ៍គំរូមួយចំនួន៖
- ចូរស្រឡាញ់ខ្លួនឯង និងអ្នកដទៃ
- និយាយដោយគួរសម
- ជួយថែរក្សាមិត្តភក្តិដែលខ្សោយ
- រីករាយជាមួយគ្នា។

២- **ម្រាមដៃនាង៖** គូស្វាមីភរិយាជាច្រើនពាក់ចិញ្ចៀនលើម្រាមដៃនេះ។ វាតំណាងឱ្យ «**ការចូលរួម និងការប្តេជ្ញាចិត្ត**»។ យើងនឹងប្តេជ្ញាសាកល្បងធ្វើសកម្មភាពថ្មីៗនិងសិក្សាឱ្យបានច្រើន។ នេះជាឧទាហរណ៍គំរូមួយចំនួន៖
- មានវត្តមាននៅក្នុងថ្នាក់
- ចូលរួមសកម្ម
- ចែករំលែក ឬផ្តួចផ្តើមគំនិត
- ចេះធ្វើការងារជាក្រុមបានល្អ
- ចូលរួមក្នុងសកម្មភាព។

៣- **ម្រាមដៃកណ្តាល៖** ជាធម្មតាមានន័យអវិជ្ជមាន និងអាក្រក់ ប៉ុន្តែសម្រាប់ថ្នាក់របស់យើង វាតំណាងឱ្យ «**ការគោរព**»។ នេះជាឧទាហរណ៍គំរូមួយចំនួន៖
- គោរពអត្តសញ្ញាណរបស់គ្នាទៅវិញទៅមក
- ស្តាប់មិត្តរបស់ប្អូនដោយយកចិត្តទុកដាក់
- លើកដៃរបស់ប្អូននៅពេលចង់និយាយ ហើយរង់ចាំដល់វេនរបស់ប្អូន
- រៀបចំសណ្តាប់ធ្នាប់ថ្នាក់រៀនរបស់ប្អូនឱ្យបានទៀងទាត់។

៤- **ម្រាមដៃចង្អុល៖** ជាធម្មតាត្រូវបានប្រើដើម្បីផ្តល់ «**ទិសដៅ**»។ នេះជាឧទាហរណ៍គំរូមួយចំនួន៖
- ចូរអាន និងធ្វើតាមការណែនាំដោយយកចិត្តទុកដាក់ មុនពេលចាប់ផ្តើមសកម្មភាព
- ចូរផ្តោតលើការសិក្សារបស់ប្អូន ដើម្បីសម្រេចគោលដៅបាន។

៥- **លើកមេដៃឡើង** តើវាមានន័យយ៉ាងណាចំពោះប្អូន?
- ធ្វើបានល្អ / ប្អូនធ្វើបានល្អ
- ល្អណាស់ / ល្អឥតខ្ចោះ
- អបអរសាទរ ឬអស្ចារ្យមែន។

[5] បំផុសគំនិតដោយកិច្ចសន្យាម្រាមដៃទាំងប្រាំ សៀវភៅណែនាំស្តីពីទិដ្ឋភាពទូទៅសម្រាប់អ្នកសម្របសម្រួលកម្មវិធីសិក្សា ភែស (P.A.C.E.) សម្រាប់សិស្សស្រីវ័យជំទង់

# មេរៀនទី ២ អក្ខរកម្មហិរញ្ញវត្ថុ

| | |
|---|---|
|  | រយៈពេល៖ ៤០នាទី |
|  | **ការត្រៀមមុនបង្រៀន**<br>- អានកិច្ចតែងការទាំងមូល<br>- ថតចម្លងសន្លឹកកិច្ចការ២.១។ |
|  | **សម្ភារៈ ធនធានដែលចាំបាច់**<br>- សន្លឹកកិច្ចការ២.១៖ តេស្តមុនវគ្គ<br>- ក្រដាសផ្ទាំងធំ ក្រដាស A4 ពណ៌ស និងពណ៌ផ្សេងៗ ហ្វឺត កន្ត្រៃ។ល។ |
|  | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- កំណត់និយមន័យនៃពាក្យទាក់ទងនឹងអក្ខរកម្មហិរញ្ញវត្ថុ<br>- ចែករំលែកគំនិតអំពីអត្ថប្រយោជន៍នៃការសិក្សាពីអក្ខរកម្មហិរញ្ញវត្ថុ<br>- កំណត់ការរំពឹងទុកក្នុងការសិក្សាពីអក្ខរកម្មហិរញ្ញវត្ថុ<br>- បង្កើតនិយមន័យនៃអក្ខរកម្មហិរញ្ញវត្ថុ។ |

## សេចក្តីផ្តើម៖ តេស្តមុនវគ្គ អក្ខរកម្មហិរញ្ញវត្ថុ (១៥នាទី)

គ្រូប្រាប់ឱ្យសិស្សបំពេញសន្លឹកកិច្ចការទី២.១៖ តេស្តមុនវគ្គ មុនពេលចាប់ផ្តើមមេរៀនអក្ខរកម្មហិរញ្ញវត្ថុ។ ការវាយតម្លៃនេះមានគោលបំណងឱ្យសិស្សយល់ដឹងកាន់តែប្រសើរអំពីអក្ខរកម្មហិរញ្ញវត្ថុ។ មុនពេលចាប់ផ្តើម សិស្សត្រូវយករបស់របរផ្ទាល់ខ្លួនទាំងអស់ចេញពីតុ ហើយដាក់វានៅក្រោមតុរបស់ពួកគេ ឬនៅផ្នែកខាងក្រោយនៃថ្នាក់រៀន។

នៅពេលតេស្តចាប់ផ្តើម សិស្សនឹងមិនអនុញ្ញាតឱ្យជជែកគ្នាឡើយ។ ប្រសិនបើពួកគេមានសំណួរទាក់ទងនឹងតេស្ត ពួកគេត្រូវលើកដៃសួរគ្រូ។ ពួកគេមិនអាចសួរមិត្តភក្តិបានទេ។ សិស្សមានពេល១៥នាទីដើម្បីបញ្ចប់តេស្ត។ នៅពេលសល់រយៈពេលវេលា៥នាទី គ្រូត្រូវសរសេរនៅលើក្តារខៀនជាការក្រើនរម្លឹក។ ប្រសិនបើសិស្សធ្វើចប់មុនម៉ោង ពួកគេអាចប្រគល់តេស្ត ហើយចេញទៅរង់ចាំនៅខាងក្រៅថ្នាក់។ ឥឡូវនេះ សិស្សអាចចាប់ផ្តើមធ្វើតេស្ត។

### ចម្លើយតេស្តមុន ឬក្រោយវគ្គ៖

| | | |
|---|---|---|
| ១- មិនមានចម្លើយត្រូវឬខុស | ២- ក ខ គ ឃ | ៣- ខ |
| ៤- គ | ៥- ក | ៦- សៀវភៅសរសេរ សម្លៀកបំពាក់ កង់ កុំព្យូទ័រយួរដៃ |
| ៧- ខ | ៨- ចាស/បាទ | ៩- មិនមានចម្លើយត្រូវ ឬខុស |
| ១០- ចាស/បាទ | ១១- ឃ | ១២- គ |
| ១៣- គ | ១៤- គ | ១៥- ក |
| ១៦- ឃ | ១៧- ក | ១៨- មិនមានចម្លើយត្រូវ ឬខុស |

## សកម្មភាពសំខាន់ទី១៖ អក្ខរកម្មហិរញ្ញវត្ថុ (២០នាទី)

គ្រូស្វាគមន៍សិស្សមកកាន់ដំណើរការសិក្សាអំពីអក្ខរកម្មហិរញ្ញវត្ថុ ហើយសួរថា នៅពេលប្អូនឮពាក្យថា អក្ខរកម្មហិរញ្ញវត្ថុ តើប្អូនគិតដល់អ្វីមុនគេ? (១០នាទី)




គ្រូគូរផែនទីគំនិត (mind map) ដែលទទេមួយ បន្ទាប់មកសរសេរចម្លើយរបស់សិស្សស្តីពីអក្ខរកម្មហិរញ្ញវត្ថុ (FL) នៅលើក្តារខៀនជាទម្រង់ផែនទីគំនិត។ នៅខាងស្តាំនេះគឺជាឧទាហរណ៍នៃផែនទីគំនិត។

ចម្លើយមួយចំនួនដែលអាចមាននៅក្នុងផែនទីគំនិតរួមមានដូចខាងក្រោម៖ លុយ របស់របរកែច្នៃឡើងវិញ ការលក់ ធ្វើការងារ រកលុយ សន្សំ ធនាគារ កម្ចី និងបំណុលជាដើម។

**ផែនទីគំនិត** គឺជាដ្យាក្រាមរូបភាពដែលត្រូវបានប្រើដើម្បីរៀបចំទិន្នន័យ ឬព័ត៌មានផ្សេងៗទាក់ទងនឹងគំនិត ឬប្រធានបទមួយ។ ប្រធានបទនោះត្រូវសរសេរនៅចំកណ្តាលរង្វង់ ហើយសិស្សទាំងអស់អាចចែករំលែកពាក្យដែលផ្សាភ្ជាប់ទៅនឹងប្រធានបទនោះ។ ក្បួនច្បាប់សម្រាប់ផែនទីគំនិត៖

- គំនិតកាន់តែច្រើន កាន់តែល្អ!
- គ្មានការរិះគន់។
- គ្មានគំនិតណាជាគំនិតមិនល្អនោះទេ។
- បង្កើតគំនិតថ្មីផ្សេងទៀត។
- បញ្ចូលគំនិតទាំងអស់។

បន្ទាប់មក គ្រូសួរសិស្សទាំងអស់នូវសំណួរខាងក្រោម៖ បាទ/ចាស ទេ គ្មានយោបល់។

- តើប្អូនគិតថាក្មេងដែលមានអាយុដូចប្អូនអាចសិក្សាអំពីអក្ខរកម្មហិរញ្ញវត្ថុបានដែរឬទេ? ___ ___ ___
- ពេលប្អូនមានលុយ តើប្អូនធ្លាប់ជួយអ្នកដែលត្រូវការជំនួយដែរឬទេ? ___ ___ ___
- តើប្អូនគិតថាប្អូននឹងទទួលបានអត្ថប្រយោជន៍ពីការសិក្សាអំពីអក្ខរកម្មហិរញ្ញវត្ថុដែរឬទេ? ___ ___ ___
- តើប្អូនមានការរំពឹងទុកពីកម្មវិធីសិក្សានេះដែរឬទេ? ___ ___ ___

ប្រសិនបើសិស្សយល់ព្រម សូមឱ្យពួកគេលើកដៃ ឬក្រោកឈរ។ បន្ទាប់មក សូមឱ្យសិស្សផ្តល់មូលហេតុសម្រាប់សំណួរនីមួយៗ។ គ្រូកត់ត្រាចំនួនសិស្សដែលនិយាយថា «បាទ/ចាស» «ទេ» ឬ «គ្មានយោបល់»។ រយៈពេល១០នាទី។

**ចំណាំ៖** គ្រូត្រូវសរសេរចម្លើយរបស់សិស្ស (ពាក្យ/ឃ្លាគន្លឹះ) នៅលើក្តារខៀន ដើម្បីបង្កើតជានិយមន័យនៃអក្ខរកម្មហិរញ្ញវត្ថុ មុនពេលបញ្ចប់មេរៀនថ្ងៃនេះ។

គ្រូអរគុណសិស្សដែលបានចូលរួមយ៉ាងសកម្ម និងពន្យល់ថា ដោយប្រើប្រាស់ចម្លើយរបស់ប្អូនទាំងអស់ស្តីពីអក្ខរកម្មហិរញ្ញវត្ថុដែលបានសរសេរនៅលើក្តារខៀន យើងចង់បង្កើតនិយមន័យអក្ខរកម្មផ្នែកហិរញ្ញវត្ថុជាមួយគ្នា។ គ្រូឱ្យសិស្សធ្វើកិច្ចការជាដៃគូដើម្បីសរសេរនិយមន័យ ហើយពួកគេមានពេល៥នាទីដើម្បីបង្កើតនិយមន័យ។

ជាមួយដៃគូ សិស្សចាប់ផ្ដើមសរសេរនិយមន័យមួយនៃអក្ខរកម្មហិរញ្ញវត្ថុ។ សិស្សនឹងចែករំលែកនិយមន័យរបស់ពួកគេជាមួយមិត្តរួមថ្នាក់ទាំងអស់។

គ្រូសំយោគគំនិតរបស់សិស្សទាក់ទងនឹងនិយមន័យអក្ខរកម្មហិរញ្ញវត្ថុ។ គ្រូប្រៀបធៀបនិយមន័យរបស់សិស្សជាមួយនិយមន័យផ្លូវការនៃអក្ខរកម្មហិរញ្ញវត្ថុ ហើយសួរសិស្សថា តើនិយមន័យទាំងនេះដូចគ្នាយ៉ាងណា? តើខុសគ្នាយ៉ាងណា? តើមានអ្វីខ្វះខាតនៅក្នុងនិយមន័យរបស់សិស្ស?

បន្ទាប់ពីការពិភាក្សាខ្លីមួយ គ្រូបញ្ចប់ការពិភាក្សា ហើយសម្រេចចុងក្រោយលើនិយមន័យនៃអក្ខរកម្មហិរញ្ញវត្ថុ។ ខាងក្រោមនេះ គ្រូនឹងឃើញនិយមន័យរបស់អក្ខរកម្មហិរញ្ញវត្ថុ។

**និយមន័យរបស់កម្មវិធីសិក្សាអក្ខរកម្មហិរញ្ញវត្ថុ៖** អក្ខរកម្មហិរញ្ញវត្ថុ បង្កើតជំនាញរបស់សិស្សក្នុងការគ្រប់គ្រងប្រាក់ ការសម្រេចចិត្ត ការគ្រប់គ្រងខ្លួនឯង និងទំនួលខុសត្រូវក្នុងសង្គម។ សិស្សសិក្សាពីរបៀបរៀបចំថវិកា សន្សំ ចំណាយ និងបរិច្ចាគ ដែលអាចធ្វើឱ្យពួកគេមានភាពវិជ្ជមានលើទម្លាប់ហិរញ្ញវត្ថុ និងបង្កើនសុខុមាលភាពរបស់ពួកគេ។

**ចំណាំ៖** គ្រូក៏អាចប្រើនិយមន័យនៃអក្ខរកម្មហិរញ្ញវត្ថុរបស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ជាជម្រើសមួយបន្ថែមលើនិយមន័យខាងលើ៖

**និយមន័យរបស់ក្រសួងអប់រំ យុវជន និងកីឡា៖** អក្ខរកម្មហិរញ្ញវត្ថុ ជាការអនុវត្តចំណេះដឹង ការយល់ដឹង ជំនាញ គុណតម្លៃ និងអាកប្បកិរិយាក្នុងបរិបទហិរញ្ញវត្ថុ ដែលអនុញ្ញាតឱ្យបុគ្គលម្នាក់ៗធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹងពេញលេញ និងមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងប្រាក់របស់ខ្លួន ដែលជះឥទ្ធិពលលើខ្លួនឯង អ្នកដទៃ សហគមន៍ និងបរិស្ថាន។

**ការឆ្លុះបញ្ចាំង (៥នាទី)**

គ្រូសួរថា តើប្អូនបានរៀនអ្វីខ្លះនៅថ្ងៃនេះ? តើប្អូនចូលចិត្តអ្វីខ្លះសម្រាប់មេរៀនថ្ងៃនេះ? តើប្អូនទទួលបានចំណេះដឹងអ្វីខ្លះពីមេរៀននេះ ត្រឡប់ទៅផ្ទះវិញ?

## សន្លឹកកិច្ចការ២.១ ៖ តេស្តមុន ឬក្រោយវគ្គ

សូមយកចិត្តទុកដាក់អានការណែនាំសម្រាប់សំណួរខាងក្រោមទាក់ទងនឹងអក្ខរកម្មហិរញ្ញវត្ថុ បន្ទាប់មកជ្រើសរើសចម្លើយដែលប្អូនគិតថាត្រឹមត្រូវ។ សំណួរខ្លះអាចមានចម្លើយត្រឹមត្រូវច្រើនជាងមួយ ចំណែកឯសំណួរផ្សេងទៀតអាចមានចម្លើយត្រឹមត្រូវតែមួយប៉ុណ្ណោះ។

១- តើប្អូនធ្លាប់បានចូលរៀនវគ្គសិក្សាស្ដីពីអក្ខរកម្មហិរញ្ញវត្ថុពីមុនមកដែរឬទេ? □បាទ/ចាស □ទេ

២- អក្ខរកម្មហិរញ្ញវត្ថុសំដៅលើ៖ (សូមគូសយកចម្លើយទាំងឡាយណាដែលត្រឹមត្រូវ)

ក- ការសន្សំ

ខ- ការចំណាយ

គ- ការរកប្រាក់ចំណូល

៣- តើនរណាជាអ្នកទទួលខុសត្រូវលើការបោះពុម្ពក្រដាសប្រាក់នៅប្រទេសកម្ពុជា?

ក- ធនាគារ អេស៊ីលីដា

ខ- ធនាគារជាតិ

គ- ធនាគារ អ៊ូរី

ឃ- ធនាគារ ABA។

៤- តើរូបិយបណ្ណមួយណាត្រូវបានប្រើប្រាស់ក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន?

សូមយកចិត្តទុកដាក់អានការណែនាំសម្រាប់សំណួរខាងក្រោមទាក់ទងនឹងអក្ខរកម្មហិរញ្ញវត្ថុ បន្ទាប់មកជ្រើសរើសចម្លើយដែលប្អូនគិតថាត្រឹមត្រូវ។ សំណួរខ្លះអាចមានចម្លើយត្រឹមត្រូវច្រើនជាងមួយ ចំណែកឯសំណួរផ្សេងទៀតអាចមានចម្លើយត្រឹមត្រូវតែមួយប៉ុណ្ណោះ។

១- តើប្អូនធ្លាប់បានចូលរៀនវគ្គសិក្សាស្ដីពីអក្ខរកម្មហិរញ្ញវត្ថុពីមុនមកដែរឬទេ? □បាទ/ចាស □ទេ

២- អក្ខរកម្មហិរញ្ញវត្ថុសំដៅលើ៖ (សូមគូសយកចម្លើយទាំងឡាយណាដែលត្រឹមត្រូវ)

ក- ការសន្សំ

ខ- ការចំណាយ

គ- ការរកប្រាក់ចំណូល

ឃ- ការបរិច្ចាគ។

៣- តើនរណាជាអ្នកទទួលខុសត្រូវលើការបោះពុម្ពក្រដាសប្រាក់នៅប្រទេសកម្ពុជា?

ក- ធនាគារ អេស៊ីលីដា

ខ- ធនាគារជាតិ

គ- ធនាគារ អ៊ូរី

ឃ- ធនាគារ ABA។

៤- តើរូបិយបណ្ណមួយណាដែលកំពុងប្រើប្រាស់ក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន?

ក- 

ខ- 

គ- 

ឃ- 

៥- ក្នុងចំណោមជម្រើសខាងក្រោម តើប្អូននឹងត្រូវចំណាយប្រាក់សន្សំរបស់ប្អូនជាបន្ទាន់ទៅលើជម្រើសមួយណា?

ក- ការព្យាបាល

ខ- ម្ហូបអាហារ

គ- ទូរទស្សន៍ឆ្លាតវៃ

ឃ- ថ្ងៃឈប់សម្រាក។

៦- សូមរៀបលំដាប់វត្ថុខាងក្រោមពីតម្លៃថោកបំផុតទៅតម្លៃថ្លៃបំផុត ដោយផ្អែកលើបទពិសោធរបស់ប្អូន។

| សម្លៀកបំពាក់ | កង់ | សៀវភៅសរសេរ | កុំព្យូទ័រយួរដៃ |
|---|---|---|---|

| | |
|---|---|
| តម្លៃថោកបំផុត | ១- |
| | ២- |
| | ៣- |
| តម្លៃថ្លៃបំផុត | ៤- |

៧- សម្រាប់គោលដៅរយៈពេលខ្លី តើប្អូនគិតថាត្រូវសន្សំរយៈពេលប៉ុន្មាន? សូមជ្រើសរើសចម្លើយត្រឹមត្រូវ។

ក- ១ ឆ្នាំ

ខ- ៦ ខែ

គ- ៣ ឆ្នាំ

ឃ- ៩ ខែ។

៨- តើប្អូនគិតថាក្មេងអាយុប្រហែលប្អូនអាចសន្សំប្រាក់នៅធនាគារបានដែរឬទេ? □បាទ/ចាស □ទេ

៩- តើប្អូនសន្សំប្រាក់ញឹកញាប់ប៉ុណ្ណា?

ក- ជានិច្ចកាល

ខ- ញឹកញាប់

គ- ម្តងម្កាល

ឃ- កម្រណាស់

ង- មិនដែលទេ។

១០- តើការកែច្នៃរបស់របរឡើងវិញជាផ្នែកមួយនៃសកម្មភាពសន្សំដែរឬទេ? □បាទ/ចាស □ទេ

១១- តើវត្ថុមួយណាខាងក្រោមមិនមែនជាគោលដៅសន្សំរយៈពេលខ្លី? (សូមជ្រើសរើសចម្លើយត្រឹមត្រូវ)

ក- ស្បែកជើង

ខ- កង់

គ- វចនានុក្រម

ឃ- ម៉ូតូ។

១២- តើវត្ថុមួយណាខាងក្រោមជាគោលដៅសន្សំរយៈពេលវែង? (សូមជ្រើសរើសចម្លើយត្រឹមត្រូវ)

ក- កាតាប

ខ- សៀវភៅរឿង

គ- នាឡិកាឆ្លាតវៃ

ឃ- សម្លៀកបំពាក់។

១៣- តើរបស់មួយណាខាងក្រោមជាការចង់បាន? (សូមជ្រើសរើសចម្លើយត្រឹមត្រូវ)

ក- ម្ហូបអាហារ

ខ- ទឹក

គ- ទូរសព្ទឆ្លាតវៃ

ឃ- ទីជម្រកស្នាក់នៅ។

១៤- តើវត្ថុមួយណាខាងក្រោមជាតម្រូវការ? (សូមជ្រើសរើសចម្លើយត្រឹមត្រូវ)

ក- ក្តារជិះស្គី

ខ- នាឡិកាថ្លៃៗ

គ- សម្លៀកបំពាក់

ឃ- សម្លៀកបំពាក់ហ៊ឺហា។

១៥- វិធីល្អបំផុតដើម្បីបង្កើនប្រាក់របស់ប្អូនគឺ៖

ក- ចំណាយតិចជាងមុន

ខ- ទិញច្រើនជាងមុន

គ- ញ៉ាំច្រើនជាងមុន

ឃ- ចម្លើយទាំងអស់ខាងលើ។

១៦- តើរបស់មួយណាខាងក្រោមដែលអាចបរិច្ចាគបាន?

ក- ពេលវេលា

ខ- ជំនាញ

គ- ទំនិញ

ឃ- ចម្លើយទាំងអស់ខាងលើ។

១៧- តើល្បះមួយណាដែលបង្ហាញពីវិធីនៃការផ្តល់ឱ្យសហគមន៍វិញ?

ក- ជួយមនុស្សដែលត្រូវការជំនួយ

ខ- ការជួយដោយខ្លួនមិនពេញចិត្ត

គ- ធ្វើឱ្យល្បីល្បាញនៅក្នុងសហគមន៍

ឃ- បង្កបញ្ហាដល់មនុស្សដែលត្រូវការជំនួយ។

១៨- តើប្អូនមានទំនុកចិត្តកម្រិតណាក្នុងការនិយាយអំពីការសន្សំប្រាក់ជាមួយក្រុមគ្រួសារ និងមិត្តភក្តិ?

ក- មានទំនុកចិត្តខ្លាំងណាស់

ខ- មានទំនុកចិត្ត

គ- មានទំនុកចិត្តខ្លះ

ឃ- មិនសូវមានទំនុកចិត្តសោះ

ង- គ្មានទំនុកចិត្តសោះ។

# មេរៀនទី ៣ ប្រវត្តិប្រាក់រៀល

| | |
|---|---|
|  | រយៈពេល៖ ៤០នាទី |
|  | **ការត្រៀមមុនបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ថតចម្លងរូបភាព<br>- ថតចម្លងសន្លឹកកិច្ចការ ៣.១<br>- បោះពុម្ពផ្ទាំងរូបភាពទី១។ |
|  | **សម្ភារៈ ធនធានដែលចាំបាច់**<br>- រូបភាព៖ ការដោះដូរទំនិញ (រូបភាពត្រី និង គ្រាប់សណ្ដែក)<br>- សន្លឹកកិច្ចការ ៣.១៖ ករណីសិក្សា (ការវិវត្តនៃលុយ)<br>- ក្រដាស កន្ត្រៃ ក្រដាសពណ៌ កម្រងស្នាដៃរបស់សិស្ស<br>- ផ្ទាំងរូបភាពទី១៖ ការវិវត្តនៃប្រាក់រៀលនៅប្រទេសកម្ពុជា។ |
|  | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- ពណ៌នាអំពីវិធីផ្សេងគ្នានៃការផ្លាស់ប្ដូរទំនិញ កាក់ និងប្រាក់<br>- ពន្យល់ពីការវិវត្តនៃប្រាក់រៀលនៅកម្ពុជា<br>- កាន់តែស្គាល់រូបិយបណ្ណរបស់ខ្មែរ។ |

### សេចក្ដីផ្ដើម៖ (៥នាទី)

គ្រូស្វាគមន៍សិស្ស៖ សួស្ដីសិស្សទាំងអស់គ្នា។ តើប្អូនចាំបានអ្វីខ្លះពីច្បាប់ម្រាមដៃទាំងប្រាំនៅក្នុងថ្នាក់យើង? គ្រូគួររំលឹកសិស្សថា ត្រូវលើកដៃជាមុនសិន មុននឹងឆ្លើយសំណួរ។ គ្រូណែនាំអំពីមេរៀនថ្មី៖ យើងនឹងចាប់ផ្ដើមមេរៀនថ្មីមួយដែលមានចំណងជើងថា **ប្រវត្តិប្រាក់រៀល**។ បច្ចុប្បន្នជាសម័យទំនើប មានធនាគារក្នុងការទុកដាក់ប្រាក់ ប៉ុន្តែវាសំខាន់ផងដែរដើម្បីដឹងពីប្រវត្តិប្រាក់រៀល។ តើប្អូនគិតថា រាប់ពាន់ឆ្នាំមុនមនុស្សបានប្រើអ្វីក្នុងការទិញដូរ? តស់ ស្វែងយល់ពីប្រវត្តិរបស់ប្រាក់រៀលទាំងអស់គ្នា។

## សកម្មភាពសំខាន់ទី១៖ ប្រវត្តិរបស់ប្រាក់រៀលនៃប្រទេសកម្ពុជា (២០នាទី)

**គ្រូបង្ហាញរូបភាព៣.១៖** ការដោះដូរទំនិញ (ត្រី និងគ្រាប់សណ្ដែក) ដល់ថ្នាក់ទាំងមូល ហើយសួរថា តើប្អូនឃើញអ្វីខ្លះនៅក្នុងរូបភាពនេះ? ឬរូបភាពនេះនិយាយអំពីអ្វី? សិស្សនឹងចែករំលែកគំនិតនៅក្នុងថ្នាក់ ហើយគ្រូសម្របសម្រួលគំនិត ព្រមទាំងពន្យល់ថា រយៈពេលរាប់ពាន់ឆ្នាំមុន ប្រជាជនខ្មែរមិនប្រើប្រាក់ទាល់តែសោះ។ មធ្យោបាយនៃការទូទាត់របស់ពួកគេគឺ តាមរយៈការដោះដូរ ឬផ្លាស់ប្ដូរទំនិញគ្នាទៅវិញទៅមក។

តស់ យើងស្វែងយល់ពីគំនិតនេះទាំងអស់គ្នា។

គ្រូបែងចែកសិស្សជាក្រុម ក្នុងមួយក្រុមមានគ្នាពី៤-៦នាក់ (ចម្រុះសិស្សប្រុសស្រី)។ គ្រូចែកសន្លឹកកិច្ចការ ៣.១៖ ករណីសិក្សា (ការវិវត្តនៃប្រាក់រៀល) ដល់សិស្សគ្រប់គ្នាអានដោយស្ងៀមស្ងាត់រយៈពេលពី១០-១៥នាទី ហើយឆ្លើយសំណួរដែលបានផ្តល់ជូនក្នុងករណីសិក្សា។ បន្ទាប់មក សិស្សរំលែកគំនិតរបស់ពួកគេស្តីពីរឿងនោះ ហើយឆ្លើយសំណួរដែលមាននៅក្នុងក្រុមតូចៗរបស់ពួកគេ។ សមាជិកម្នាក់កត់ត្រាគំនិតដែលបានពិភាក្សា និងចម្លើយនៅលើក្រដាស A4 ហើយបង្ហាញដល់មិត្តរួមថ្នាក់ទាំងមូល។ បញ្ជីខាងក្រោមគឺ ជាសេចក្តីសង្ខេបនៃសំណួរសំខាន់ៗមួយចំនួនដែលក្រុមត្រូវឆ្លើយ។ គ្រូស្តាប់ចម្លើយរបស់ក្រុម និងផ្តល់ការណែនាំដែលចាំបាច់ ប្រសិនបើចម្លើយហាក់ដូចជាខុស។

គ្រូអាចបង្ហាញសំណួរដែលមានក្នុងករណីសិក្សានៅលើក្តារខៀនដើម្បីឱ្យសិស្សបានឃើញទាំងអស់គ្នា។

១- តើមនុស្សប្រើប្រាស់អ្វីខ្លះ ដើម្បីដោះដូរ ឬទិញ?

២- បើមនុស្សយករបស់របរដូចជា អង្ករ សាច់ជាដើម ដើម្បីដោះដូរសម្រាប់ជីវិតប្រចាំថ្ងៃ តើវាមានភាពងាយស្រួល ឬពិបាក? ហេតុអ្វី?

៣- តើមនុស្សបានបង្កើតអ្វីខ្លះ ដើម្បីទិញអ្វីមួយកាន់តែមានភាពងាយស្រួល និងឆាប់រហ័ស?

៤- ក្រោយអាណានិគមបារាំង តើរូបិយបណ្ណប្រាក់រៀលចាប់ផ្តើមបោះពុម្ពនៅពេលណា? ដោយនរណា?

៥- តើមានអ្វីកើតឡើងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩?

៦- ហេតុអ្វីបានជាកម្ពុជាប្រើប្រាក់ដុល្លារអាមេរិកដែរ?

### ចម្លើយសំខាន់ៗដែលអាចកើតមាន៖

១- មុនពេលប្រើប្រាក់ មនុស្សបានទិញរបស់របរដោយការផ្លាស់ប្តូរគ្នាដូចជា គ្រាប់ពូជ ស្រូវ សត្វ ផ្លែឈើ។

២- វាអាចមានភាពងាយស្រួលប្រសិនបើអ្នកប្តូររបស់មួយស្មើៗគ្នា។ វាមិនងាយស្រួលទេ ប្រសិនបើអ្នកប្តូររបស់មួយ និងបានមកវិញនូវរបស់ច្រើនដែលពិបាកយកតាមខ្លួន ដោយសារទម្ងន់និងទំហំ។ *ឧទាហរណ៍៖* ត្រីពីរក្បាល ត្រូវប្តូរបានមកវិញនូវបន្លែមួយកន្ត្រក គ្រឿងផ្សំ និងអង្ករ។ល។

៣- មនុស្សបានបង្កើតប្រាក់ដំបូងដោយប្រើលោហៈ ហើយក្រោយមកទៀតបង្កើតជាក្រដាសប្រាក់វិញ ពីព្រោះវាស្រាលជាង និងងាយស្រួលប្រើ។

៤- ប្រទេសកម្ពុជាបានចាប់ផ្តើមប្រើប្រាស់ប្រាក់រៀលនៅឆ្នាំ១៩៥៤។ ប្រាក់នេះត្រូវបានបោះពុម្ពដោយធនាគារជាតិនៃកម្ពុជា។

៥- ចន្លោះឆ្នាំ១៩៧៥ដល់១៩៧៩ របបខ្មែរក្រហមបានបំផ្លាញប្រព័ន្ធសេដ្ឋកិច្ចនិងប្រព័ន្ធធនាគារផងដែរ។

៦- កម្ពុជាក៏ប្រើប្រាក់ដុល្លារដែរ ព្រោះនៅឆ្នាំ១៩៩១ និង១៩៩២ ពេលអង្គការសហប្រជាជាតិ អាជ្ញាធរអន្តរកាល (អ៊ុនតាក់) កសាងរដ្ឋនៅកម្ពុជាឡើងវិញ ប្រាក់ដុល្លារបានប្រើប្រាស់រហូតដល់សព្វថ្ងៃ។

## សកម្មភាពសំខាន់ទី២៖ ផ្ទាំងរូបភាពការវិវត្តនៃប្រាក់រៀលនៅប្រទេសកម្ពុជា (២០នាទី)

បន្ទាប់មក គ្រូបង្ហាញផ្ទាំងរូបភាពទី១៖ ការវិវត្តនៃប្រាក់រៀលក្នុងប្រទេសកម្ពុជាដល់សិស្សទាំងអស់ក្នុងថ្នាក់។ គ្រូឱ្យសិស្សសង្កេតនិងស្វែងយល់ពីការផ្លាស់ប្តូររូបិយបណ្ណកម្ពុជាអំឡុងទសវត្សរ៍ឆ្នាំ១៩៥០រហូតដល់សព្វថ្ងៃ។

គ្រូសួរសំណួរទៅកាន់ក្រុមធំ៖

- តើប្អូនបានឃើញអ្វីខ្លះនៅលើក្រដាសប្រាក់?
- តើក្រដាសប្រាក់រៀលដែលមានតម្លៃតិចជាងគេបំផុតមានតម្លៃប៉ុន្មាន? តើក្រដាសប្រាក់នោះបានបង្កើតនៅឆ្នាំណា?
- តើក្រដាសប្រាក់រៀលដែលមានតម្លៃច្រើនជាងគេបំផុតមានតម្លៃប៉ុន្មាន? តើរូបភាពក្នុងក្រដាសប្រាក់នោះប្រាប់ពីអ្វី?

### ប្រវត្តិប្រាក់រៀលនៅកម្ពុជា

បន្ទាប់ពីប្រទេសកម្ពុជាទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ ប្រាក់រៀលកម្ពុជាត្រូវបានបង្កើតឡើងដើម្បីជំនួសប្រាក់ ព្យ៉ាស់ ដែលជារូបិយបណ្ណឥណ្ឌូចិនបារាំង។

១៩៥៦-១៩៧០៖ ព្រះរាជាណាចក្រកម្ពុជា (ភាសាផ្លូវការពីរ៖ ភាសាខ្មែរនិងភាសាបារាំង) ក្រដាសប្រាក់បង្ហាញពីការរស់នៅបែបជនបទធម្មតារបស់ប្រជាជនកម្ពុជា ដែលមានរូបភាពច្រូតកាត់ នេសាទ និងការងារធ្វើស្រែចម្ការជាដើម។

**១៩៧០-១៩៧៥៖ សម័យសាធារណរដ្ឋខ្មែរ**

សម័យសាធារណរដ្ឋខ្មែរ រដ្ឋរបស់កម្ពុជាស្ថិតក្រោមរបបផ្តាច់ការយោធា ដែលគាំទ្រដោយសហរដ្ឋអាមេរិករបស់សេនាប្រមុខ លន់ នល់ ពីឆ្នាំ១៩៧០ដល់១៩៧៥។ ក្រដាសប្រាក់នាពេលនោះមានរូបភាព ស្ត្រីតម្បាញសិស្សានុសិស្សរៀន កវីក្រមង៉ុយ (អ៊ុក អ៊ូ) នៅលើក្រដាសប្រាក់៥ ០០០រៀល។

**១៩៧៥-១៩៧៩៖ របបខ្មែរក្រហម**

អំឡុងរបបខ្មែរក្រហមចាប់តាំងឆ្នាំ១៩៧៥ ពួកគេបានលុបបំបាត់ការប្រើប្រាស់ប្រាក់រៀលទាំងស្រុង ហើយបានបង្កើតរូបិយប័ណ្ណថ្មីមួយដែរ ប៉ុន្តែមិនបានប្រើប្រាស់ជាសាធារណៈឡើយ។

**១៩៧៩-១៩៩០៖ សាធារណរដ្ឋប្រជាមានិតកម្ពុជា**

ក្រោយពីរបបប៉ុលពតត្រូវបានផ្តួលរំលំនៅឆ្នាំ១៩៧៩ ប្រាក់រៀលក៏ត្រូវបានបោះពុម្ពជាថ្មីនិងដាក់ឱ្យចរាចរឡើងវិញនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០។ ប្រាក់រៀលក៏ត្រូវបានធ្វើបច្ចុប្បន្នកម្មជាលំដាប់ ដោយមានរូបភាពបុព្វបុរសខ្មែរ ប្រជាជន និងសកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ចដើម្បីជំរុញសាមគ្គីភាពជាតិ។

**១៩៩០-១៩៩២៖ សម័យរដ្ឋកម្ពុជា**

អង្គការសហប្រជាជាតិបានផ្តល់ជំនួយមនុស្សធម៌ជាប្រាក់ដុល្លារអាមេរិកដល់ប្រទេសកម្ពុជា ហើយប្រាក់ដុល្លារក៏បានចាប់ផ្តើមចរាចរកាន់តែច្រើនឡើងៗចាប់តាំងពីពេលនោះមក។ ប្រជាជនកម្ពុជាភាគច្រើនចូលចិត្តប្រើប្រាស់ប្រាក់ដុល្លារដើម្បីទិញដូរទំនិញនិងសេវាកម្មផ្សេងៗ។ ចំណែកឯរូបិយបណ្ណប្រាក់រៀលនៅតែបន្តចរាចរជាធម្មតា ហើយនៅលើក្រដាសប្រាក់រៀលបានបង្ហាញពីបូជនីយដ្ឋានខ្មែរ និងរូបភាពលោក សឹង ង៉ុកមិញ។

នៅឆ្នាំ១៩៧៩ ប្រាក់កាក់ដែលមានតម្លៃប្រាំសេន ដែលធ្វើពីអាលុយមីញ៉ូម បានបោះពុម្ពជាលើកដំបូង។ បន្ទាប់មកពុំមានផលិតប្រាក់កាក់បន្ថែមទៀតឡើយ រហូតដល់ឆ្នាំ១៩៩៤ ទើបមានការផលិតប្រាក់កាក់បន្ថែមដែលមានតម្លៃហាសិបរៀល មួយរយរៀល ពីររយរៀល និងប្រាំរយរៀល។ ដោយសារប្រាក់កាក់ដែលផលិតពីអាលុយមីញ៉ូមមានទម្ងន់ធ្ងន់ និងពិបាកទុកដាក់ ប្រជាពលរដ្ឋខ្មែរពុំសូវនិយមប្រើប្រាស់ប្រាក់កាក់នោះឡើយ។

សរុបនៃមេរៀនថ្ងៃនេះ តើប្អូនបានរៀនអ្វីខ្លះក្នុងថ្ងៃនេះ?

រូបភាព៖ ការដោះដូរទំនិញ (ត្រី និងគ្រាប់សណ្តែក)



## សន្លឹកកិច្ចការ ៣.១៖ ករណីសិក្សា

នៅពេលដែលមនុស្សជាអ្នកបរបាញ់ ឬកសិករ ការដោះដូរជាទំនិញដំណើរការបានល្អ។ កសិករអាចយកស្រូវដូរយកបន្លែ ឬអ្នកបរបាញ់អាចយកសាច់ដូរយកស្រូវ។ ឧទាហរណ៍៖ ប្រសិនបើអ្នកមានមាន់មួយក្បាល អ្នកអាចដូរបានអង្ករពីរបាវ។ នៅពេលដែលជីវិតកាន់តែស្មុគស្មាញ ការដោះដូរជាទំនិញក៏មានភាពស្មុគស្មាញផងដែរ។ ការដោះដូរជាទំនិញនាំឱ្យមានការភាន់ច្រឡំ ហើយមនុស្សត្រូវការវិធីល្អជាងនេះដើម្បីធ្វើអាជីវកម្ម។




ក្រោយមកគេបានបង្កើតប្រាក់ ដោយប្រើលោហៈផ្សេងៗ។ នៅពេលដែលគេមានអារម្មណ៍ថាលោហៈមានទម្ងន់ធ្ងន់ពេក គេបានសម្រេចចិត្តប្រើប្រាក់ជាក្រដាស ដែលក្រោយមកបានវិវត្តទៅជាប្រាក់នាពេលបច្ចុប្បន្ន។



សម្តេចសីហនុ ដណ្តើមបានឯករាជ្យពេញលេញពីប្រទេសបារាំង និងបានបោះពុម្ពរូបិយបណ្ណជាតិដំបូងរបស់ខ្លួនគឺ ប្រាក់រៀលនៅក្នុងធនាគារជាតិនៃកម្ពុជាក្នុងឆ្នាំ ១៩៥៤។ ប៉ុន្តែពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ក្រោមរបបខ្មែរក្រហម ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុទាំងអស់នៅក្នុងប្រទេសកម្ពុជា (ទីផ្សារពាណិជ្ជកម្ម ប្រាក់ និងធនាគារ) ត្រូវបានបំផ្លាញជាប្រព័ន្ធ។

នៅឆ្នាំ១៩៩១-១៩៩២ ប្រាក់ដុល្លារបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងសេដ្ឋកិច្ចកម្ពុជា នៅពេលដែលអាជ្ញាធរអន្តរកាលអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) ចូលមកកសាងរដ្ឋឡើងវិញ។ ពួកគេនាំយកប្រាក់ដុល្លាររបស់សហរដ្ឋអាមេរិកដើម្បីធ្វើពាណិជ្ជកម្ម ទំនិញ ឬវត្ថុផ្សេងៗទៀត។ រូបិយបណ្ណពីរ (រៀលនិងដុល្លារ) ត្រូវបានប្រើប្រាស់ជាផ្លូវការក្នុងប្រទេសកម្ពុជា។ រដ្ឋាភិបាលជំរុញឱ្យប្រជាពលរដ្ឋប្រើប្រាស់រូបិយបណ្ណប្រាក់រៀលឱ្យបានច្រើន ដើម្បីស្ថិរភាពសេដ្ឋកិច្ចជាតិ។



១- តើមនុស្សប្រើប្រាស់អ្វីខ្លះ ដើម្បីដោះដូរ ឬទិញ?

២- បើមនុស្សយករបស់របរដូចជា អង្ករ សាច់ជាដើម ដើម្បីដោះដូរសម្រាប់ជីវិតប្រចាំថ្ងៃ តើវាមានភាពងាយស្រួល ឬពិបាក? ហេតុអ្វី?

៣- តើមនុស្សបានបង្កើតអ្វីខ្លះ ដើម្បីទិញអ្វីមួយកាន់តែមានភាពងាយស្រួល និងឆាប់រហ័ស ?

៤- ក្រោយអាណានិគមបារាំង តើរូបិយបណ្ណប្រាក់រៀលចាប់ផ្តើមបោះពុម្ពនៅពេលណា? ដោយនរណា?

៥- តើមានអ្វីកើតឡើងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩?

៧- ហេតុអ្វីបានជាកម្ពុជាប្រើប្រាក់ដុល្លារអាមេរិកដែរ?

## ផ្ទាំងរូបភាពទី១៖




ប្រភព៖ ធនាគារជាតិ នៃ កម្ពុជា

# មេរៀនទី ៤ ការប៉ាន់ស្មានតម្លៃទំនិញ

| | |
|---|---|
|  | រយៈពេល៖ ៤០នាទី |
|  | ការត្រៀមមុនបង្រៀន<br>- អានមេរៀនទាំងមូល<br>- ថតចម្លងសន្លឹកកិច្ចការ ៤.១ និងទី៤.២។ |
|  | សម្ភារៈ ធនធានដែលចាំបាច់<br>- សន្លឹកកិច្ចការ ៤.១៖ ចូរប៉ាន់ស្មានតម្លៃទំនិញ<br>- សន្លឹកកិច្ចការ ៤.២៖ ការចង់បាន និងតម្រូវការ<br>- ក្រដាសវ៉ាម A4។ |
|  | លទ្ធផលសិក្សា៖<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- ប៉ាន់ប្រមាណតម្លៃនៃវត្ថុផ្សេងៗដែលពួកគេបានឃើញ<br>- កំណត់អាទិភាពជ្រើសរើសវត្ថុទាក់ទងនឹងតម្រូវការ ឬចំណង់។ |

### សេចក្តីផ្តើម ( ៥នាទី )

គ្រូស្វាគមន៍សិស្ស៖ សូមស្វាគមន៍ត្រឡប់មកកាន់ថ្នាក់អក្ខរកម្មហិរញ្ញវត្ថុ! តើប្អូនមានអារម្មណ៍យ៉ាងណានៅថ្ងៃនេះ? ប្រសិនបើប្អូនមានអារម្មណ៍ល្អ ឬមានថាមពលខ្លាំង សូមលើកមេដៃទាំងពីរឡើង។ ប្រសិនបើមានអារម្មណ៍ធម្មតា សូមបង្ហាញមេដៃទាំងពីរត្រង់ធម្មតា។ ហើយប្រសិនបើមានអារម្មណ៍មិនសប្បាយចិត្ត ឬអស់កម្លាំង សូមទម្លាក់មេដៃទាំងពីរចុះ។

បន្ទាប់ពីលំហាត់នេះ គ្រូគួសង្កេតអារម្មណ៍របស់សិស្សភាគច្រើន។ ឧទាហរណ៍៖ ការប្រើប្រយោគដូចជា៖

- មើលទៅដូចជាអ្នកគ្រប់គ្នាមានអារម្មណ៍ល្អណាស់នៅថ្ងៃនេះ។ វាគួរតែជាពេលវេលាល្អសម្រាប់មេរៀនថ្ងៃនេះ។
- មើលទៅដូចជាអ្នកភាគច្រើន ឬមួយចំនួននឿយហត់បន្តិចនៅថ្ងៃនេះ។ តើមានហេតុផលជាក់លាក់ដែរទេ?

មុននឹងចាប់ផ្តើមមេរៀន គ្រូសួរថា តើប្អូនណាចង់ចែករំលែកអ្វីដែលយើងបានរៀនកាលពីម្សិលមិញ?

គ្រូប្រហែលជាត្រូវបង្កើតបញ្ជីខ្លីមួយនៅលើក្តារខៀនអំពីអ្វីដែលសិស្សបានរៀននៅក្នុងមេរៀនមុន។ គូសបញ្ជាក់ចំណុចណាមួយដែលអាចពាក់ព័ន្ធ ជាពិសេសពាក់ព័ន្ធនឹងមេរៀនថ្ងៃនេះ។

### សកម្មភាពសំខាន់ទី១៖ ការប៉ាន់ស្មានតម្លៃទំនិញ ( ១០នាទី )

គ្រូចាប់ផ្តើមមេរៀនថ្មី៖ ការប៉ាន់ស្មានតម្លៃទំនិញ ហើយបន្ទាប់មកសួរសំណួរសិស្សទាំងអស់គ្នា៖ តើប្អូនដឹងពីតម្លៃរបស់វត្ថុជុំវិញខ្លួនដែរឬទេ?

គ្រូឱ្យសិស្សធ្វើការជាដៃគូ ហើយចែកសន្លឹកកិច្ចការ៤.១៖ ការប៉ាន់ស្មានតម្លៃ ដោយមានការណែនាំដូចខាងក្រោម៖

- មានវត្ថុបួនប្រភេទដូចជា សម្ភារៈបន្ទប់ទឹក សម្ភារៈផ្ទះបាយ សម្ភារៈនៅសាលារៀន និងសម្ភារៈកម្សាន្ត។
- ដៃគូនីមួយៗ សរសេរតម្លៃលើវត្ថុទាំងនោះ។
- បន្ទាប់មកឱ្យដៃគូនីមួយៗ ផ្លាស់ប្តូរសន្លឹកកិច្ចការជាមួយដៃគូផ្សេងទៀតដើម្បីប្រៀបធៀបតម្លៃគ្នា។

បន្ទាប់មក គ្រូសួរសំណួរដល់សិស្សទាំងអស់៖

- តើប្អូនឃើញថាការប៉ាន់ស្មានតម្លៃទំនិញរវាងដៃគូប្អូន ដូចគ្នានឹងដៃគូផ្សេងដែរឬទេ? ហេតុអ្វី?
- ចម្លើយអាចឆ្លើយ៖ ការប៉ាន់ស្មានប្រែប្រួលឬមិនដូចគ្នា គឺអាស្រ័យលើបទពិសោធរបស់មនុស្សម្នាក់ៗ។
- តើប្អូនដឹងដោយរបៀបណាថាតើវត្ថុ ឬទំនិញដែលប្អូនទិញមិនថ្លៃពេក?
- ចម្លើយអាចឆ្លើយ៖ ប្រៀបធៀបតម្លៃនៅក្នុងហាងផ្សេងៗគ្នាដើម្បីទទួលបានតម្លៃធូរថ្លៃ ឬសួរអ្នកដែលដឹងតម្លៃនោះ។
- តើប្អូនអាចបានប្រាក់ដោយរបៀបណា ដើម្បីទិញទំនិញទាំងនេះ? ចម្លើយអាចឆ្លើយ៖ បានពីឪពុកម្តាយ
- ប្រសិនបើឪពុកម្តាយរបស់ប្អូនទិញទំនិញទាំងនេះ តើពួកគាត់បានលុយតាមរបៀបណា? ចម្លើយអាចឆ្លើយ៖ បានពីការធ្វើការងារ។

> ការប៉ាន់ស្មានតម្លៃ ជួយសិស្សស្វែងយល់ពីគំនិតនៃប្រាក់ និងតម្លៃរបស់វានៅក្នុងជីវិតប្រចាំថ្ងៃ។ សិស្សកាន់តែយល់ដឹងអំពីតម្លៃទំនិញ និងសេវាកម្ម ដើម្បីសម្រេចចិត្តដោយមានពត៌មានគ្រប់គ្រាន់។ លើសពីនេះ ការអនុវត្តការប៉ាន់ស្មានតម្លៃអាចបង្កើនសមត្ថភាពរបស់សិស្សក្នុងការគណនាលេខបានរហ័ស និងលើកទឹកចិត្តពួកគេឱ្យគិតពីកត្តាផ្សេងៗដូចជា ទំហំ បរិមាណ និងគុណភាព នៅពេលធ្វើការប៉ាន់ស្មានតម្លៃ។ សរុបមក សិស្សអាចប្រើអក្ខរកម្មហិរញ្ញវត្ថុ និងមានការទទួលខុសត្រូវបន្ថែមទៀតនាពេលអនាគត។

### សកម្មភាពសំខាន់ទី២៖ ការចង់បាន ឬតម្រូវការ (២០នាទី)

គ្រូចាប់ផ្តើមសកម្មភាពនេះដោយសរសេរពាក្យទាំងពីរនេះ (ការចង់បាន និងតម្រូវការ) នៅលើក្តារខៀន និងចាប់ផ្តើមការពិភាក្សារយៈពេលបីនាទីជាមួយសិស្សទាំងអស់ដោយសួរថា តើពាក្យទាំងពីរនេះខុសគ្នាដូចម្តេច។ គ្រូសរសេរនិយមន័យនៃការចង់បាន ឬតម្រូវការនៅចុងបញ្ចប់នៃមេរៀន។

បន្ទាប់មកសិស្សធ្វើការងារជាក្រុមដោយមានគ្នាពី៤-៦នាក់ និងមានការណែនាំដូចខាងក្រោម៖ (១៥នាទី)

- គ្រូផ្តល់សន្លឹកកិច្ចការ៤.២៖ ការចង់បាន និងតម្រូវការដល់ក្រុមនីមួយៗ។
- ក្រុមនីមួយៗជ្រើសរើសវត្ថុបីដើម្បីបង្ហាញពីការចង់បានដោយសរសេរអក្សរកាត់(ច) នៅក្បែរវត្ថុទាំងនោះ និងជ្រើសរើសវត្ថុបីផ្សេងទៀតបង្ហាញពីតម្រូវការ ដោយសរសេរអក្សរកាត់(ត) នៅក្បែរវត្ថុទាំងនោះ។
- ក្រុមនីមួយៗគួរពន្យល់ពីមូលហេតុដែលគិតថាវត្ថុនោះជាតម្រូវការឬការចង់បាន។ គ្រូគូរតារាងចំណាត់ថ្នាក់ការចង់បាននិងតម្រូវការ ជាមួយឧទាហរណ៍គំរូ។ សិស្សធ្វើចំណាត់ថ្នាក់វត្ថុដែលពួកគេបានជ្រើសរើសទៅក្នុងកូឡោនការចង់បាន ឬតម្រូវការ។

- ក្រុមនីមួយៗពន្យល់ថា ហេតុអ្វីវត្ថុនោះស្ថិតក្នុងកូឡោនតម្រូវការ ឬកូឡោនការចង់បាន?
- គ្រូផ្តល់ក្រដាសរ៉ាម A4 ដល់ក្រុមនីមួយៗ ដើម្បីគូរតារាងដូចដែលបង្ហាញនៅលើក្តារខៀន បន្ទាប់មកក្រុមនីមួយៗសរសេរឈ្មោះវត្ថុដែលបានជ្រើសរើសក្នុងកូឡោន ការចង់បាន ឬតម្រូវការ។
- ក្រុមនីមួយៗពន្យល់ពីមូលហេតុនៃវត្ថុដែលបានដាក់ក្នុងកូឡោន ការចង់បាន ឬតម្រូវការ។
- គ្រូសម្របសម្រួលចម្លើយសិស្ស។

| វត្ថុ | តម្រូវការ | ការចង់បាន | ការពន្យល់ |
|---|---|---|---|
| ឧទាហរណ៍៖ ម្ហូបអាហារ | ✓ | | អាហារគឺចាំបាច់សម្រាប់បរិភោគ និងទ្រទ្រង់ជីវិត។ យើងមិនអាចរស់បាន ប្រសិនបើគ្មានអាហារ។ |
| ឧទាហរណ៍៖ ទូរសព្ទឆ្លាតវៃ | ✓ | | ទូរសព្ទប្រើប្រាស់ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយមនុស្ស ប៉ុន្តែមានវិធីផ្សេងទៀត ដើម្បីទំនាក់ទំនងគ្នា។ វាមិនចាំបាច់ខ្លាំងទេ។ |
| | | | |
| | | | |

គ្រូសួរសិស្សជាក្រុមធំ៖ ដូចម្តេចដែលហៅថា ការចង់បានឬតម្រូវការ? គ្រូសរសេរនិយមន័យការចង់បាន និងតម្រូវការនៅលើក្តារខៀន។

**ការចង់បាន៖** ការប្រាថ្នាចង់បានអ្វីមួយ។ ការចង់បានសំដៅលើរបស់ដែលអ្នកចង់មាន ប៉ុន្តែមិនចាំបាច់នោះទេ។ ការចង់បានអាចប្រែប្រួលតាមពេលវេលា។

**តម្រូវការ៖** តម្រូវការសំដៅលើអ្វីមួយដែលអ្នកត្រូវតែមានដើម្បីរស់។ តម្រូវការគឺ ថេរនិងមិនប្រែប្រួល។ ឧទាហរណ៍៖ អាហារ សម្លៀកបំពាក់ ការអប់រំ និងទីជម្រក ត្រូវការវាជាប្រចាំ។

## ការឆ្លុះបញ្ចាំង ( ៥នាទី )

គ្រូអានសំណួរ បន្ទាប់មកសុំឱ្យសិស្សលើកដៃ ប្រសិនបើពួកគេគិតថា វាត្រឹមត្រូវ ឬមិនត្រឹមត្រូវ។

១- តើរបស់មួយណាជាការចង់បាន?

ក- ម្ហូបអាហារ ខ- ទឹក គ- កង់ ឃ- សម្លៀកបំពាក់។

២- តើរបស់មួយណាជាតម្រូវការ?

ក- ទីជម្រក ខ- នាឡិកាថ្លៃ គ- ទូរទស្សន៍ ឃ- សម្លៀកបំពាក់ហ៊ីហា។

៣- អ្នកឃើញនាឡិកាដៃស្អាតមួយដែលចង់បាន។ អ្នកមិនមានលុយទេ ហើយតើអ្នកនឹងធ្វើដូចម្តេចដើម្បីបានរបស់នោះ?

៤- ប្រសិនបើឪពុកម្ដាយរបស់អ្នកអាចចិញ្ចឹមអ្នកដោយមានលុយតិចតួចដើម្បីរស់ តើអ្នកចង់ឱ្យពួកគាត់ធ្វើអ្វីសម្រាប់អ្នក?

ក- ទិញម្ហូបអាហារញ៉ាំក្នុងគ្រួសារ    ខ- ទិញស្បែកជើងជិះស្គីលេង។

**ចម្លើយ៖ ១: គ  ២: ក  ៣: រកលុយ ឬសន្សំលុយ  ៤: ក។**

គ្រូធ្វើការសន្និដ្ឋានដល់សិស្សក្នុងថ្នាក់ថា អ្វីៗត្រូវចំណាយលុយ។ អ្នកអាចធ្វើបានតាមអ្វីដែលអ្នកអាចដើម្បីរកប្រាក់។ អ្នកគួរកំណត់អាទិភាពតម្រូវការជាមុនសិន ហើយការចង់បាននឹងមកតាមក្រោយ។ នៅពេលអ្នកចង់បានអ្វីមួយ អ្នកគួរតែគិតថា តើវានឹងផ្ដល់ផលប្រយោជន៍អ្វីខ្លះដល់អ្នក។

គ្រូប្រាប់សិស្សថា៖ នៅមេរៀនបន្ទាប់ស្ដីពី **ការសន្សំ** ហើយប្អូននឹងត្រូវបង្កើតប្រអប់សន្សំលុយ ។ សូមយកប្រអប់មួយ (ប្រអប់ស្បែកជើង) ឬស្ស៊ី ឬ កំប៉ុងដែលមានរាងជាការ៉េ ឬចតុកោណកែង និងសម្ភារៈផ្សេងទៀត។

## សន្លឹកកិច្ចការ ៤.១៖ ការប៉ាន់ស្មានតម្លៃទំនិញ

**ការណែនាំ៖** សូមមើលរូបភាពប្រភេទទំនិញខាងក្រោម និងព្យាយាមប៉ាន់ស្មានតម្លៃទំនិញ ដោយផ្អែកលើបទពិសោធផ្ទាល់របស់ប្អូន បន្ទាប់មកប្រៀបធៀបតម្លៃ ជាមួយសមាជិកផ្សេងទៀតនៅក្នុងក្រុម។

# ចូរទាយតម្លៃ



## សន្លឹកកិច្ចការ ៤.២៖ ការចង់បាន ឬតម្រូវការ
















# មេរៀនទី ៥ ការកំណត់គោលដៅហិរញ្ញវត្ថុ

| | |
|---|---|
|  | រយៈពេល៖ ៨០នាទី (២ វគ្គ) |
|  | **ការត្រៀមមុនបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ថតចម្លងសន្លឹកកិច្ចការ៥.១ ៥.២ និង ៥.៣<br>- ត្រៀមសម្ភារៈសម្រាប់ធ្វើប្រអប់សន្សំ<br>- ក្រដាសផ្ទាំងធំ។ |
|  | **សម្ភារៈ ធនធានដែលចាំបាច់**<br>- រូបភាពប្រភេទផ្សេងគ្នានៃការសន្សំ<br>- សន្លឹកកិច្ចការ៥.១៖ ប្រភេទផ្សេងគ្នានៃការសន្សំ (កាត Flash Card)<br>- សន្លឹកកិច្ចការ៥.២៖ កំណត់ត្រាទម្លាប់សន្សំ<br>- សម្ភារៈសម្រាប់បង្កើតប្រអប់សន្សំ៖ ប្រអប់ស្បែកជើងចាស់ ឬស៊ី កំប៉ុង កាសែតចាស់ៗ ក្រដាសខ្ចប់ចាស់ៗ កាវ កន្ត្រៃ សម្ភារៈផាត់ពណ៌ ថ្នាំលាប<br>- សន្លឹកកិច្ចការ៥.៣៖ ផែនការសន្សំរបស់ខ្ញុំ។ |
|  | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- ស្គាល់ប្រភេទផ្សេងៗក្នុងការសន្សំ<br>- បង្កើតប្រអប់សន្សំផ្ទាល់ខ្លួន<br>- បង្កើតផែនការសន្សំសម្រាប់រយៈពេលខ្លី ឬវែង។ |

## ផ្នែកទី១៖ តម្លៃនៃការសន្សំ- ៤០នាទី

### សេចក្តីផ្តើម៖

គ្រូអាចចាប់ផ្តើមមេរៀនជាក់ស្តែងដូចខាងក្រោម៖ ថ្ងៃនេះ យើងនឹងរៀនមេរៀនថ្មីមួយ៖ ការកំណត់គោលដៅហិរញ្ញវត្ថុ។ គ្រូសួរសិស្សថា៖តើយើងត្រូវធ្វើដូចម្តេចខ្លះ ដើម្បីឱ្យថ្នាក់រៀនដំណើរការបានល្អ? គ្រូសង្ឃឹមថា យើងនឹងអនុវត្តច្បាប់ម្រាមដៃទាំងប្រាំរួមគ្នា។

### សកម្មភាពសំខាន់ទី១៖ ប្រភេទនៃការសន្សំ (២០នាទី)

គ្រូសរសេរពាក្យ ការសន្សំនៅលើក្តារខៀន ហើយគូសរង្វង់ជុំវិញពាក្យនោះ បន្ទាប់មកសួរសំណួរក្រុមធំ៖ តើប្អូនដឹងអ្វីខ្លះអំពីការសន្សំ? សូមផ្តល់ឧទាហរណ៍មួយចំនួនទាក់ទងនឹងការសន្សំ។

គ្រូសរសេរចម្លើយរបស់សិស្សលើក្ដារខៀន ក្នុងផែនទីគំនិតដូចក្នុងឧទាហរណ៍នៅខាងស្ដាំ។

គ្រូបង្ហាញរូបភាពបីសន្លឹកទាក់ទងនឹងទម្លាប់នៃការសន្សំ។ បន្ទាប់មកសួរសិស្សថា៖ តើរូបនេះបង្ហាញពីអ្វី? គ្រូបិទរូបភាពទាំងនោះឱ្យត្រូវតាមប្រភេទនៃការសន្សំក្នុងតារាងខាងក្រោម៖




| តារាងទី ១៖ ប្រភេទផ្សេងៗនៃការសន្សំ | | |
|---|---|---|
| **អំពើល្អ** | **ធនធាន** | **លុយ** |
|  |  |  |
| ឧ. ផ្ដល់អាហារដល់មនុស្សចាស់ | ឧ. កាត់បន្ថយប្រើប្លាស្ទិច | ឧ. ចិញ្ចឹមមាន់ |

គ្រូបន្តសួរសិស្សថា៖តើការសន្សំមានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចម្លើយ៖ ការសន្សំមានបីប្រភេទគឺការសន្សំអំពើល្អ ការសន្សំធនធាន និងសន្សំលុយ។ គ្រូអាចសុំឱ្យសិស្សលើកឧទាហរណ៍១ឬ២ ដែលបង្ហាញពីការសន្សំខុសៗគ្នា។

បន្ទាប់ពីសកម្មភាពនេះ គ្រូហៅសិស្សស្ម័គ្រចិត្តដើម្បីឱ្យនិយមន័យនៃពាក្យ «សន្សំ»។ បន្ទាប់មកគ្រូបង្ហាញនិយមន័យនៅលើក្ដារខៀន ហើយពន្យល់៖



**និយមន័យ៖** ការសន្សំ មានន័យថាការមិនចំណាយប្រាក់របស់អ្នកភ្លាមៗនោះទេ ប៉ុន្តែរក្សាទុកវាឱ្យបានគ្រប់គ្រាន់ ដើម្បីចំណាយនៅពេលក្រោយ។ អ្នកអាចសន្សំក្នុងប្រអប់សន្សំ ឬទុកដាក់ជាមួយឪពុកម្ដាយ ។ ការដាក់ប្រាក់សន្សំនៅក្នុងធនាគារគឺជាជម្រើសដ៏ល្អបំផុត និងមានសុវត្ថិភាព។ (ត្រូវបន្ថែមអត្ថន័យសន្សំអំពើល្អ និងសន្សំធនធាន)។

គ្រូបែងចែកសិស្សជាក្រុមដែលមានគ្នាពី៤-៦នាក់។ ចែកកាតចំនួន៣ឬ៤ (យកចេញពីសន្លឹកកិច្ចការ៥.១) ដែលបង្ហាញពីប្រភេទផ្សេងគ្នានៃការសន្សំ។ សិស្សគួរពិភាក្សាគ្នាអំពីវិធីចាត់ថ្នាក់កាតទៅក្នុងប្រភេទត្រឹមត្រូវក្នុងតារាងខាងលើ។ ចំណាំ៖ សិស្សអាចដាក់កាតមួយ ក្នុងប្រភេទច្រើនជាងមួយបាន។

គ្រូក៏អាចស្វែងរករូបភាព ឬរូបថតផ្សេងទៀតដែលឆ្លុះបញ្ចាំងពីទម្លាប់នៃការសន្សំដើម្បីប្រើប្រាស់សម្រាប់កាត បន្ថែមពីលើរូបភាពដែលបានផ្តល់ជូនក្នុងសន្លឹកកិច្ចការ។



និមិត្តសញ្ញាព្រួញបីតំណាងឱ្យដំណើរការកែច្នៃវត្ថុមួយឡើងវិញ។ ឧទាហរណ៍៖ ដបប្លាស្ទិកដែលឈប់ប្រើអាចកែច្នៃទៅជាផលិតផលថ្មីដូចជា ប្រដាប់ប្រដាក្មេងលេងធ្វើពីប្លាស្ទិក ឧបករណ៍អេឡិចត្រូនិក និងវត្ថុប្លាស្ទិកផ្សេងៗទៀតនៅក្នុងផ្ទះរបស់អ្នក ។

ពាក្យថា «**ធនធាន**» សម្រាប់ថ្នាក់អក្ខរកម្មហិរញ្ញវត្ថុ សំដៅលើវត្ថុនានា (ឧ. រុក្ខជាតិ ទឹក ដី អគ្គិសនី ក្រដាស ឬប្លាស្ទីកដូចបានរៀបរាប់ក្នុងសន្លឹកកិច្ចការ៥.១)។ ប្រាក់នឹងត្រូវបានចាត់ទុកថាជាប្រភេទមួយផ្សេងទៀតសម្រាប់ប្រភេទផ្សេងគ្នានៃការសន្សំ។

សន្លឹក/រូបភាព ផ្ទាំងក្រដាសធំ (Flash Card) ចំនួន ១៨ សន្លឹក នៅក្នុងសន្លឹកកិច្ចការ ៥.១ ពណ៌នាអំពីការសន្សំចំនួនបីប្រភេទផ្សេងៗគ្នា (១- ការសន្សំអំពើល្អ ២- ការសន្សំធនធាន ៣- ការសន្សំប្រាក់)។ គ្រូអាចប្រាប់សិស្សអំពីឈ្មោះរូបភាពប្រសិនបើចាំបាច់។ ខាងក្រោមនេះគឺជាឈ្មោះនៃរូបភាពពីសន្លឹកកិច្ចការ ៥.១។

| | |
|---|---|
| រូបភាពទី១៖ ការបោះចោលសំរាម | រូបភាពទី២៖ ការដើរជាមួយមនុស្សវ័យចាស់ |
| រូបភាពទី៣៖ អំពូលភ្លើង | រូបភាពទី៤៖ ការបើក / បិទអគ្គិសនី |
| រូបភាពទី៥៖ ការញ៉ាំអាហារ | រូបភាពទី៦៖ ប្រាក់ |
| រូបភាពទី៧៖ ការជួយនរណាម្នាក់ដែលកំពុងមានគ្រោះថ្នាក់ | រូបភាពទី៨៖ ការប្រើប្រាស់ទឹក |
| រូបភាពទី៩៖ សំរាមនៅលើថ្នល់ | រូបភាពទី១០៖ និមិត្តសញ្ញាកែច្នៃឡើងវិញ |
| រូបភាពទី១១៖ ការប្រើប្រាស់កង្ហារ | រូបភាពទី១២៖ ការទិញទំនិញតាមអនឡាញ |
| រូបភាពទី១៣៖ ការចែករំលែកអាហារ | រូបភាពទី១៤៖ ការជួយធ្វើការងារផ្ទះ |
| រូបភាពទី១៥៖ ការទុកលុយក្នុងប្រអប់សន្សំ | រូបភាពទី១៦៖ ដបទឹកដែលឈប់ប្រើ |
| រូបភាពទី១៧៖ ការដាំបន្លែ | រូបភាពទី១៨៖ ការបើកទឹកតិចៗ |

១- ការសន្សំ និងធ្វើអំពើល្អ មិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់អ្នកដទៃប៉ុណ្ណោះទេ វាថែមទាំងធ្វើឱ្យខ្លួនអ្នកពេញចិត្ត ពង្រឹងទំនាក់ទំនង និងបង្កើនសុខុមាលភាព។ វាក៏ធ្វើឱ្យពិភពលោកល្អប្រសើរផងដែរ។ ទង្វើតិចតួចនៃសេចក្តីសប្បុរសនិងក្តីមេត្តាកាន់តែជួយបង្កើតបានជាសង្គមវិជ្ជមាន និងមានមេត្តាធម៌។ តាមរយៈការផ្សព្វផ្សាយសេចក្តីល្អ និងធ្វើឱ្យមានការផ្លាស់ប្តូរនៅក្នុងជីវិតរបស់អ្នកដទៃ យើងអាចធ្វើការរួមគ្នាឆ្ពោះទៅកាន់ពិភពលោកមួយដែលមានភាពសុខដុមរមនា និងយកចិត្តទុកដាក់គ្នាច្រើនជាងមុន។

២- ការសន្សំធនធានមានអត្ថប្រយោជន៍ជាច្រើន រាប់ចាប់ពីអត្ថប្រយោជន៍ចំពោះបរិស្ថាន រហូតដល់ការសន្សំថ្លៃចំណាយ និងការបង្កើនប្រសិទ្ធភាព។ វាគឺជាវិធីសាស្ត្រប្រកបដោយទំនួលខុសត្រូវ និងការគិតឆ្ពោះទៅមុខ ដែលលើកកម្ពស់ឱ្យមានអនាគតប្រកបដោយនិរន្តរភាព និងវិបុលភាព។ ការសន្សំធនធានផ្តល់នូវអត្ថប្រយោជន៍៖

- **និរន្តរភាពបរិស្ថាន៖** ការសន្សំធនធានជួយថែរក្សា និងការពារបរិស្ថាន។ តាមរយៈការកាត់បន្ថយការប្រើប្រាស់ និងចោលកាកសំណល់ យើងអាចអភិរក្សធនធានធម្មជាតិដូចជាទឹក ថាមពល និងវត្ថុធាតុដើម។ នេះរួមចំណែកដល់និរន្តរភាពនៃភពផែនដីរបស់យើង និងជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងបញ្ហាបរិស្ថានផ្សេងទៀត។
- **ការសន្សំការចំណាយផ្សេងៗ៖** ការសន្សំធនធានអាចនាំឱ្យមានការសន្សំថ្លៃចំណាយយ៉ាងសំខាន់។ ឧទាហរណ៍ តាមរយៈការសន្សំថាមពល អ្នកអាចកាត់បន្ថយថ្លៃចំណាយលើវិក្កយបត្រថ្លៃភ្លើងរបស់អ្នក។ ដូចគ្នានេះដែរ ការកាត់បន្ថយការប្រើប្រាស់ទឹកអាចជួយឱ្យវិក្កយបត្រថ្លៃទឹកធ្លាក់ចុះ។ បន្ថែមលើនេះ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសម្ភារៈឡើងវិញអាចសន្សំប្រាក់ មិនចាំបាច់ទិញរបស់របរថ្មីៗ។
- **ការថែរក្សាសម្រស់ធម្មជាតិ៖** ការសន្សំធនធានជួយថែរក្សាសម្រស់ធម្មជាតិជុំវិញខ្លួនយើង។ តាមរយៈការកាត់បន្ថយការបំពុល កាត់បន្ថយកាកសំណល់ និងការការពារប្រព័ន្ធអេកូឡូស៊ី ដែលអាចរក្សាបានសោភណភាពនៃបរិស្ថានរបស់យើង និងធានាថា មនុស្សជំនាន់ក្រោយអាចរីករាយនឹងធម្មជាតិនេះផងដែរ។
- **ទំនួលខុសត្រូវសង្គម៖** ការសន្សំធនធានគឺជាសកម្មភាពទំនួលខុសត្រូវសង្គម។ វាបង្ហាញពីការប្តេជ្ញាចិត្តចំពោះនិរន្តរភាព និងសុខុមាលភាពរបស់មនុស្សជំនាន់បច្ចុប្បន្ននិងអនាគត។ តាមរយៈការអភិរក្សធនធាន វាពិតជាការរួមចំណែកធ្វើឱ្យមានគុណភាពជីវិតកាន់តែប្រសើរឡើងសម្រាប់ខ្លួនយើង និងអ្នកដទៃ។

៣- ការសន្សំប្រាក់ផ្តល់នូវសុវត្ថិភាពហិរញ្ញវត្ថុ សមត្ថភាពក្នុងការសម្រេចបាននូវគោលដៅ ភាពបត់បែន សន្តិភាពផ្លូវចិត្ត ឯករាជ្យភាព ឱកាសវិនិយោគ និងការត្រៀមខ្លួនសម្រាប់អនាគត។ វាគឺជាទម្លាប់ហិរញ្ញវត្ថុដ៏ឈ្លាសវៃ ដែលអាចធ្វើឱ្យសុខុមាលភាពហិរញ្ញវត្ថុទាំងមូលរបស់អ្នកប្រសើរឡើង និងផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់អនាគតដ៏រុងរឿង។

បន្ទាប់ពីធ្វើចំណាត់ថ្នាក់ប្រភេទផ្សេងៗនៃការសន្សំក្នុងតារាងទី១រួចរាល់។ គ្រូបង្ហាញតារាងទី២៖ អំពីទម្លាប់សន្សំនៅលើក្តារខៀន។ គ្រូបង្ហាញឧទាហរណ៍គំរូក្នុងតារាងទី២ និងសួរគំនិតសិស្ស៖ តើរូបភាពនេះបង្ហាញពីទម្លាប់សន្សំល្អ ឬអាក្រក់? ហេតុអ្វី?

គ្រូឱ្យក្រុមនីមួយៗមកយកកាតរបស់ខ្លួនដែលបានបិទក្នុងតារាងទី១ និងបន្ទាប់មកណែនាំសិស្សឱ្យមើលកាតរបស់ពួកគេ ហើយសម្រេចចិត្តថា តើវាជាទម្លាប់សន្សំល្អ ឬមិនល្អ ព្រមទាំងផ្តល់ការពន្យល់សមហេតុផល។

## តារាងទី២៖ ទម្លាប់សន្សំ

| សកម្មភាព | ទម្លាប់ល្អ | ទម្លាប់អាក្រក់ | ពន្យល់ពីមូលហេតុ |
|---|---|---|---|
|  | ✓ | | ការជួយជនដែលមានពិការភាពគឺជាសញ្ញានៃអំពើល្អ និងការចូលរួម។ |
|  | | ✓ | ការបោះចោលសំរាមនៅទីសាធារណៈ ចូលរួមបំពុលបរិស្ថាន និងទីក្រុមមិនស្អាត។ |

### សកម្មភាពសំខាន់ទី២៖ កំណត់ត្រាទម្លាប់សន្សំ (១០នាទី)

គ្រូចាប់ផ្ដើមសកម្មភាពនេះ ដោយសួរសិស្ស៖ តើប្អូនអាចកែលម្អទម្លាប់សន្សំផ្ទាល់ខ្លួនរបស់ប្អូនពីមួយថ្ងៃទៅមួយថ្ងៃដោយរបៀបណា?

គ្រូចែកសន្លឹកកិច្ចការ៥.២៖ កំណត់ត្រាទម្លាប់សន្សំឱ្យសិស្សម្នាក់អាន និងសួរសំណួរប្រសិនបើមានចម្ងល់។ បន្ទាប់មកសិស្សបំពេញតារាងនេះ។

គ្រូរំឭកឡើងវិញនូវឧទាហរណ៍មួយចំនួននៃទម្លាប់សន្សំដែលមាននៅក្នុងសន្លឹកកិច្ចការ៥.២ ដើម្បីឱ្យសិស្សយល់ថាវាជាអ្វី។ សិស្សក៏អាចបន្ថែមទម្លាប់មួយចំនួនទៀតនៅក្នុងចន្លោះទទេដែលមាននៅខាងក្រោមតារាង។ ត្រូវប្រាកដថា គ្រូបានលើកទឹកចិត្តសិស្សឱ្យកត់ត្រាទម្លាប់សន្សំរបស់ពួកគេ ក្នុងរយៈពេលពេញមួយសប្ដាហ៍ ហើយស្វែងរកពេលវេលាដើម្បីពិនិត្យមើលពីរបៀបដែលពួកគេបានធ្វើនៅចុងសប្ដាហ៍បន្ទាប់។

**សកម្មភាពផ្ទះបញ្ចាំង៖** តើប្អូនបានរៀនសូត្រអ្វីខ្លះពីសកម្មភាពនេះ? តើប្អូននឹងយកចំណេះដឹងដែលបានរៀនទៅអនុវត្តនៅផ្ទះដូចម្ដេចខ្លះ?

# រូបភាពប្រភេទផ្សេងៗនៃការសន្សំ









## សន្លឹកកិច្ចការ ៥.១៖ ប្រភេទផ្សេងៗនៃការសន្សំ

**កំណត់ចំណាំសម្រាប់គ្រូ៖** ឯកសារនេះមិនមែនសម្រាប់ចែកឱ្យសិស្សទេ ប៉ុន្តែជាប្រភពនៃរូបភាពទាក់ទងនឹងការសន្សំប្រាក់ ដែលត្រូវកាត់ចេញពីគ្នា ហើយចែកឱ្យសិស្ស។ គ្រូថតចម្លងរូបភាពជាច្រើនសន្លឹកក្នុងសន្លឹកកិច្ចការនេះ ដើម្បីចែកឱ្យក្រុមនីមួយៗ។



## សន្លឹកកិច្ចការ ៥.២៖

# បញ្ជីទម្លាប់សន្សំរបស់ខ្ញុំ

នៅចុងបញ្ចប់នៃថ្ងៃនីមួយៗ សូមពិនិត្យមើលបញ្ជី ថាតើប្អូនបានធ្វើអ្វីខ្លះ។

ផ្តល់ឱ្យខ្លួនឯង (សិស្សអាចគូរផ្កាយដោយប្រើប៊ិចរបស់ពួកគេ)

★ ផ្កាយពណ៌បៃតងមួយ ប្រសិនបើប្អូនចាំថាបានធ្វើវាគ្រប់ពេល

★ ផ្កាយពណ៌ខៀវ ប្រសិនបើប្អូនធ្វើវាពេលខ្លះ

★ ផ្កាយពណ៌ក្រហម ប្រសិនបើប្អូនភ្លេចធ្វើវា។

ប្រសិនបើប្អូនមិនមានប៊ិចពណ៌គ្រប់ចំនួន។ ប្អូនអាចគូសនិមិត្តសញ្ញាផ្សេងៗតំណាងឱ្យពណ៌ ។ ធ្វើបែបនេះសម្រាប់ពេញមួយសប្តាហ៍។ ចាំថាត្រូវស្មោះត្រង់!



ចាប់ពី______________ រហូតដល់ ___________________

ខែ __________________________________

| ខ្ញុំចាំថា ខ្ញុំបាន... | ថ្ងៃទី១ | ថ្ងៃទី២ | ថ្ងៃទី៣ | ថ្ងៃទី៤ | ថ្ងៃទី៥ | ថ្ងៃទី៦ | ថ្ងៃទី៧ |
|---|---|---|---|---|---|---|---|
| ញ៉ាំអាហារក្នុងចានរបស់ខ្ញុំឱ្យអស់ | | | | | | | |
| បោះចោលសំរាមក្នុងធុង | | | | | | | |
| ប្រើពាក្យគួរសម | | | | | | | |
| គោរពច្បាប់ចរាចរណ៍ | | | | | | | |
| ប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈដោយប្រុងប្រយ័ត្ន | | | | | | | |
| ចែករំលែកជាមួយអ្នកដទៃ | | | | | | | |
| រៀបចំកាតាបខ្លួនឯង និងទៅសាលាដោយមានរបៀបស្អាត | | | | | | | |
| បិទភ្លើង និងកង្ហារបន្ទាប់ពីប្រើរួច | | | | | | | |
| ប្រមូល និងកែច្នៃរបស់របរប្រើប្រាស់ឡើងវិញ | | | | | | | |
| បិទទឹកបន្ទាប់ពីប្រើរួច | | | | | | | |
| ប្រមូលរបស់ដែលលែងប្រើដើម្បីយកលក់យកប្រាក់ដាក់ក្នុងប្រអប់សន្សំ | | | | | | | |
| ដាក់ប្រាក់ក្នុងប្រអប់សន្សំរបស់ខ្ញុំ | | | | | | | |
| រក្សាកំណត់ត្រានៅក្នុងសៀវភៅសន្សំរបស់ខ្ញុំ។ | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

## វគ្គទី២៖ សកម្មភាពសន្សំរបស់ខ្ញុំ (៤០នាទី)

### សកម្មភាពសំខាន់ទី៣៖ បង្កើតប្រអប់សន្សំ (២០នាទី)

គ្រូអាចចាប់ផ្តើមសកម្មភាពនេះដោយសួរសំណួរខាងក្រោម៖

**តើប្អូនដឹងស្គាល់កន្លែងណាដែលប្អូនអាចសន្សំប្រាក់បានដែរឬទេ?**
**តើប្អូនមានកន្លែងសម្រាប់រក្សាទុកដាក់របស់ពិសេសរបស់ប្អូនដែរឬទេ?**

បន្ទាប់ពីសួរសំណួរទាំងនេះ គ្រូផ្តើមគំនិតថា «ខ្ញុំមានគំនិតល្អមួយ! តស់ យើងធ្វើប្រអប់ដាក់វត្ថុអនុស្សាវរីយ៍មួយ! យើងហៅវាថា ប្រអប់សន្សំ។ ប្អូនអាចដាក់អ្វីដែលចូលចិត្ត។ ប្អូនអាចដាក់របស់តូចៗដែលអាចរកបាន ឬរបស់ដែលគេឱ្យជាអំណោយ។ ប្អូនថែមទាំងអាចដាក់ប្រាក់បានទៀតផង។»

តស់ ចាប់ផ្តើម។ ទាំងនេះជាសម្ភារៈដែលយើងត្រូវការដើម្បីធ្វើប្រអប់សន្សំ។ ត្រូវប្រាកដថា ប្អូនមានអ្វីៗគ្រប់យ៉ាងរួចរាល់មុនពេលចាប់ផ្តើម។ សម្ភារៈមួយចំនួនដែលអាចប្រើសម្រាប់លំហាត់នេះត្រូវបានណែនាំដូចខាងក្រោម៖



*ប្រអប់ស្បែកជើង/កំប៉ុង/ឬស្សី*




*កាសែតចាស់ៗ / ក្រដាសខ្ចប់ចាស់ៗ*




*សម្ភារៈលាបពណ៌ / ថ្នាំលាប*



*កាវ*



*កន្ត្រៃ*

ប្អូនត្រូវធ្វើតាមបីជំហាន ដើម្បីបង្កើតជាប្រអប់សន្សំ។ ពន្យល់ជំហានទាំងនេះដល់សិស្ស យោងទៅតាមការពន្យល់ដែលបានផ្តល់ជូនខាងក្រោម។




**ជំហានទី១៖** វាស់ និងកាត់ក្រដាសកាសែត ឬក្រដាសរុំខ្ចប់ដើម្បីឱ្យត្រូវនឹងប្រអប់ស្បែកជើង។



**ជំហានទី២៖** រុំប្រអប់ជាមួយក្រដាសកាសែត ឬក្រដាសរុំខ្ចប់។ ប្រើកាវដើម្បីបិទក្រដាសជុំវិញប្រអប់។



**ជំហានទី៣៖** ធ្វើឱ្យប្រអប់មានពណ៌ចម្រុះដោយគូរឬលាបពណ៌ម៉ូតផ្សេងៗ។ ត្រូវច្នៃប្រឌិត!

គ្រូពន្យល់ថា ប្អូនគួរតែទុកប្រអប់សន្សំរបស់ប្អូននៅកន្លែងដែលមានសុវត្ថិភាពនៅផ្ទះ។ នៅខាងក្នុងប្រអប់ប្អូនអាចដាក់របស់របរណាមួយដែលប្អូនគិតថា មានតម្លៃសម្រាប់រក្សាទុកឱ្យមានសុវត្ថិភាព។

## សកម្មភាពសំខាន់ទី៤៖ ផែនការសន្សំរបស់អ្នក (២០នាទី)

គ្រូចែកសន្លឹកកិច្ចការ៥.៣៖ ផែនការសន្សំរបស់ខ្ញុំ ដល់សិស្សគ្រប់គ្នា។ គ្រូបង្ហាញសំណួរខាងក្រោមនេះនៅលើក្ដារខៀន បន្ទាប់មកឱ្យសិស្សគិតជាបុគ្គល រយៈពេល៣នាទី រួចឱ្យសិស្សធ្វើការជាដៃគូ ដើម្បីចែករំលែកគំនិតទៅកាន់ដៃគូរយៈពេល៥នាទី ហើយចុងក្រោយ គ្រូហៅសិស្សដែលស្ម័គ្រចិត្តចែករំលែកគំនិតទៅកាន់សិស្សទាំងអស់រយៈពេល៥នាទី។

- នៅលើតារាងផែនការសន្សំនេះតើគេប្រាប់ពីអ្វីខ្លះ?
- តើអ្វីជាគោលដៅរយៈពេលខ្លីឬរយៈពេលវែង?
- តើអ្នកយល់ពីវិធីគណនានៃឧទាហរណ៍គំរូក្នុងតារាងផែនការសន្សំនេះដែរឬទេ? ចូរពន្យល់។
- ប្រសិនបើអ្នកសន្សំ៥០០រៀលក្នុងមួយថ្ងៃ តើអ្នកអាចទិញរបស់អ្វីមួយដែលអ្នកត្រូវការ ឬចង់បានដែរឬទេ? តើវាជាអ្វី? ហើយតើអ្នកត្រូវសន្សំរយៈពេលប៉ុន្មាន?

គ្រូបង្ហាញនិយមន័យគោលដៅរយៈពេលខ្លី និងរយៈពេលវែងនៅលើក្ដារខៀន។

### និយមន័យ៖

**គោលដៅរយៈពេលខ្លី៖** គឺជាការចង់ទិញទំនិញអ្វីមួយដែលត្រូវចំណាយពេលប្រហែល៦ខែ ដើម្បីសន្សំប្រាក់បានគ្រប់គ្រាន់។

**គោលដៅរយៈពេលវែង៖** គឺជាការចង់ទិញទំនិញអ្វីមួយដែលត្រូវការក្នុងរយៈពេលច្រើនជាង៦ខែ ឬច្រើនឆ្នាំ ដើម្បីសន្សំប្រាក់បានគ្រប់។

គ្រូឱ្យសិស្សម្នាក់ៗអនុវត្តការបំពេញផែនការសន្សំ ជាមួយនឹងឧទាហរណ៍មួយផ្សេងទៀតគឺ កាតាបថ្មី ដើម្បីឱ្យសិស្សយល់កាន់តែច្បាស់ពីការបំពេញផែនការសន្សំរយៈពេល៥នាទី ។

### ឆ្លុះបញ្ចាំង - ៥នាទី

ដើម្បីបញ្ចប់មេរៀន គ្រូសួរថា តើប្អូនបានរៀនអ្វីខ្លះនៅថ្ងៃនេះ? តើប្អូនចូលចិត្តអ្វីខ្លះសម្រាប់មេរៀនថ្ងៃនេះ? តើប្អូនទទួលបានចំណេះដឹងអ្វីខ្លះពីមេរៀននេះ?

# ____________________ផែនការសន្សំ

## តើខ្ញុំរកប្រាក់បានប៉ុន្មានក្នុងមួយខែ?

____________________

## តម្រូវការ និងការចង់បានរបស់ខ្ញុំ

1.ស្បែកជើងកីឡា

2. កាតាបថ្មី

____________________

____________________



## គោលដៅរបស់ខ្ញុំ

រយៈពេលខ្លី (តិចជាង ៦ ខែ)

រយៈពេលវែង (ច្រើនជាង ៦ ខែ)

| ខ្ញុំចង់ទិញ | ក្នុងពេលចំនួន ... ខែ | វាមានតម្លៃ | តើខ្ញុំសន្សំប៉ុន្មានក្នុងមួយថ្ងៃ/សប្តាហ៍? | តើខ្ញុំសន្សំបានប៉ុន្មានក្នុងមួយខែ? |
|---|---|---|---|---|
| ស្បែកជើងកីឡា | ៣ | ៤២០០០ រៀល | ៥០០ រៀលក្នុងមួយថ្ងៃ ៣៥០០ រៀលក្នុងមួយសប្តាហ៍ | ១៤០០០ រៀលក្នុងមួយខែ ៤២០០០ រៀល ក្នុង ៣ ខែ |
| | | | | |
| | | | | |
| | | | | |

# មេរៀនទី ៦ ការត្រៀមខ្លួនសន្សំ

| | |
|---|---|
|  | រយៈពេល៖ ៤០នាទី |
|  | **ការត្រៀមមុនបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ត្រៀមសម្រាប់លេងល្បែងសិក្សា Game of the Goose (ក្ដារល្បែងសិក្សា ១ គ្រាប់ឡុកឡាក់១គ្រាប់ក្នុងមួយក្រុម និងកូនដើរ១ដើម សម្រាប់អ្នកលេងម្នាក់<br>- ថតចម្លងសន្លឹកកិច្ចការ ៦.១។ |
|  | **សម្ភារៈ ធនធានដែលចាំបាច់**<br>- សន្លឹកកិច្ចការ ៦.១ ៖ ល្បែងសិក្សាសន្សំលុយ<br>- ល្បែងសិក្សា Game of the Goose និងគ្រាប់ឡុកឡាក់ (១គ្រាប់ ក្នុងមួយក្រុម)<br>- ក្រដាស A4 កាវ ខ្មៅដៃ ឬប៊ិក សម្ភារៈលាបពណ៌ បន្ទាត់<br>- ផ្ទាំងរូបភាពទី២។ |
|  | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- បង្កើតសៀវភៅកត់ត្រាការសន្សំប្រចាំសប្ដាហ៍/ខែ<br>- សាកល្បងប្រភេទផ្សេងៗនៃការសន្សំតាមរយៈការលេងល្បែងសិក្សា។ |

### សេចក្ដីផ្ដើម៖ (៥នាទី)

គ្រូចាប់ផ្ដើមវគ្គ៖ សូមស្វាគមន៍ត្រឡប់មកកាន់ថ្នាក់អក្ខរកម្មហិរញ្ញវត្ថុ! តើប្អូនមានអារម្មណ៍យ៉ាងណានៅថ្ងៃនេះ? ប្រសិនបើប្អូនមានអារម្មណ៍ល្អ ឬមានថាមពលខ្លាំង សូមលើកមេដៃទាំងពីរឡើង។ ប្រសិនបើមានអារម្មណ៍ធម្មតា សូមបង្ហាញមេដៃទាំងពីរត្រង់ធម្មតា។ ហើយប្រសិនបើមានអារម្មណ៍មិនសប្បាយចិត្ត ឬអស់កម្លាំង សូមទម្លាក់មេដៃទាំងពីរចុះ។ មុនពេលយើងចាប់ផ្ដើមមេរៀន តើអ្នកណាចង់ចែករំលែកអ្វីដែលយើងបានរៀនកាលពីម្សិលមិញ?

យើងបានមកដល់ពាក់កណ្ដាលផ្លូវនៃដំណើររបស់យើងលើមេរៀនអក្ខរកម្មហិរញ្ញវត្ថុ។ ថ្ងៃនេះយើងចាប់ផ្ដើមមេរៀនថ្មី៖ ការត្រៀមខ្លួនសន្សំ។

### សកម្មភាពសំខាន់ទី១៖ បង្កើតសៀវភៅសន្សំ (២០នាទី)

គ្រូគួរចាប់ផ្ដើមមេរៀនដោយសួរសំណួរខាងក្រោម៖

**ចាប់តាំងពីប្អូនបង្កើតប្រអប់សន្សំមក តើប្អូនបានដាក់លុយខ្លះចូល ឬដកចេញដែរឬទេ? តើប្អូនដឹងទេថាប្អូនមានលុយប៉ុន្មានក្នុងប្រអប់សន្សំរបស់ខ្លួន?**

**តើប្អូនធ្លាប់ស្គាល់ពីកំណត់ត្រាសន្សំដែរឬទេ? តើប្អូនដឹងទេថាវាជាអ្វី? ហើយយើងអាចប្រើវាដើម្បីអ្វី?**

គ្រូពន្យល់ពីសារៈសំខាន់ ពីការដក និងដាក់លុយទៅសិស្ស៖ តើប្អូនដឹងទេថា នៅពេលដក/ដាក់លុយចូលប្រអប់សន្សំមានអត្ថប្រយោជន៍ដូចម្ដេច? ប្អូនត្រូវមានកំណត់ត្រាអំពីសៀវភៅនេះ។ កំណត់ត្រានេះត្រូវបានហៅថា សៀវភៅសន្សំ។ ក្នុងនោះ ប្អូននឹងសរសេរថាតើប្អូនដាក់លុយប៉ុន្មាន ដកចេញប៉ុន្មាន ហើយនៅសល់ប៉ុន្មាន។

ត្រូវប្រាកដថា សិស្សគ្រប់គ្នាត្រូវតែមានសៀវភៅសន្សំមួយក្បាល ដែលបង្កើតឡើងដោយស្នាដៃរបស់ខ្លួនផ្ទាល់។ វាជារឿងល្អដែលប្អូនអាចបង្កើតវាចេញពីការស្រលាញ់ និងការខិតខំប្រឹងប្រែង។

បន្ទាប់មក គ្រូគួរសួរសិស្សថា៖ តើប្អូនបានរៀនសូត្រអ្វីខ្លះពីសកម្មភាពនេះ? តើប្អូនសុខចិត្តកត់ត្រាប្រាក់របស់ប្អូននៅក្នុងសៀវភៅសន្សំ បន្ទាប់ពីបានដាក់ប្រាក់ក្នុងប្រអប់សន្សំដែរឬទេ? ហេតុអ្វី?

បន្ទាប់ពីការពិភាក្សាខ្លីៗលើសំណួរនេះ សូមពិនិត្យជំហានខាងក្រោមជាមួយសិស្សអំពីរបៀបបង្កើតសៀវភៅសន្សំ។

**ជំហានទី១៖** យកក្រដាស A4 បីសន្លឹក ហើយបត់វាជាពីរ។



**ជំហានទី២៖** បិទកាវ ឬបិទភ្ជាប់តាមផ្នត់។



ហើយបិទសន្លឹកជាមួយគ្នា។ ឥឡូវនេះ ប្អូនមានសៀវភៅមួយក្បាលចំនួនប្រាំមួយទំព័រ។

**ជំហានទី៣៖** គូរគម្របដ៏ស្រស់ស្អាត ដោយសរសេរឈ្មោះរបស់ប្អូន កំណត់ត្រាសន្សំ និងឆ្នាំសិក្សានៅខាងក្រោម។



នៅខាងក្នុងផ្នែកទំព័រនីមួយៗ គូរតារាងមួយ មានបួនជួរ រួចសរសេរ៖ "កាលបរិច្ឆេទ" "ប្រាក់ដាក់ចូល" (វាមានន័យថាតើប្អូនដាក់ប្រាក់ប៉ុន្មាន) "ប្រាក់ដកចេញ" (វាមានន័យថាតើប្អូនយកប្រាក់ប៉ុន្មានចេញ) និង "សមតុល្យ" (វាមានន័យថាចំនួនប្រាក់ដែលនៅសល់) តាមជួរនីមួយៗរៀងគ្នា។

| កាលបរិច្ឆេទ | ប្រាក់ដាក់ចូល | ប្រាក់ដកចេញ | សមតុល្យ |
|---|---|---|---|
| | | | |
| | | | |

### សកម្មភាពសំខាន់ទី២៖ ល្បែងក្ងានប្រដេញគ្នា (Game of the goose) (១៥នាទី)

បន្ទាប់មក គ្រូគួរប្រកាសប្រាប់សិស្សថា តស់ យើងលេងល្បែងសិក្សាសប្បាយទាំងអស់គ្នា! យើងនឹងលេងល្បែងសិក្សាដែលរំឭកអំពីប្រភេទផ្សេងៗនៃការសន្សំ។ សម្រាប់សកម្មភាពនេះ គ្រូគួរតែចែកសន្លឹកកិច្ចការ ៦.១៖ ល្បែងក្ងានប្រដេញគ្នា ។

គ្រូបែងចែកសិស្ស មួយក្រុមមានសមាជិកប្រាំនាក់។ បន្ទាប់មក គ្រូពន្យល់ពីការណែនាំដូចខាងក្រោម៖

- ដាក់ក្ដារល្បែងសិក្សានៅកណ្ដាលតុសិស្ស។
- ដាក់កូនដើររបស់អ្នកនៅលើប្រអប់ចាប់ផ្ដើម។
- មានលេខចាប់ពីលេខ១ ដល់លេខ៣០ នៅលើក្ដារល្បែងសិក្សា។
- អ្នកលេងម្នាក់ៗប្ដូរវេនគ្នាក្រឡុកគ្រាប់ឡុកឡាក់។
- អ្នកលេងត្រូវផ្លាស់ទីកូនទៅតាមលេខគ្រាប់ឡុកឡាក់។ ប្រសិនបើកូនស្ថិតនៅលើប្រអប់ដែលមានការណែនាំ អ្នកត្រូវតែអាន ហើយធ្វើតាមការណែនាំ។
- អ្នកលេងណាដែលឈានដល់ប្រអប់បញ្ចប់ មុនគេ គឺជាអ្នកឈ្នះ។

**ចំណាំ៖** ប្រសិនបើអ្នកផ្លាស់ទីកូនទៅតាមជណ្ដើរ (ជណ្ដើរមានន័យថាអ្នកបានជោគជ័យក្នុងផែនការសន្សំរបស់អ្នក ឬអ្នកបើកគណនីធនាគារ) នោះអ្នកអាចឡើងទៅផ្នែកដែលអ្នកជិតទទួលបានជោគជ័យបំផុត។

អ្នកបានឃើញថា មានមួកពណ៌ខ្មៅនៅលើក្ដារល្បែងសិក្សា។ មួកពណ៌ខ្មៅមានន័យថាអ្នកមិនបានបង់វិក្កយបត្រ ឬប្រាក់កម្ចីទាន់ពេលវេលា។ ប្រសិនបើអ្នកផ្លាស់ទីកូនជាមួយមួកខ្មៅ នោះអ្នកនឹងចុះថយក្រោយទៅកាន់ចំណុចប្រអប់ដែលបានបង្ហាញ។

បន្ទាប់មក គ្រូសួរសិស្ស៖ តើប្អូនយល់ពីរបៀបលេងដែរឬទេ? តើអ្នកណាមិនទាន់យល់ច្បាស់អំពីការណែនាំ? សូមលើកដៃ ហើយគ្រូនឹងពន្យល់ការណែនាំម្ដងទៀត។

គ្រូឱ្យសិស្សចាប់ផ្ដើមលេង ដោយនិយាយថា តស់ ចាប់ផ្ដើមលេងសប្បាយជាមួយក្រុមរបស់ប្អូន!

### ការឆ្លុះបញ្ចាំង (៥នាទី)

ដើម្បីបញ្ចប់មេរៀននេះ គ្រូគួរសួរសំណួរខាងក្រោម ដើម្បីដឹកនាំសកម្មភាពឆ្លុះបញ្ចាំង៖

- តើមានល្បះនិយាយអំពីការសន្សំអំពើល្អដែរឬទេ? បើមាន តើជាល្បះអ្វី?
- តើមានល្បះនិយាយអំពីការសន្សំធនធានដែរឬទេ? បើមាន តើជាល្បះអ្វី?
- តើមានល្បះនិយាយអំពីការសន្សំលុយដែរឬទេ? បើមាន តើជាល្បះអ្វី?
- តើការសន្សំមានប៉ុន្មានប្រភេទ?
- តើប្អូនអាចអនុវត្តគំនិតសន្សំទាំងនេះឱ្យបានទៀងទាត់ដែរឬទេ? បើបានហេតុអ្វី? បើមិនបានហេតុអ្វី?

## សន្លឹកកិច្ចការ ៦.១៖ ល្បែងសិក្សាក្ងានប្រដេញគ្នា (Game of the Goose)



# មេរៀនទី ៧ ការរកប្រាក់

| | |
|---|---|
|  | រយៈពេល៖ ៤០នាទី |
|  | ការត្រៀមមុនបង្រៀន<br>- អានមេរៀនទាំងមូល<br>- ត្រៀមសម្ភារៈសម្រាប់ល្បែងសិក្សា<br>- ថតចម្លងសន្លឹកកិច្ចការ៖ ៧.១ ការងារដែលអ្នកអាចធ្វើបាន និង៧.២ ល្បែងសិក្សារបស់អ្នក។ |
|  | សម្ភារៈ ធនធានដែលចាំបាច់<br>- សម្ភារៈល្បែងសិក្សា<br>- សន្លឹកកិច្ចការ ៧.១៖ ការងារដែលអ្នកអាចធ្វើបាន<br>- សន្លឹកកិច្ចការ ៧.២៖ ល្បែងសិក្សារបស់អ្នក<br>- ក្រដាស A4 ខ្មៅដៃ។ |
|  | លទ្ធផលសិក្សា៖<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- បង្ហាញពីវិធីផ្សេងៗក្នុងការរកលុយ<br>- រាប់ឈ្មោះការងារដែលពួកគេចូលចិត្ត និងមិនចូលចិត្ត។ |

## សេចក្តីផ្តើម៖ (៥នាទី)

គ្រូចាប់ផ្តើមមេរៀនដោយនិយាយថា សូមស្វាគមន៍ត្រឡប់មកកាន់ថ្នាក់អក្ខរកម្មហិរញ្ញវត្ថុ! ថ្ងៃនេះយើងនឹងលេងល្បែងសិក្សារកប្រាក់តាមប្រភេទការងារផ្សេងៗ។ វាគ្រាន់តែជាល្បែងសម្រាប់សកម្មភាពក្នុងថ្នាក់ប៉ុណ្ណោះ។ ប្អូនមិនគួរលេងល្បែងនេះក្នុងជីវិតពិតរបស់ប្អូន និងនៅសាលារៀននោះទេ។ ប៉ុន្តែ ប្រសិនបើការងារមិនប៉ះពាល់ដល់ការសិក្សា ឬសុខភាព ឬសុខុមាលភាពរបស់ប្អូន ប្អូនអាចធ្វើការដើម្បីរកប្រាក់តាមគោលដៅរបស់ប្អូន។

មុនយើងចាប់ផ្តើមមេរៀន តើអ្នកណាចង់ចែករំលែកពីអ្វីដែលយើងបានរៀនកន្លងមក?

## សកម្មភាពសំខាន់ទី១៖ ល្បែងរកលុយ (២៥នាទី)

គ្រូនិយាយទៅកាន់សិស្សទាំងអស់៖ ប្អូនៗសាកស្រមៃថាប្អូនចង់ទិញហ្គីតាមួយ តម្លៃ១២០ ០០០រៀល។ បន្ទាប់មក ប្អូនៗត្រូវធ្វើការងារដើម្បីរកប្រាក់ទិញវា។ នៅក្នុងហ្គេមនេះ មានការងារជាច្រើន ហើយប្អូនអាចសម្រេចចិត្តរកប្រាក់ដោយផ្អែកលើការចូលចិត្តរបស់ប្អូន។ វិន័យក្នុងការលេងហ្គេមគឺ អនុញ្ញាតឱ្យប្អូនៗធ្វើការតែ៤ថ្ងៃប៉ុណ្ណោះ ហើយការងារមួយធ្វើបានតែមួយថ្ងៃ។ **ចំណាំ៖** វាគ្រាន់តែជាហ្គេមលេងក្នុងថ្នាក់ប៉ុណ្ណោះ។ វាមិនពាក់ព័ន្ធនឹងការកេងកម្លាំងពលកម្មកុមារនោះទេ។

គ្រូណែនាំពីរបៀបលេងល្បែងរកប្រាក់។

១- បែងចែកសិស្សជាក្រុមដែលមានសមាជិក៤នាក់។ ជ្រើសរើសអ្នកដឹកនាំម្នាក់ក្នុងក្រុមនីមួយៗ។

២- ចែកសន្លឹកកិច្ចការ៖ ៧.១ ការងារដែលអ្នកអាចធ្វើបាន និង ៧.២ ល្បែងសិក្សាដល់ក្រុមនីមួយៗ

៣- ហៅសិស្សស្ម័គ្រចិត្តអានសន្លឹកកិច្ចការ ៧.២ ឱ្យឮៗ និងបញ្ជាក់ថា ក្រុមនីមួយៗយល់ពីរបៀបលេង។ ក្រុមនីមួយៗត្រូវបំពេញសន្លឹកកិច្ចការនោះទៅតាមការណែនាំក្នុងក្រដាសនោះ។ **បញ្ជាក់៖** លើកលែងកូឡោនពិន្ទុសុខុមាលភាពមិនតម្រូវឱ្យក្រុមនីមួយៗបំពេញទេ។

៤- គ្រូ ឬអ្នកដឹកនាំក្រុមអានស្វែងយល់ពី ៧.៣ សន្លឹកព័ត៌មានបន្ថែមអំពីការងារដែលបញ្ជាក់ពី៖ ឈ្មោះការងារ ចំនួនប្រាក់ចំណូល ការចូលចិត្ត និងមិនចូលចិត្ត និងពិន្ទុសុខុមាលភាព។ បញ្ជាក់៖ គ្រូ ឬអ្នកដឹកនាំក្រុមត្រូវមានសន្លឹកកិច្ចការ៧.២ ដើម្បីបំពេញរាល់ព័ត៌មានដែលសមាជិកក្រុមនីមួយៗបានបំពេញ។

៥- គ្រូ ឬអ្នកដឹកនាំក្រុម សង្កេតមើលសមាជិកក្រុមជ្រើសរើសការងារ និងមិនត្រូវផ្តល់យោបល់ដល់ក្រុមទេ។ បន្ទាប់មក ដាក់ពិន្ទុសុខុមាលភាពទៅតាមការចូលចិត្ត និងមិនចូលចិត្តចំពោះការងារដែលសមាជិកបានជ្រើសរើស។ គ្រូ ឬអ្នកដឹកនាំក្រុម ធ្វើបែបនេះក្នុងការដាក់ពិន្ទុសុខុមាលភាពចំនួន៤ដង (១ដងក្នុង១ថ្ងៃសម្រាប់ការងារ១)។

នៅពេលល្បែងសិក្សារួចរាល់ គ្រូសរសើរសិស្ស ហើយគ្រូឬអ្នកដឹកនាំក្រុមបង្ហាញចំនួនប្រាក់សរុបដែលក្រុមនីមួយៗរកបាន និងពិន្ទុសុខុមាលភាព។

បន្ទាប់មកទៀត គ្រូសួរសិស្សថា តើប្អូនដឹងទេថាពាក្យ «សុខុមាលភាព» មានន័យដូចម្តេច?

**គ្រូពន្យល់ពីនិយមន័យនៃសុខុមាលភាព៖** សុខុមាលភាពត្រូវបានផ្សារភ្ជាប់យ៉ាងខ្លាំងទៅនឹងសុភមង្គល និងការពេញចិត្តក្នុងជីវិតរស់នៅ រួមទាំង ផ្លូវកាយ ផ្លូវចិត្ត និងអារម្មណ៍។ មានការងារជាច្រើនដែលមនុស្សអាចធ្វើវាបាន ប៉ុន្តែប្រសិនបើការងារនោះប៉ះពាល់ដល់សុខភាពផ្លូវកាយ ផ្លូវចិត្ត និងអារម្មណ៍ និងសង្គម គឺចាត់ទុកថាវាជាការងារដែលគ្មានសុខុមាលភាព។ នៅក្នុងមាត្រដ្ឋានពិន្ទុសុខុមាលភាពចាប់ពី -១ ដល់ -៦ គឺបង្ហាញការងារដែលអ្នកធ្វើគ្មានសុខុមាលភាព ចំណែកឯពិន្ទុចាប់ពី១ដល់៦ គឺបង្ហាញការងារដែលអ្នកធ្វើមានសុខុមាលភាព។

គ្រូសួរថា តើប្អូនយល់យ៉ាងណាចំពោះល្បែងសិក្សានេះ? តើប្អូនចូលចិត្តវាឬទេ? ហេតុអ្វី?

## សកម្មភាពសំខាន់ទី២៖ ហ៊ានសុបិនអំពីការងាររបស់អ្នក (១០នាទី)

គ្រូសរសេរបញ្ជីការងារខាងក្រោម (អ្នកមានការងារបន្ថែមទៀតនៅទីនេះ) នៅលើក្តារខៀន៖ វេជ្ជបណ្ឌិត គ្រូបង្រៀន មេធាវី ជាងជួសជុលម៉ូតូ អ្នកលក់ កម្មករសំណង់ កសិករ នគរបាល បុគ្គលិកធនាគារ អ្នកចម្រៀង អ្នកបង្កើតវីដេអូ...។

ក្នុងបញ្ជី សិស្សម្នាក់ៗជ្រើសរើសការងារមួយដែលចូលចិត្ត និងមិនចូលចិត្តធ្វើនៅពេលអនាគត ហើយពន្យល់ពីមូលហេតុនៅក្នុងតារាងខាងក្រោម។

| **ឈ្មោះការងារ** | **ចូលចិត្ត ឬមិនចូលចិត្ត** | **មូលហេតុ** |
|---|---|---|
| ឧទាហរណ៍៖ គ្រូបង្រៀន | ចូលចិត្ត | ខ្ញុំចូលចិត្តជួយអ្នកដទៃឱ្យរៀនអ្វីថ្មីៗ និងពង្រីកការយល់ដឹងរបស់ពួកគេ។ |
| | | |
| | | |

បន្ទាប់មកគ្រូសួរថា តើការងារដែលប្អូនជ្រើសរើសធ្វើឱ្យសុខុមាលភាពរបស់ប្អូនប្រសើរឡើងដែរឬទេ? (សុខុមាលភាពត្រូវបានផ្សាភ្ជាប់យ៉ាងខ្លាំងទៅនឹងសុភមង្គល និងការពេញចិត្តក្នុងជីវិត) តើប្អូនអាចផ្តល់មូលហេតុមួយបានទេ?

### ការឆ្លុះបញ្ចាំង (៥នាទី)

គ្រូឱ្យសិស្សគិត៖ តើប្អូនបានរៀនសូត្រអ្វីខ្លះនៅថ្ងៃនេះ? តើប្អូនចូលចិត្តអ្វីខ្លះសម្រាប់មេរៀនថ្ងៃនេះ? តើប្អូនទទួលបានចំណេះដឹងអ្វីខ្លះពីមេរៀននេះសម្រាប់យកត្រឡប់ទៅផ្ទះវិញ?

## សន្លឹកកិច្ចការ ៧.១

# ការងារដែលអ្នកអាចធ្វើបាន



## ការងារនៅសាលា



| ការងារ | លក្ខណៈរបស់ការងារ | លុយរកបាន |
|---|---|---|
| | • ធ្វើការនៅខាងក្រៅ<br>• ធ្វើការតែម្នាក់ឯង<br>• កិច្ចការដដែលៗ | ៤០ ០០០ រៀល |
| ដាំដំណាំក្នុងសួនច្បារ | • ចង់បានអ្នកចេះថែសួន<br>• ធ្វើការនៅខាងក្រៅ<br>• ធ្វើការជាមួយអ្នកដទៃ | ៣០ ០០០ រៀល |
| លក់នំនៅក្នុងសាលា | • ធ្វើការនៅខាងក្នុង<br>• ធ្វើការតែម្នាក់ឯង<br>• ប្រុងប្រយ័ត្នជាមួយអំពូលភ្លើង | ២០ ០០០ រៀល |





## នៅកសិដ្ឋាន



| ការងារ | លក្ខណៈរបស់ការងារ | លុយរកបាន |
|---|---|---|
| ប្រមូលពងមាន់ | • កាន់ពងមាន់ដោយប្រយ័ត្ន<br>• ទ្រុងមាន់អាចមានក្លិនមិនល្អ<br>• ធ្វើការដដែលៗ | ៤៥ ០០០ រៀល |
| បេះផ្លែចេក | • ធ្វើការនៅខាងក្រៅ<br>• ជាការលំហាត់ប្រាណល្អ<br>• ធ្វើការដដែលៗ | ៣០ ០០០ រៀល |
| ដាំស្រូវក្នុងវាលស្រែ | • ធ្វើការនៅខាងក្រៅ<br>• ធ្វើការថែសួន<br>• ធ្វើការជាមួយអ្នកដទៃ | ១៥ ០០០ រៀល |



## សន្លឹកកិច្ចការ ៧.២

# សន្លឹកហ្គេមរបស់អ្នក។




សាកស្រមៃថាអ្នកចូលចិត្តតន្ត្រី ហើយអ្នកចង់លេងហ្គីតានៅក្នុងក្រុមរបស់អ្នក។ សាលារបស់អ្នកនឹងរៀបចំកម្មវិធីបវេសនកាលឆាប់ៗនេះ ហើយអ្នកចង់សម្តែងនៅលើឆាក ប៉ុន្តែឥឡូវនេះអ្នកមិនមានហ្គីតាទេ។ អ្នកត្រូវរកលុយដើម្បីទិញវា។ ហ្គីតាថ្មីមួយតម្លៃ ១២ ម៉ឺនរៀល។

ការងារដែលអ្នកនឹងត្រូវធ្វើគឺទាក់ទងនឹងចំណូលចិត្ត និងសុខុមាលភាពរបស់អ្នក។

**សូមចងចាំ៖ អ្នកមានពេល ៤ ថ្ងៃដើម្បីរកលុយ ហើយអ្នកអាចធ្វើការងារបាន ១ ក្នុងមួយថ្ងៃ។ ពិន្ទុសុខុមាលភាពរបស់អ្នកចាប់ផ្តើមពី ០។**

| ឧទាហរណ៍ | **ថ្ងៃទី ១** | **ថ្ងៃទី ២** | **ថ្ងៃទី ៣** | **ថ្ងៃទី ៤** |
|---|---|---|---|---|
| ការងារ៖ ប្រមូលពងមាន់<br><br>លុយរកបាន៖ ៤៥ ០០០ រៀល | ការងារ ___________<br>លុយរកបាន ___________<br>ពិន្ទុសុខុមាលភាព ___________ | ការងារ ___________<br>លុយរកបាន ___________<br>ពិន្ទុសុខុមាលភាព ___________ | ការងារ ___________<br>លុយរកបាន ___________<br>ពិន្ទុសុខុមាលភាព ___________ | ការងារ ___________<br>លុយរកបាន ___________<br>ពិន្ទុសុខុមាលភាព ___________ |

| **ចូលចិត្ត / ពូកែធ្វើ** | **មិនចូលចិត្ត / មិនពូកែធ្វើ** |
|---|---|
| ថ្ងៃទី១៖ ___________________________<br>ថ្ងៃទី២៖ ___________________________<br>ថ្ងៃទី៣៖ ___________________________<br>ថ្ងៃទី៤៖ ___________________________ | ថ្ងៃទី១៖ ___________________________<br>ថ្ងៃទី២៖ ___________________________<br>ថ្ងៃទី៣៖ ___________________________<br>ថ្ងៃទី៤៖ ___________________________ |

**មាត្រដ្ឋានសុខុមាលភាព**




| **តារាងពិន្ទុចុងក្រោយ** | |
|---|---|
| **លុយរកបាន** | |
| **ពិន្ទុសុខុមាលភាព** | |

សន្លឹកកិច្ចការ៧.៣

# ព័ត៌មានបន្ថែម

## (សម្រាប់អ្នកដឹកនាំក្រុម និងគ្រូបង្រៀន)

| | ការងារ | **លុយរកបាន** | **ចូលចិត្ត និង មិនចូលចិត្ត** | **ពិន្ទុសុខុមាលភាព** |
|---|---|---|---|---|
| ការងារនៅសាលា | លាបថ្នាំពណ៌របង | ៤០ ០០០ រៀល | ចូលចិត្ត៖ ធ្វើឱ្យបរិស្ថានសាលារៀនល្អប្រសើរ<br><br>មិនចូលចិត្ត៖ ធ្វើកិច្ចការដដែលៗ | + ២ ពិន្ទុ (ចូលចិត្ត)<br>- ១ ពិន្ទុ (មិនចូលចិត្ត) |
| | ដាំដំណាំក្នុងសួនច្បារ | ៣០០០០ រៀល | ចូលចិត្ត៖ ធ្វើកិច្ចការជាមួយអ្នកដទៃ ធ្វើកិច្ចការនៅក្រៅ | + ២ ពិន្ទុ (ចូលចិត្ត)<br>- ១ ពិន្ទុ (មិនចូលចិត្ត) |
| | លក់នំនៅក្នុងសាលា | ២០០០០ រៀល | ចូលចិត្ត៖ ធ្វើកិច្ចការជាមួយអ្នកដទៃ<br><br>មិនចូលចិត្ត៖ គួរឱ្យធុញ | + ១ ពិន្ទុ (ចូលចិត្ត)<br>- ១ ពិន្ទុ (មិនចូលចិត្ត) |
| នៅកសិដ្ឋាន | ប្រមូលពងមាន់ | ៤៥០០០ រៀល | ចូលចិត្ត៖ ធ្វើការនៅជិតផ្ទះ<br><br>មិនចូលចិត្ត៖ ក្លិនមិនល្អ ធ្វើកិច្ចការដដែលៗ | + ១ ពិន្ទុ (ចូលចិត្ត)<br>- ២ ពិន្ទុ (មិនចូលចិត្ត) |
| | បេះផ្លែចេក | ៣០០០០ រៀល | ចូលចិត្ត៖ ហាត់ប្រាណ<br><br>មិនចូលចិត្ត៖ ធ្វើការនៅខាងក្រៅ ពេលអាកាសធាតុក្តៅ | + ១ ពិន្ទុ (ចូលចិត្ត)<br>- ១ ពិន្ទុ (មិនចូលចិត្ត) |
| | ដាំស្រូវក្នុងវាលស្រែ | ១៥០០០ រៀល | ចូលចិត្ត៖ ការដាំដំណាំ ធ្វើកិច្ចការជាមួយអ្នកដទៃ<br><br>មិនចូលចិត្ត៖ ធ្វើការនៅខាងក្រៅ ពេលអាកាសធាតុក្តៅ ធ្វើកិច្ចការដដែលៗ | + ២ ពិន្ទុ (ចូលចិត្ត)<br>- ១ ពិន្ទុ (មិនចូលចិត្ត) |

# មេរៀនទី ៨ ជម្រើសរបស់ខ្ញុំក្នុងការចំណាយ

| | |
|---|---|
| | រយៈពេល៖ ៨០នាទី (២វគ្គ) |
| | **ការត្រៀមមុនបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ថតចម្លងសន្លឹកកិច្ចការ ៨.១ និង ៨.២។ |
| | **សម្ភារៈ ធនធានដែលចាំបាច់**<br>- សន្លឹកកិច្ចការណែនាំ ៨.១៖ ការសម្តែងតួ (role play)<br>- សន្លឹកកិច្ចការ ៨.២៖ ទម្រង់សង្កេតការសម្តែងតួ<br>- ផ្ទាំងក្រដាសធំ។ |
| | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- ពន្យល់ពីគុណសម្បត្តិ និងគុណវិបត្តិនៃការចំណាយ។<br>- ធ្វើសេចក្តីសម្រេចចិត្តលើការចំណាយឱ្យបានត្រឹមត្រូវ និងឆ្លាតវៃដោយប្រើករណីសិក្សាដែលមានបង្ហាញក្នុងថ្នាក់។ |

## វគ្គទី១ (៤០នាទី)

### សេចក្តីផ្តើម (៥នាទី)

គ្រូចាប់ផ្តើមមេរៀននិងសួរ៖ សូមស្វាគមន៍ត្រឡប់មកកាន់ថ្នាក់អក្ខរកម្មហិរញ្ញវត្ថុ! តើប្អូនមានអារម្មណ៍យ៉ាងណានៅថ្ងៃនេះ? ប្រសិនបើប្អូនមានអារម្មណ៍ល្អ ឬមានថាមពលខ្លាំង សូមលើកមេដៃទាំងពីរឡើង។ ប្រសិនបើមានអារម្មណ៍ធម្មតា សូមបង្ហាញមេដៃទាំងពីរត្រង់ធម្មតា។ ហើយប្រសិនបើមានអារម្មណ៍មិនសប្បាយចិត្ត ឬអស់កម្លាំង សូមទម្លាក់មេដៃទាំងពីរចុះ។

គ្រូរំលឹកមេរៀនចាស់ដោយសួរសំណួរក្រុមធំនិងប្រាប់ចម្លើយផងដែរ។ បន្ទាប់មកសិស្សនឹងលើកដៃចំពោះចំលើយណាមួយដែលគាត់គិតថាត្រឹមត្រូវ ។ គ្រូសម្របសម្រួលចម្លើយសិស្ស។ ខាងក្រោមនេះជាចម្លើយត្រឹមត្រូវ៖ ១-ខ; ២-ខ; ៣-គ ;៤-ង។

១- ប្រសិនបើប្អូនចង់ទិញផ្ទះមួយ តើប្អូនត្រូវការការសន្សំប្រភេទណា?
ក- រយៈពេលខ្លី
ខ- រយៈពេលវែង។

២- ប្រសិនបើប្អូនទិញទូរសព្ទ Iphone ចេញថ្មីបំផុតមួយគ្រឿង តើវាជាតម្រូវការ ឬការចង់បាន?
ក- តម្រូវការ
ខ- ការចង់បាន។

៣- តើពាក្យ «សុខុមាលភាព» មានន័យដូចម្ដេច?

ក- គឺការញ៉ាំអ្វីៗដែលខ្ញុំចូលចិត្តជានិច្ច

ខ- គឺជាការមិនដែលហាត់ប្រាណ ដោយសារតែខ្ញុំមិនចូលចិត្តវា

គ- គឺការសប្បាយចិត្ត និងការពេញចិត្តក្នុងជីវិតរបស់ខ្ញុំ។

៤- តើអ្វីខ្លះជាផ្នែកនៃអក្ខរកម្មហិរញ្ញវត្ថុ?

ក- ការសន្សំ

ខ- ការរកប្រាក់ចំណូល

គ- ការចំណាយ

ឃ- ការបរិច្ចាគ

ង- ចម្លើយទាំងអស់ខាងលើ។

**ចម្លើយត្រឹមត្រូវ៖ ១- ខ; ២- ខ; ៣- គ; ៤- ង។**

## សកម្មភាពសំខាន់ទី១៖ និយមន័យការចំណាយ (៥នាទី)

បន្ទាប់ពីលំហាត់ខាងលើ គ្រូនិយាយថា យើងចាប់ផ្ដើមមេរៀនថ្មី «ជម្រើសរបស់ខ្ញុំក្នុងការចំណាយ»។ តើប្អូនដឹងអ្វីខ្លះអំពីការចំណាយ? តើមានរបស់អ្វីខ្លះដែលប្អូនអាចចំណាយលុយទិញ?

គ្រូសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀនក្នុងផែនទីគំនិតដូចក្នុងឧទាហរណ៍។ តាមរយៈការពិភាក្សាណែនាំ គ្រូគួរតែព្យាយាមធ្វើឱ្យសិស្សយល់ពីនិយមន័យនៃ «**ការចំណាយ**» ដូចខាងក្រោម។ គ្រូសរសេរនិយមន័យនេះនៅលើក្ដារខៀនសម្រាប់សិស្សចម្លងទៅក្នុងសៀវភៅសរសេររបស់ពួកគេ។




**និយមន័យ៖** ការចំណាយ មានន័យថាការប្រើប្រាស់លុយដើម្បីទិញទំនិញ ឬសេវាកម្ម។

## សកម្មភាពទី២៖ ការត្រៀមរៀបចំការសម្ដែងតួ ទាក់ទងនឹងការសម្រេចចិត្តចំណាយ (២០នាទី)

គ្រូចាប់ផ្ដើមសកម្មភាពនេះដោយការចែកសន្លឹកកិច្ចការណែនាំ៨.១៖ ការដើរសម្ដែងតួអំពីការចំណាយ។ ឯកសារនេះពណ៌នាអំពីសាច់រឿងនៃការសម្រេចចិត្តចំណាយចំនួន៤។ គ្រូបែងចែកសិស្សជាបួនក្រុម ហើយកំណត់សាច់រឿងមួយដល់ក្រុមនីមួយៗ។ គ្រូណែនាំសិស្សក្នុងក្រុមនីមួយៗឱ្យអានសាច់រឿងរបស់ពួកគេដោយប្រុងប្រយ័ត្ន ហើយពិភាក្សានៅក្នុងក្រុមរៀងៗខ្លួន។ សំណួរនៅក្នុងសាច់រឿងនីមួយៗនឹងជួយសិស្សឱ្យឆ្លុះបញ្ចាំងពីបញ្ហាដែលបានរំលេច ហើយគិតអំពីផលប៉ះពាល់នៃការសម្រេចចិត្តចំណាយរបស់បុគ្គលម្នាក់ៗ។ នៅពេលដែលក្រុមនីមួយៗបានសម្រេចចិត្តពីរបៀបឆ្លើយសំណួរដែលបានចង្អុលបង្ហាញនោះ ក្រុមគួរតែបង្កើតការសម្ដែងតួរយៈពេល ៣ ទៅ ៥ នាទី ដែលតំណាងឱ្យស្ថានភាពនោះ។ ការសម្ដែងតួនឹងត្រូវធ្វើនៅម៉ោងបន្ទាប់។

ដើម្បីរៀបចំការសម្តែងតួ ប្អូនត្រូវកំណត់តួនាទីក្នុងក្រុមដើម្បីដើរតួជាតួអង្គណាខ្លះ។ ជ្រើសរើសអ្នកដឹកនាំម្នាក់ក្នុងក្រុម ដើម្បីជួយសម្រួលដល់ការសម្តែង។ អានសាច់រឿង តើមានតួអង្គប៉ុន្មាននាក់ត្រូវសម្តែង? ពិនិត្យមើលសាច់រឿង (script) ដែលជារបស់តួអង្គនីមួយៗឱ្យបានច្បាស់លាស់។ ដើម្បីបង្កើនទំនុកចិត្តរបស់ប្អូនប្អូនអាចសាកល្បងអនុវត្តសម្តែងតួ ប្រសិនបើបានរៀបចំរួចរាល់ហើយ។

ខណៈពេលដែលសិស្សកំពុងត្រៀមរៀបចំសម្តែងតួ គ្រូដើរជុំវិញតាមក្រុមនីមួយៗ ដើម្បីគាំទ្រពួកគេ និងឆ្លើយរាល់សំណួរដែលសិស្សមាន។

## សន្លឹកកិច្ចការណែនាំ ៨.១ - ការសម្តែងតួអំពីការចំណាយ

### សាច់រឿងទី១

រាល់ពេលដែលប្អូនធ្វើកិច្ចការផ្ទះដោយមិនបាច់ម្តាយប្រើ ម្តាយប្អូនឱ្យលុយខ្លះគិតជារៀល។ ប្អូនសន្សំប្រាក់រៀលទាំងអស់នៅក្នុងប្រអប់សន្សំរបស់ប្អូន។ ថ្ងៃមួយ ប្អូនដើរកាត់ហាងលក់របស់ក្មេងលេង បានឃើញរបស់លេងមួយដែលប្អូនចង់បានជាខ្លាំង។ ប្អូនប្រញាប់ទៅផ្ទះ ហើយយកប្រាក់ចេញពីប្រអប់សន្សំ និងរាប់វា។ នៅខ្វះប្រាក់ខ្លះ។ ប្អូនគណនាថា បើធ្វើកិច្ចការពីរបីដងទៀត ប្អូននឹងមានប្រាក់គ្រប់គ្រាន់សម្រាប់ទិញរបស់លេងនោះ។ ប្អូនប្រឹងប្រែងធ្វើការក្នុងរយៈពេលពីរបីសប្តាហ៍បន្ទាប់ ដោយធ្វើដំណើរទៅហាងជារៀងរាល់ថ្ងៃ ដើម្បីមើលថា តើរបស់ក្មេងលេងនោះនៅសល់ដែរឬទេ។

បន្ទាប់មកថ្ងៃមួយ ប្អូនដឹងថាមិត្តល្អរបស់ប្អូនបានជួបគ្រោះថ្នាក់ ហើយកំពុងសម្រាកនៅមន្ទីរពេទ្យ។ ពេលទៅលេងមិត្តភក្តិ ប្អូនដឹងថានាងបាក់ជើង។ គ្រួសារនាងមិនអាចមានលទ្ធភាពទិញឈើច្រត់ជើងឱ្យនាងបានទេ។ ពួកគាត់បានស្វែងរកនរណាម្នាក់ ដើម្បីជួយពួកគាត់ ប៉ុន្តែគ្មាននរណាម្នាក់ក្នុងគ្រួសារបានសន្សំប្រាក់នោះទេ។ ប្អូនសួរថា តើឈើច្រត់ជើងមានតម្លៃប៉ុន្មាន? វាមានតម្លៃស្មើនឹងប្រាក់ដែលប្អូនមាននៅក្នុងប្រអប់សន្សំរបស់ប្អូន។

តើប្អូនធ្វើបែបណា? តើប្អូនទិញរបស់លេង ឬជួយមិត្តរបស់ប្អូន? ប្អូនពិតជាចង់បានរបស់លេង ប៉ុន្តែប្រសិនបើមិត្តរបស់ប្អូនមានឈើច្រត់ជើង នាងអាចទៅសាលារៀន ហើយនឹងមិនខកខានធ្វើកិច្ចការ និងការប្រឡងឡើយ។

សម្រេចចិត្តថាប្អូននឹងធ្វើអ្វី ហើយរៀបចំការដើរតួសម្តែងទាក់ទងនឹងការសម្រេចចិត្តរបស់ប្អូន។ ហេតុអ្វីបានជាប្អូនធ្វើការសម្រេចចិត្តបែបនេះ? តើជម្រើសរបស់ប្អូននឹងមានលទ្ធផលបែបណា? តើប្អូនសប្បាយចិត្តនឹងជម្រើសរបស់ប្អូនដែរឬទេ?

### សាច់រឿងទី២

នៅទីបំផុត ប្អូនអាចស្តាប់ឮសំឡេងកាក់ជាច្រើនក្នុងប្រអប់សន្សំរបស់ប្អូន! ប្អូនសម្រេចចិត្តរាប់លុយ។ អូហូ! សន្សំបានច្រើនណាស់! ភាពអត់ធ្មត់របស់ប្អូនពិតជាបានផលហើយ។ តើប្អូននឹងចំណាយប្រាក់នេះដោយរបៀបណា? សូមគិតពីការចង់បាន និងតម្រូវការរបស់ប្អូន ហើយចាត់ចែងការចំណាយរបស់ប្អូន។

តើមានអ្វីកើតឡើង ប្រសិនបើប្អូនចំណាយលុយទៅតាមការចង់បានរបស់ប្អូន? តើប្អូននឹងទិញអ្វី? តើប្អូននឹងចំណាយប៉ុន្មាន? តើប្អូននឹងនៅសល់ប៉ុន្មាន? ចុះតម្រូវការរបស់ប្អូនវិញ?

តើនឹងមានអ្វីកើតឡើង ប្រសិនបើប្អូនចំណាយលើការចង់បានរបស់ប្អូន តើនឹងមានអ្វីកើតឡើង ប្រសិនបើប្អូនចំណាយលើតម្រូវការរបស់ប្អូន?

រៀបចំការដើរតួសម្តែងលើអ្វីដែលប្អូននឹងចំណាយប្រាក់របស់ប្អូន។ តើប្អូនបានជ្រើសរើសអ្វី ការចង់បាន ឬតម្រូវការ? តើអ្វីជាលទ្ធផលនៃការសម្រេចចិត្តរបស់ប្អូន?

### សាច់រឿងទី៣

សិស្សថ្នាក់ទី៥ ទាំងអស់បានសន្សំប្រាក់រយៈពេលជាច្រើនខែ។ សរុបមក ពួកគេសន្សំបានប្រមាណ៧០ ម៉ឺនរៀលក្នុងមួយថ្នាក់។ ឥឡូវនេះ ប្អូនត្រូវសម្រេចចិត្តថាត្រូវចំណាយប្រាក់លើអ្វី ដូច្នេះត្រូវប្រជុំក្នុងថ្នាក់រៀន។ អ្នកខ្លះចង់ចំណាយលុយទៅទស្សនកិច្ចសួនសត្វ ព្រោះគ្មានអ្នកណាធ្លាប់បានឃើញសួនសត្វថ្មី ចាប់តាំងពីបើកមក។ អ្នកខ្លះចង់ជប់លៀងញ៉ាំអាហារ និងលេងល្បែងសិក្សា។ អ្នកខ្លះចង់បរិច្ចាគប្រាក់ទៅសាលាអប់រំពិសេសក្នុងមូលដ្ឋាន សម្រាប់ទិញសៀវភៅ និងឧបករណ៍ឱ្យសិស្សនៅទីនោះ។

ក្នុងថ្នាក់ប្អូនមានសិស្ស៣០នាក់ ហើយបើទៅសួនសត្វ ត្រូវចំណាយ១ម៉ឺនរៀល ក្នុងម្នាក់។ បើធ្វើពិធីជប់លៀងនឹងត្រូវចំណាយអស់ ២៣ ០០០ រៀលក្នុងម្នាក់ ហើយការបរិច្ចាគសម្រាប់សាលាអប់រំពិសេស បើកទទួលស្វាគមន៍ចំនួនប្រាក់ប៉ុន្មានក៏បាន។

តើប្អូនគិតថាថ្នាក់ប្អូនគួរចំណាយប្រាក់លើអ្វី? សូមបង្កើតការរៀបចំថវិកា និងពិភាក្សាអំពីលទ្ធផលនៃការសម្រេចចិត្តរបស់ប្អូន។

### សាច់រឿងទី៤

សរុបមក សាលារបស់ប្អូនដែលមានប្អូនថ្នាក់ផ្សេងគ្នាបានសន្សំប្រាក់ចំនួន ២ ០០០ ០០០ រៀល។ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់សប្បាយរីករាយណាស់។ អ្នកទាំងអស់គ្នាបានប្រឹងប្រែងយ៉ាងខ្លាំង ដោយចំណាយពេលប្រាំមួយខែ ដើម្បីសន្សំប្រាក់នេះ។ ឥឡូវដល់ពេលសម្រេចចិត្តហើយតើប្អូនៗនឹងយកលុយនេះទៅធ្វើអ្វី?

សាលាត្រូវការសៀវភៅថ្មីៗជាច្រើន ថ្នាំលាបថ្មី បង្គន់អនាម័យ និងរុក្ខជាតិសម្រាប់សួនកុមារ។ លោកគ្រូ អ្នកគ្រូក៏បានលើកឡើងដែរថា កុមារមួយចំនួនក្នុងសាលាមានជីវភាពក្រីក្រ ឪពុកម្តាយមិនអាចបង់ថ្លៃសាលាបាន ហើយពួកគេប្រហែលជាត្រូវឈប់មករៀន។ ដូច្នេះ យើងអាចប្រើប្រាស់លុយនេះជាអាហារូបករណ៍។

តើប្អូននឹងចំណាយលុយលើអ្វី? សូមសម្រេចចិត្តពីជម្រើសរបស់ប្អូន ហើយរៀបចំដើរតួសម្តែងដែលបង្ហាញពីការសម្រេចចិត្តរបស់ប្អូន លទ្ធផលនៃការសម្រេចចិត្ត និងមូលហេតុ។

## វគ្គទី២ (៤០នាទី)

### សកម្មភាពសំខាន់ទី១៖ ការសម្តែងតួទាក់ទងនឹងការសម្រេចចិត្ត (២០នាទី)

ក្រុមនីមួយៗសម្តែងតួនៅមុខមិត្តរួមថ្នាក់ទាំងអស់។ ក្រុមផ្សេងទៀតនឹងសង្កេត និងផ្តល់មតិត្រឡប់លើចំណុចខាងក្រោម៖

- **ការត្រៀមខ្លួន៖** សម្ភារៈប្រើប្រាស់ តួអង្គសម្តែងទាំងអស់ ទីតាំងលម្អិត អត្ថបទរឿង។ល។
- **ការសម្តែង៖** ក្រសែភ្នែក កម្រិតសំឡេង កាយវិការ សារ។ល។
- ចំណុចសំខាន់ៗលើការសម្រេចចិត្តចំណាយ៖ ពន្យល់ពីជម្រើសនៃការចំណាយថាតើវាឆ្លុះបញ្ចាំងពីតម្រូវការ ឬការចង់បាន និងសុខុមាលភាព។

បន្ទាប់មក គ្រូចែកសន្លឹកកិច្ចការ៨.២៖ ទម្រង់សង្កេតការដើរតួសម្តែង ដល់ក្រុមទាំងអស់ ហើយអនុញ្ញាតឱ្យពួកគេបំពេញ ខណៈពេលដែលក្រុមមួយកំពុងធ្វើសកម្មភាពសម្តែង។

បន្ទាប់ពីការសម្តែងនីមួយៗ សូមសួរសិស្សផ្សេងទៀតក្នុងថ្នាក់៖ តើប្អូនយល់យ៉ាងណាអំពីស្ថានភាពដែលមិត្តភក្តិបានសម្តែង? បន្ទាប់មក សុំឱ្យសមាជិកណាម្នាក់ក្នុងក្រុមអានសាច់រឿងរបស់ក្រុមឱ្យសិស្សផ្សេងទៀតស្តាប់។ បន្ទាប់មក កំណត់ថាតើក្រុមផ្សេងទៀតយល់ពីចំណុចសំខាន់ៗនៃការសម្តែងបានកម្រិតណា។

គ្រូគួរតែសួរថា តើក្រុមផ្សេងទៀតអាចបង្កើតជម្រើសផ្សេងទៀតសម្រាប់ការចំណាយនេះបានទេ? តើការសម្តែងរបស់ក្រុមនេះមានចំណុចល្អអ្វីខ្លះ? តើមានមតិយោបល់អ្វីខ្លះដើម្បីកែលម្អដល់ក្រុមសម្តែង?

ដូចដែលយើងបានឃើញ មានផលវិបាកផ្សេងៗគ្នាចំពោះសកម្មភាពហិរញ្ញវត្ថុ ដូច្នេះយើងត្រូវគិតអំពីរឿងរ៉ាវផ្សេងៗ និងរៀបចំផែនការ។ (គ្រូត្រូវសំយោគគំនិតអំពីជម្រើសនៃការចំណាយ)

### សកម្មភាពសំខាន់ទី២៖ ផែនការចំណាយរបស់ខ្ញុំ (១៥ នាទី)

សម្រាប់សកម្មភាពបន្ទាប់ គ្រូឱ្យសិស្សស្រមៃថាប្អូនរកលុយបានពីការសន្សំផ្ទាល់ខ្លួនរបស់ប្អូន។ ប្អូនមានលុយមួយចំនួន ដើម្បីចំណាយតាមដែលប្អូនចង់បាន ឬត្រូវការ។ សូមចងចាំនូវអ្វីដែលប្អូនបានសរសេរនៅក្នុងផែនការសន្សំរបស់ប្អូនដើម្បីចំណាយ។ ប្អូនអាចអនុវត្តបំពេញលុយក្នុងសន្លឹកកិច្ចការ ៨.៣ផែនការចំណាយរបស់ខ្ញុំ។

គ្រូបង្ហាញឧទាហរណ៍គំរូនៅខាងក្រោមនេះជាមុនសិន បន្ទាប់មកសិស្សអាចអនុវត្តបំពេញផែនការំណាយរបស់ពួកគេដោយប្រើសន្លឹកកិច្ចការ ៨.៣ ផែនការចំណាយប្រចាំខែរបស់ខ្ញុំ។

## ផែនការចំណាយប្រចាំខែ មករា ២០២៣

ឈ្មោះ៖ ហ៊ឹម ម៉ារី ________________

| ពណ៌នាប្រាក់ចំណូល (រៀល) | ពណ៌នាការចំណាយ (រៀល) |
|---|---|
| ទទួលបានលុយពីឪពុកម្តាយប្រចាំថ្ងៃ ១២០ ០០០ រៀល<br>ធ្វើការងារ ឬ ការងារផ្ទះ ១០ ០០០ រៀល<br>កាដូ ០<br>ផ្សេងៗ ៥ ០០០ រៀល | អាហារសម្រន់ ឬចំណី ៦០ ០០០ រៀល<br>សម្លៀកបំពាក់ ១០ ០០០ រៀល<br>ស្បែកជើង ០<br>របស់លេង ២០ ០០០ រៀល<br>កាដូ ០<br>អ៊ិនធឺណិត ៨ ០០០ រៀល<br>មធ្យោបាយធ្វើដំណើរ ១៦ ០០០ រៀល |
| **ប្រាក់ចំណូលសរុប ១៣៥ ០០០ រៀល** | **ការចំណាយសរុប ១១៤ ០០០ រៀល** |
| **សមតុល្យ ( ប្រាក់ចំណូលសរុប - ការចំណាយសរុប ) ២១ ០០០ រៀល** | |

គ្រូសួរសំណួរក្រុមធំ៖

- ប្រសិនបើប្អូនចាយលុយច្រើនជាងរកលុយបាន តើប្អូននឹងបានអ្វី?
- ប្រសិនបើប្អូនចាយលុយតិចជាងរកលុយបាន តើប្អូននឹងបានអ្វី?
- តើកន្លងមកប្អូនធ្លាប់ធ្វើផែនការចំណាយប្រចាំខែដែរឬទេ? ចាស/បាទ ទេ។
- តើការធ្វើផែនការចំណាយទុកជាមុន ផ្តល់ប្រយោជន៍អ្វីខ្លះ?

ការចំណាយមានផែនការច្បាស់លាស់ ជួយឱ្យយើងអាចកំណត់ជម្រើសនៃការចំណាយបានដោយប្រសើរ និងអាចចាត់អាទិភាពការចំណាយមួយណាដែលចាំបាច់ និងត្រូវចំណាយជាមុនប្រកបដោយសុខុមាលភាពក្នុងជីវិតប្រចាំថ្ងៃ។ ការបណ្តុះទម្លាប់នៃការចំណាយដែលមានផែនការត្រឹមត្រូវ គឺជួយឱ្យមនុស្សគ្រប់រូបរស់នៅប្រកបដោយសេចក្តីសុខ និងគ្មានការព្រួយបារម្ភពីការចាយលុយលើស និងមិនជាប់ក្នុងអន្ទាក់បំណុល។ ប្រជាជនកម្ពុជា ជំពាក់បំណុលគេច្រើនដោយសារតែការចាយលុយច្រើនលើសលុប ចាយទៅតាមការចង់បាន ប៉ុន្តែលុយដែលរកបានគឺតិចជាង។ គំនិតអប់រំក្នុងមេរៀននេះ ចង់បង្ហាញថា ប្រសិនបើរកចំណូលបានតិចជាងចំណាយ គឺប្រឈមនឹងការគ្មានលុយ និងជាប់បំណុល។

### ការឆ្លុះបញ្ចាំង ( ៥នាទី )

គ្រូអាចបញ្ចប់មេរៀននេះជាមួយនឹងសំណួរឆ្លុះបញ្ចាំងខាងក្រោម៖ តើប្អូនបានរៀនសូត្រអ្វីខ្លះនៅថ្ងៃនេះ? តើប្អូនចង់ដឹងអ្វីខ្លះអំពីការចំណាយ?

## សន្លឹកកិច្ចការ ៨.២៖ ទម្រង់សង្កេតការសម្តែងតួ

ឈ្មោះក្រុម៖ ______________________________

| តើក្រុម/តួអង្គសម្តែងបានល្អយ៉ាងណា... ? | | បាទ/ចាស | ទេ | មតិយោបល់ |
|---|---|---|---|---|
| ការត្រៀមខ្លួន | សម្ភារៈប្រើប្រាស់ | | | |
| | តួអង្គសម្តែងទាំងអស់ | | | |
| | ទីតាំងលម្អិត | | | |
| | ខ្លឹមសារ | | | |
| | ផ្សេងៗ | | | |
| ការសម្តែង | ក្រសែភ្នែក | | | |
| | កម្រិតសំឡេង | | | |
| | កាយវិការ | | | |
| | ខ្លឹមសារ | | | |
| | ផ្សេងៗ | | | |
| ចំណុចសំខាន់ៗលើការសម្រេចចិត្តចំណាយ | ជម្រើសនៃការចំណាយលើការចង់បាន | | | |
| | ជម្រើសនៃការចំណាយលើតម្រូវការ | | | |
| | ជម្រើសនៃការចំណាយលើសុខុមាលភាព (រីករាយ និងពេញចិត្តក្នុងជីវិតរបស់ខ្ញុំ) | | | |
| | ការពន្យល់ច្បាស់លាស់អំពីជម្រើសនៃការចំណាយ | | | |
| ផ្សេងៗ | | | | |

## សន្លឹកកិច្ចការ ៨.៣ ៖ ផែនការចំណាយប្រចាំខែ..........

### ផែនការចំណាយប្រចាំខែ.............

ឈ្មោះ៖ ______________________________

| ប្រាក់ចំណូល | (រៀល) | ការចំណាយ | (រៀល) |
|---|---|---|---|
| ប្រាក់ឪពុកម្តាយឱ្យប្រចាំថ្ងៃ | ______ | អាហារសម្រន់/ ម្ហូបអាហារ | ______ |
| ការងារ / កិច្ចការ | ______ | សម្លៀកបំពាក់ | ______ |
| កាដូ | ______ | ស្បែកជើង | ______ |
| ផ្សេងៗ | ______ | របស់លេង | ______ |
| | | កាដូ | ______ |
| | | អ៊ិនធឺណិត | ______ |
| | | មធ្យោបាយធ្វើដំណើរ | ______ |
| | | ផ្សេងៗ | ______ |
| **ប្រាក់ចំណូលសរុប** | ______ | **ការចំណាយសរុប** | ______ |
| **សមតុល្យ ( ប្រាក់ចំណូលសរុប - ការចំណាយសរុប )** | | ______________________ | |

# មេរៀនទី ៩ អន្តរកម្មហិរញ្ញវត្ថុសម្រាប់ធ្វើកិច្ចការល្អៗ

| | |
|---|---|
|  | រយៈពេល៖ ១២០នាទី (៣វគ្គ) |
|  | **ការត្រៀមមុនបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ថតចម្លងសន្លឹកកិច្ចការទាំងអស់។ |
|  | **សម្ភារៈ ធនធានដែលចាំបាច់**<br>- រូបភាព៩.១៖ សកម្មភាពជួយ<br>- រូបភាព៩.២៖ តើអ្នកមានអារម្មណ៍យ៉ាងណា?<br>- សន្លឹកកិច្ចការ៩.៣៖ ពាក្យសំខាន់ៗ<br>- សន្លឹកកិច្ចការ៩.៤៖ ការជួយអ្នកដទៃ<br>- សន្លឹកកិច្ចការណែនាំ ៩.៥៖ ខ្ញុំ និងសហគមន៍របស់ខ្ញុំ<br>- សន្លឹកកិច្ចការ ៩.៦៖ មនុស្សដែលប្រហែលជាត្រូវការជំនួយពីអ្នក<br>- ក្រដាសពណ៌ ខ្មៅដៃ<br>- ក្តារឆ្នួន ដីស។ |
|  | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- ពន្យល់ពីសារៈសំខាន់នៃការជួយអ្នកដទៃ<br>- ផ្តល់ឧទាហរណ៍អំពីសកម្មភាពដើម្បីគាំទ្រដល់អ្នកដទៃនៅក្នុងសាលា និងសហគមន៍<br>- ពណ៌នាអំពីមនុស្សដែលប្រហែលជាត្រូវការជំនួយ។ |

## វគ្គទី១៖ ៤០ នាទី

### សេចក្តីផ្តើម

គ្រូអាចចាប់ផ្តើមមេរៀនដោយធ្វើការណែនាំខាងក្រោម៖ នៅក្នុងមេរៀននេះ យើងនឹងនិយាយអំពីអ្វីដែលប្អូនអាចធ្វើបានជាមួយនឹងប្រាក់សន្សំរបស់ប្អូនដើម្បីជួយអ្នកដទៃ។ វាគឺជាផ្នែកមួយដ៏សំខាន់របស់យើង ក្នុងនាមជាបុគ្គលម្នាក់ដែលជាផ្នែកមួយនៃសហគមន៍។ យើងទាំងអស់គ្នារស់នៅក្នុងភូមិដែលមានមនុស្សជាច្រើនរស់នៅ។ មនុស្សមួយចំនួនត្រូវការជំនួយច្រើនជាងអ្នកដទៃ ហើយថ្ងៃនេះយើងនឹងនិយាយអំពីរបៀបដែលយើងអាចជួយអ្នកដទៃ ហើយហេតុអ្វីចាំបាច់ត្រូវជួយ។

### សកម្មភាពសំខាន់ទី១៖ ការជួយអ្នកដទៃ (៤០នាទី)

គ្រូគួរបន្តពន្យល់ដូចតទៅ៖ ចូរស្រមៃមើលជីវិតប្រចាំថ្ងៃរបស់ប្អូននៅផ្ទះ ឬក្នុងសហគមន៍ មានវិធីជាច្រើនដើម្បីជួយគ្នាទៅវិញទៅមក។

គ្រូបង្ហាញរូបភាពម្តងមួយៗក្នុងរូបភាព៩.១៖ សកម្មភាពជួយដល់ថ្នាក់ទាំងមូល។ បន្ទាប់មក ឱ្យសិស្សពណ៌នាអំពីសកម្មភាពដែលពួកគេឃើញ។ រូបភាពខាងក្រោមនេះគឺជាចម្លើយដែលរំពឹងទុក។

សូមចងចាំច្បាប់នៃប្រាមដៃទាំងប្រាំសម្រាប់ការបំផុសគំនិត៖
- គំនិតកាន់តែច្រើន កាន់តែល្អ!
- គ្មានការរិះគន់
- គ្មានគំនិតណាជាគំនិតមិនល្អនោះទេ
- បង្កើតគំនិតច្នៃប្រឌិតថ្មី
- បញ្ចេញគំនិតទាំងអស់។

| | |
|---|---|
|  |  |
| **រូបភាពទី១**- ផ្តល់ជំនួយដល់មិត្តភក្តិ និងក្រុមគ្រួសារ ដោយផ្តល់ការលួងលោម។ | **រូបភាពទី២**- មានភាពរួសរាយរាក់ទាក់ ជាពិសេស ចំពោះជនដែលមានពិការភាព ដើម្បីឱ្យគ្រប់គ្នាមាន អារម្មណ៍ថាទទួលបានបរិយាបន្ន។ |
|  |  |
| **រូបភាពទី៣**- ជួយមនុស្សខ្វះខាតក្នុងសហគមន៍របស់ប្អូនដោយផ្តល់អាហារដល់ពួកគាត់។ | **រូបភាពទី៤**- ការជួយមនុស្សចាស់ដោយចំណាយពេលជាមួយពួកគាត់។ |

គ្រូបន្តពន្យល់ថា ទាំងនេះគ្រាន់តែជាឧទាហរណ៍ខ្លះៗនៃមធ្យោបាយជាច្រើនដែលយើងអាចជួយអ្នកដទៃបាន។ ឥឡូវនេះ សូមក្រឡេកមើលជីវិតប្រចាំថ្ងៃរបស់ប្អូនបន្តិច ក្នុងការជួយអ្នកដទៃ។

គ្រូសរសេរសំណួរខាងក្រោមនៅលើក្ដារខៀន។ សូមឱ្យសិស្សគិតជាលក្ខណៈបុគ្គល ហើយសរសេរចម្លើយនៅក្នុងសៀវភៅសរសេររបស់ពួកគេ។ បន្ទាប់មកចែករំលែករឿង និងអារម្មណ៍របស់ពួកគេទៅកាន់ក្រុមដែលមានសមាជិកបួននាក់។ គ្រូសុំឱ្យអ្នកស្ម័គ្រចិត្តពីរ ឬបីនាក់ចែករំលែកសាច់រឿង និងអារម្មណ៍ដល់សិស្សក្នុងថ្នាក់អស់។

១- សរសេរប្រយោគអំពីពេលវេលាដែលអ្នកដទៃ (អាចជាមិត្តភក្ដិ គ្រូ ឪពុកម្ដាយ អ្នកជិតខាង) បានជួយប្អូន។ បន្ទាប់មក ពណ៌នាអំពីអ្វី ពេលណា និងរបៀបដែលអ្នកមានអារម្មណ៍។

២- សរសេរប្រយោគអំពីពេលវេលាដែលប្អូនបានជួយអ្នកដទៃ។ បន្ទាប់មក ពណ៌នាអំពីអ្វី ពេលណា និងរបៀបដែលអ្នកមានអារម្មណ៍។

នៅពេលនរណាម្នាក់ជួយប្អូន តើប្អូនមានអារម្មណ៍បែបណា? នៅពេលប្អូនជួយនរណាម្នាក់តើប្អូនមានអារម្មណ៍បែបណា? ចម្លើយអាចជា រីករាយ ខឹង រំភើប សោកសៅ...។

(ជាជម្រើស៖ ក្នុងករណីសិស្សពិបាកក្នុងការកំណត់អារម្មណ៍របស់ពួកគេ សូមថតចម្លងរូបភាព៩.២៖ តើអ្នកមានអារម្មណ៍យ៉ាងណា?) ។ វាជាលំហាត់ដ៏ល្អសម្រាប់សិស្ស ដើម្បីឆ្លុះបញ្ចាំងអារម្មណ៍របស់ខ្លួន។

គ្រូសួរសំណួរសិស្សខាងក្រោម។ នៅពេលដែលពួកគេយល់ស្រប ពួកគេនឹងលើកដៃឡើង។ គ្រូរាប់ និងសរសេរចំនួនសិស្សដែលយល់ស្របនៅលើក្ដារខៀន។

១- តើនរណាខ្លះមានអារម្មណ៍មិនសប្បាយចិត្ត ឬខឹង នៅពេលជួយអ្នកដទៃ? ហេតុអ្វី?

២- តើនរណាខ្លះមានអារម្មណ៍មិនសប្បាយចិត្ត ឬខឹង នៅពេលអ្នកដទៃជួយអ្នក? ហេតុអ្វី?

៣- តើនរណាខ្លះមានអារម្មណ៍រីករាយ ឬដឹងគុណ នៅពេលជួយអ្នកដទៃ? ហេតុអ្វី?

៤- តើនរណាខ្លះមានអារម្មណ៍រីករាយ ឬដឹងគុណ នៅពេលអ្នកដទៃជួយ? ហេតុអ្វី?

ការឆ្លុះបញ្ចាំងនៅចុងបញ្ចប់នៃសកម្មភាព៖



សេចក្ដីសន្និដ្ឋានដែលអាចធ្វើបាន៖ មានវិធីផ្សេងៗគ្នាជាច្រើនដែលយើងអាចជួយអ្នកដទៃបាន។ យើងមិនមែនត្រូវការលុយតែមួយមុខដើម្បីជួយគេនោះទេ។ ជំនួយអាចជាការយកចិត្តទុកដាក់ដល់អ្នកដទៃ ទោះបីជាយើងមិនស្គាល់ពួកគេក៏ដោយ។ នេះហើយដែលគេហៅថា សាមគ្គីភាព ការយកចិត្តទុកដាក់លើអ្នកដទៃ។

ជាធម្មតា ការជួយអ្នកដទៃធ្វើឱ្យប្អូនមានអារម្មណ៍ល្អចំពោះខ្លួនឯង និងទទួលបានការគោរពពីអ្នកដទៃ រាប់ចាប់តាំងពីក្រុមគ្រួសារ និងមិត្តភក្ដិរបស់ប្អូន ដែលនឹងធ្វើឱ្យប្អូនមានមោទនភាព។

តើប្អូនដឹងទេថា ភាពសប្បុរសធ្វើឱ្យខួរក្បាលរបស់ប្អូនមានសុខភាពកាន់តែល្អ និងជួយប្អូនឱ្យគ្រប់គ្រងស្ថានការណ៍តានតឹងបាន? នេះគឺជាឧបករណ៍ដ៏មានឥទ្ធិពល!

## រូបភាព៩.១៖ សកម្មភាពជួយអ្នកដទៃ



រូបភាពទី១



រូបភាពទី២



រូបភាពទី៣



រូបភាពទី៤

រូបភាព៩.២៖ តើអ្នកមានអារម្មណ៍យ៉ាងណា?



## វគ្គទី២

### សកម្មភាពទី២៖ តើអ្នកអាចជួយអ្នកដទៃបានដោយរបៀបណា? (៤៥នាទី)

គ្រូពន្យល់ថា យើងអាចជួយអ្នកដទៃតាមវិធីជាច្រើន និងដោយប្រើវត្ថុផ្សេងៗគ្នា។ យើងអាចជួយដោយផ្ដល់ពេលវេលា ផ្ដល់ប្រាក់ ឬផ្ដល់របស់របរដែលយើងមានដល់មនុស្សដែលត្រូវការជំនួយ។ យើងក៏អាចជួយដល់មនុស្ស ឬកន្លែងដែលយើងស្គាល់ផងដែរ។ យើងអាចជួយតាមរយៈអង្គការដែលមានវត្តមាននៅក្នុងសហគមន៍របស់យើង ឬអាចធ្វើវាដោយខ្លួនឯង និងជាមួយមិត្តភក្ដិរបស់យើង។

ចូរចាប់ផ្ដើមគិតអំពីវិធីដែលអាចធ្វើទៅបានក្នុងការជួយអ្នកដទៃជាមួយអ្វីដែលប្អូនបានរៀនកន្លងមក!

គ្រូបែងចែកសិស្សជាក្រុម ដែលមានសមាជិកប្រាំនាក់។ បន្ទាប់មក ចែកជូនក្រុមនីមួយៗនូវសន្លឹកកិច្ចការ ៩.៣៖ ពាក្យសំខាន់ៗ (ការបរិច្ចាគ ការស្ម័គ្រចិត្ត និងការរៃអង្គាសប្រាក់)។ ក្រុមនីមួយៗនឹងសរសេរពាក្យគន្លឹះ ឬឃ្លាដែលពន្យល់ពាក្យទាំងនោះ។




គ្រូសុំឱ្យក្រុមនីមួយៗបង្ហាញគំនិតរបស់ពួកគេអំពីពាក្យសំខាន់ៗទាំងបីខាងលើ។ គ្រូអាចសំយោគចម្លើយរបស់សិស្ស ហើយបង្ហាញ និងពន្យល់ដោយប្រើសន្លឹកកិច្ចការ ៩.៤៖ ការជួយអ្នកដទៃ។

**យើងអាចជួយអ្នកដទៃតាមរយៈ ...**

គ្រូគូសតារាងខាងក្រោមនៅលើក្ដារខៀន ហើយអានល្បះនីមួយៗឱ្យសិស្សទាំងអស់គ្នាស្ដាប់។ បន្ទាប់មកគ្រូសុំឱ្យសិស្សពិភាក្សាអំពីល្បះទាំងនោះជាគូជាមុនសិន រយៈពេល១នាទី។ គូនីមួយៗសរសេរចម្លើយរបស់ពួកគេនៅលើក្ដារខៀន។ បន្ទាប់មក គ្រូជ្រើសរើសមួយគូដោយចៃដន្យ ហើយសុំឱ្យពួកគេចែករំលែកចម្លើយរបស់ពួកគេ។ គ្រូត្រូវប្រាកដថាអ្នកឱ្យសិស្សទាំងអស់បានចូលរួម មិនមែនឱ្យតែសិស្សដែលសកម្មនោះទេ។ រួចសួរសិស្សដទៃក្នុងថ្នាក់ ថាតើពួកគេយល់ស្រប ឬអត់?

ខាងក្រោមនេះគឺជាល្បះដែលមានចម្លើយ។

| ល្បះ | ការបរិច្ចាគ | ការស្ម័គ្រចិត្ត | ការរៃអង្គាសប្រាក់ |
|---|---|---|---|
| ប្រមូល និងបរិច្ចាគសម្លៀកបំពាក់ ស្បែកជើង សៀវភៅ និងកាតាបរបស់ខ្ញុំ | ✓ | | |
| សម្អាតបរិស្ថាន | | ✓ | |
| ជួយមិត្តភក្ដិរបស់ខ្ញុំធ្វើកិច្ចការផ្ទះរបស់ពួកគេ | | ✓ | |
| ប្រមូល និងនាំយកម្ហូបអាហារជូនជនក្រីក្រ | ✓ | ✓ | |
| ជួយសិស្សក្រីក្រដោយទិញសៀវភៅ និងសម្ភារៈសិក្សាឱ្យ | ✓ | | |
| ប្រមូលប្រាក់ជួយសិស្សក្រីក្រដើម្បីឱ្យពួកគេទិញសម្ភារៈសិក្សា | | | ✓ |
| ស្ដាប់មិត្តរបស់ខ្ញុំពេលគេមានបញ្ហាខ្លះ | | ✓ | |
| ប្រមូលប្រាក់ទិញថ្នាំព្យាបាលជូនអ្នកជំងឺក្នុងសហគមន៍ | | | ✓ |

គ្រូអាចបញ្ចប់សកម្មភាពនេះដោយសួរសំណួរខាងក្រោម៖ តើប្អូនបានរៀនសូត្រអ្វីខ្លះនៅថ្ងៃនេះ? តើប្អូនចូលចិត្តអ្វីខ្លះសម្រាប់មេរៀនថ្ងៃនេះ? តើប្អូនទទួលបានចំណេះដឹងអ្វីខ្លះពីមេរៀននេះ ពេលប្អូនត្រឡប់ទៅផ្ទះវិញ?

## សន្លឹកកិច្ចការ ៩.៣៖ ពាក្យសំខាន់ៗ

**ការណែនាំ៖** ពាក្យខាងក្រោម គឺជាវិធីសំខាន់ៗក្នុងការជួយអ្នកដទៃ។ ក្នុងចន្លោះដែលមាន សូមសរសេរឃ្លាសំខាន់ៗ ឬឧទាហរណ៍ដែលជួយពន្យល់ពាក្យនីមួយៗ។

## ពាក្យសំខាន់ៗ

| ការបរិច្ចាគ | ការស្ម័គ្រចិត្ត | ការរៃអង្គាសប្រាក់ |
|---|---|---|
|  |  |  |
| ____________________ | ____________________ | ____________________ |
| ____________________ | ____________________ | ____________________ |
| ____________________ | ____________________ | ____________________ |

## សន្លឹកកិច្ចការណែនាំ ៩.៤៖ ការជួយអ្នកដទៃ

**ព័ត៌មានសម្រាប់គ្រូ៖** មានវិធីជាច្រើនក្នុងការជួយអ្នកដទៃដូចជា ផ្តល់ពេលវេលា ផ្តល់ប្រាក់ ឬផ្តល់របស់ដែលខ្លួនមានដល់មនុស្សដែលត្រូវការ។ មនុស្សគ្រប់គ្នាមានសារៈសំខាន់ណាស់នៅក្នុងសហគមន៍របស់យើង។ យើងទាំងអស់គ្នាធ្វើការរួមគ្នាដើម្បីធ្វើឱ្យសហគមន៍របស់យើងក្លាយជាកន្លែងដ៏អស្ចារ្យមួយ។

ការបរិច្ចាគគឺនៅពេលដែលប្អូនឱ្យរបស់របររបស់ប្អូនដើម្បីជួយអ្នកដទៃ។ វិធីខ្លះនៃការបរិច្ចាគគឺ ៖

- ឱ្យរបស់លេង ឬសម្លៀកបំពាក់ចាស់ៗរបស់ប្អូនទៅអង្គការសប្បុរសធម៌ដែលជួយកុមារមានជំងឺ ឬអ្នកក្រីក្រ
- ឱ្យសៀវភៅចាស់ៗរបស់ប្អូនទៅសាលា ឬបណ្ណាល័យសហគមន៍។



ការបរិច្ចាគ

**ការស្ម័គ្រចិត្ត (នៅក្នុងសាលា ឬសហគមន៍របស់ប្អូន)**



*ការស្ម័គ្រចិត្ត*

ការស្ម័គ្រចិត្ត គឺនៅពេលដែលប្អូនផ្ដល់ពេលវេលារបស់ប្អូនដើម្បីជួយអ្នកដទៃ។ វិធីខ្លះនៃការស្ម័គ្រចិត្តគឺ៖

- សម្អាតបង់នៅមាត់ទន្លេកុំឱ្យមានសំរាមប្លាស្ទិក។
- ទៅសួរសុខទុក្ខមនុស្សចាស់ដើម្បីនិយាយជាមួយពួកគាត់ ឬជួយពួកគាត់។
- ផ្ដល់ពេលវេលាដល់មិត្តភក្ដិរបស់ប្អូនដើម្បីជួយពួកគេសិក្សាឱ្យទាន់គេ។
- ប្រមូលអាហារ ឬសម្លៀកបំពាក់សម្រាប់កុមារ និងគ្រួសារដែលត្រូវការបំផុត។

**ការរៃអង្គាសលុយ** គឺជាពេលដែលប្អូនប្រមូលលុយដើម្បីជួយអ្នកដទៃ។ ក្នុងករណីរបស់យើង ប្អូនបានប្រមូលលុយ ឬរបស់របរផ្សេងទៀតរួចហើយ ក្លាយជាអ្នកសន្សំដ៏ល្អ ប៉ុន្តែក្នុងករណីដែលប្អូនត្រូវការលុយ ឬរបស់របរបន្ថែម សូមចងចាំជានិច្ចថា ប្អូនអាចធ្វើការរៃអង្គាសលុយបានតាមរយៈ៖



*ការរៃអង្គាសលុយ*

- ធ្វើសកម្មភាពនៅក្នុងសាលា ឬសហគមន៍ដើម្បីប្រមូលលុយ ឬរបស់របរដើម្បីចែកជូនមនុស្សដែលត្រូវការជំនួយបំផុតដែលប្អូនចង់ជួយ។
- ឧទាហរណ៍៖ ការអញ្ជើញសហគមន៍ទៅក្នុងសាលារៀន ពន្យល់ពីគម្រោងរបស់ប្អូន និងសុំការរួមចំណែក។
- រៀបចំអាហារសម្រន់ និងភេសជ្ជៈ និងលក់នៅក្នុងព្រឹត្តិការណ៍សាលា ឬសហគមន៍។
- សុំឱ្យក្រុមគ្រួសារ អ្នកជិតខាង និងមិត្តភក្តិនាំយកអាហារដែលពួកគេអាចទៅសាលារៀន ហើយលក់វាដើម្បីរៃអង្គាសលុយ។

## វគ្គទី៣

### សកម្មភាពសំខាន់ទី៣៖ តើអ្នកណាត្រូវការជំនួយពីអ្នក? (៤០នាទី)

គ្រូចាប់ផ្ដើមសកម្មភាពដោយចែក ឯកសារ៩.៥៖ ខ្ញុំនិងសហគមន៍របស់ខ្ញុំ ហើយពន្យល់ដល់សិស្សថាមានមនុស្ស និងស្ថានភាពផ្សេងៗគ្នាជាច្រើនដែលត្រូវការជំនួយនៅក្នុងសហគមន៍របស់យើង។ សូមក្រឡេកមើលសហគមន៍របស់យើង និងមនុស្សដែលរស់នៅទីនោះ។

បន្ទាប់មក គ្រូសួរថា៖ តើអ្នកណារស់នៅក្នុងផ្ទះរបស់ប្អូន? តើអ្នកណាស្នាក់នៅសាលារបស់ប្អូន? តើអ្នកណារស់នៅក្នុងសហគមន៍របស់ប្អូន?

**ព័ត៌មានជំនួយ៖** ដើម្បីកុំឱ្យសិស្សដដែលៗឆ្លើយសំណួរ សូមរៀបចំបាល់ក្រដាសមួយ ហើយពន្យល់ដល់សិស្សថា អ្នកដែលចាប់បានបាល់ ត្រូវឆ្លើយសំណួរ។

ដើម្បីធ្វើឱ្យសកម្មភាពនេះកាន់តែងាយស្រួល គ្រូអាចគូរដ្យាក្រាមខាងក្រោមនៅលើក្ដារខៀន និងសរសេរឈ្មោះរបស់មនុស្សទាំងនោះនៅក្នុងរង្វង់ ដោយផ្អែកលើអ្វីដែលសិស្សរបស់អ្នកនិយាយ។

# កន្លែងដែលខ្ញុំធំឡើង និងខ្ញុំអាចជួយបាន

**សង្ខេប៖**

- **នៅផ្ទះ** ៖ គ្រួសារ អ្នកជិតខាង មិត្តភក្តិ
- **នៅក្នុងសាលា៖** មិត្តរួមថ្នាក់ សិស្សផ្សេងទៀត បុគ្គលិកនៅក្នុងសាលា (គ្រូបង្រៀន នាយកសាលា បណ្ណារក្ស។ល។)។
- **ក្នុងសហគមន៍៖** មនុស្សជាច្រើននាក់ផ្សេងគ្នា រាប់ចាប់តាំងពីកសិកររហូតដល់គ្រូពេទ្យ មេភូមិ និងគ្រូបង្រៀន ប៉ុន្តែក៏មានមនុស្សដែលត្រូវការជំនួយ និងផ្តល់ជំនួយផងដែរ។




**សេចក្តីសន្និដ្ឋាន៖** មនុស្សគ្រប់គ្នាមានសារៈសំខាន់ណាស់នៅក្នុងសហគមន៍របស់យើង។ យើងទាំងអស់គ្នាធ្វើការរួមគ្នាដើម្បីធ្វើឱ្យសហគមន៍របស់យើងក្លាយជាកន្លែងដ៏អស្ចារ្យមួយ។

គ្រូពន្យល់សិស្សថា ការសន្មៃ យើងអាចគិតអំពីនរណាម្នាក់ដែលអាចនឹងត្រូវការជំនួយរបស់យើង មិនថានៅក្នុងសាលារៀន ឬនៅក្នុងសហគមន៍។ យើងយកចិត្តទុកដាក់ និងធ្វើការរួមចំណែកដល់សហគមន៍។ យើងនឹងអាចធ្វើឱ្យគ្រួសាររបស់យើងមានមោទនភាព និងរីករាយចំពោះអ្វីដែលយើងធ្វើ។

**ចងចាំ៖** តាមវិធីធំក្តី ឬតូចក្តី យើងទាំងអស់គ្នាអាចធ្វើឱ្យមានការផ្លាស់ប្តូរ។

មនុស្សដែលប្រហែលជាត្រូវការជំនួយ...

គ្រូផ្តល់សន្លឹកកិច្ចការ៩.៦៖ មនុស្សដែលប្រហែលជាត្រូវការជំនួយពីអ្នក។ គ្រូប្រាប់ឱ្យសិស្សពិភាក្សាជាក្រុមតូចៗអំពីរបៀបឆ្លើយតបចំពោះឈ្មោះនីមួយៗដែលបានផ្តល់ជូន និងគូស សញ្ញា (✓) នៅក្នុងប្រអប់ណាមួយ។ ឧទាហរណ៍មួយត្រូវបានធ្វើសម្រាប់ប្អូន។

| ឈ្មោះ | បាទ/ចាស | ទេ | បើត្រូវការ តើប្អូននឹងជួយពួកគាត់ដោយរបៀបណា? | | |
|---|---|---|---|---|---|
| | | | បរិច្ចាគ | ស្ម័គ្រចិត្ត | រៃអង្គាស |
| ឧ- សិស្សដែលទើបតែបាត់បង់ម្តាយ | ✓ | | ✓ | | |
| មនុស្សចាស់ដែលគ្មានសាច់ញាតិ | | | | | |
| កុមារ និងអ្នកផ្ទុកមេរោគអេដស៍ | | | | | |
| អ្នកដែលរស់នៅក្នុងផ្ទះខ្ទម ឬផ្ទះតូច | | | | | |
| ជនដែលមានពិការភាព | | | | | |
| កុមារកំព្រា | | | | | |
| ស្ត្រីដែលមានពិការភាព | | | | | |
| ក្រុមជនជាតិដើមភាគតិច ឬជនជាតិភាគតិច | | | | | |

| | | | | | |
|---|---|---|---|---|---|
| កុមារដែលប្រឈមនឹងការបោះបង់ការសិក្សា | | | | | |
| កុមារដែលរស់នៅមានអ្វីៗគ្រប់យ៉ាង | | | | | |
| អ្នកដែលធ្វើការមានប្រាក់ចំណូលទៀងទាត់ | | | | | |
| ... | | | | | |

គ្រូឱ្យសិស្សសរសេរបន្ថែមទៀតទាក់ទងនឹងមនុស្សដែលពួកគេគិតថាពួកគេប្រហែលជាត្រូវការជំនួយ។

គ្រូពន្យល់ថា ដើម្បីដឹងថានរណាជាអ្នកដែលត្រូវការជំនួយនោះ យើងគួរតែស្វែងរកពួកគេនៅក្នុងសហគមន៍របស់យើង ឬនៅក្នុងសាលារៀនដើម្បីគាំទ្រពួកគេ។




គ្រូសួរសិស្សទាំងអស់នូវសំណួរខាងក្រោម៖

- តើអ្នកណាខ្លះដែលត្រូវការជំនួយនៅក្នុងសហគមន៍និងក្នុងសាលារៀន?

បន្ទាប់មក គ្រូសរសេរចម្លើយរបស់សិស្សនៅក្នុងរង្វង់ដែលបានផ្តល់ជូន។

សេចក្តីសន្និដ្ឋានសម្រាប់មេរៀនថ្ងៃនេះ៖

- យើងបានរៀនថា មានវិធីជាច្រើនក្នុងការជួយអ្នកដទៃ។
- យើងបានរៀនពាក្យសំខាន់ៗចំនួន៣ ៖ ការបរិច្ចាគ ការស្ម័គ្រចិត្ត និងការរែអង្គាសលុយ។
- យើងបានរៀនថា សេចក្តីសប្បុរសធ្វើឱ្យយើងមានអារម្មណ៍ល្អ ហើយខួរក្បាលរបស់យើងក៏មានអារម្មណ៍ល្អផងដែរ។
- យើងក៏បានរៀនផងដែរថា នៅពេលអនាគត ជាមួយនឹងការសន្សំ ឬវត្ថុដែលយើងប្រមូលបាន យើងអាចជួយមនុស្សដទៃនៅក្នុងសហគមន៍ និងសាលារៀន។

**ព័ត៌មានជំនួយ៖** គ្រូគួររៀបចំសកម្មភាពសប្បុរសធម៌សម្រាប់សិស្ស ដូច្នេះពួកគេអាចធ្វើការរែអង្គាសថវិកា ស្ម័គ្រចិត្ត ឬបរិច្ចាគនៅពេលដែលពួកគេអាចកំណត់ឃើញមនុស្សដែលត្រូវការជំនួយនៅក្នុងសហគមន៍ ឬសាលារៀន។

## សន្លឹកកិច្ចការ ៩.៥៖ ខ្ញុំ និងសហគមន៍របស់ខ្ញុំ

គ្រូគួរតែថតចម្លងឯកសារនេះ ឬគូរនៅលើផ្ទាំងក្រដាសធំ ដើម្បីប្រមូល និងសរសេរគំនិតរបស់សិស្សនៅក្នុងរង្វង់។

## សន្លឹកកិច្ចការ ៩.៦៖ មនុស្សដែលប្រហែលជាត្រូវការជំនួយពីអ្នក

**ការណែនាំ៖** សូមអានល្បះខាងក្រោម ហើយគូសសញ្ញាធីក (✓) នៅក្នុងជួរឈរសមស្រប ដើម្បីឆ្លើយសំណួរ។ ឧទាហរណ៍មួយត្រូវបានផ្ដល់ជូនសម្រាប់ប្អូនដើម្បីឱ្យដឹងរបៀបឆ្លើយ។ ប្រសិនបើប្អូនមានពេល ប្អូនអាចបន្ថែមល្បះផ្ទាល់ខ្លួននៅខាងក្រោមតារាង ហើយឆ្លើយសំណួរទៅតាមនោះផងដែរ។

| ល្បះ | បាទ/ចាស | ទេ | បើត្រូវការ តើប្អូននឹងជួយពួកគាត់ដោយរបៀបណា? | | |
|---|---|---|---|---|---|
| | | | បរិច្ចាគ | ស្ម័គ្រចិត្ត | អែអង្គាស |
| ឧ- សិស្សដែលទើបតែបាត់បង់ម្ដាយ | ✓ | | ✓ | | |
| មនុស្សចាស់ដែលគ្មានសាច់ញាតិ | | | | | |
| កុមារ និងអ្នកផ្ទុកមេរោគអេដស៍ | | | | | |
| អ្នកដែលរស់នៅក្នុងផ្ទះខ្ទមឬផ្ទះតូច | | | | | |
| ជនដែលមានពិការភាព | | | | | |
| កុមារកំព្រា | | | | | |
| ស្ត្រីដែលមានពិការភាព | | | | | |
| ក្រុមជនជាតិដើមភាគតិច ឬជនជាតិភាគតិច | | | | | |
| កុមារដែលប្រឈមនឹងការបោះបង់ការសិក្សា | | | | | |
| កុមារដែលរស់នៅមានអ្វីៗគ្រប់យ៉ាង | | | | | |
| អ្នកដែលធ្វើការមានប្រាក់ចំណូលទៀងទាត់ | | | | | |
| បន្ថែមល្បះរបស់អ្នកខាងក្រោម | | | | | |
| ... | | | | | |
| ... | | | | | |

# មេរៀនទី ១០ បញ្ចប់មេរៀនអក្ខរកម្មហិរញ្ញវត្ថុ

| | |
|---|---|
| | រយៈពេល៖ ៤០នាទី (៣វគ្គ) |
| | **ការត្រៀមមុនបង្រៀន**<br>- អានមេរៀនទាំងមូល<br>- ថតចម្លងសន្លឹកកិច្ចការ២.១។ |
| | **សម្ភារៈ ធនធានដែលចាំបាច់**<br>- សន្លឹកកិច្ចការ ២.១៖ តេស្តក្រោយវគ្គ<br>- ទម្រង់វាយតម្លៃតរិយាបថសិស្ស។ |
| | **លទ្ធផលសិក្សា៖**<br>បន្ទាប់ពីបញ្ចប់មេរៀននេះ សិស្សនឹងអាច៖<br>- បញ្ចេញគំនិត និងអារម្មណ៍ស្តីពីអក្ខរកម្មហិរញ្ញវត្ថុ ដែលមានលក្ខណៈដើម និងពិតប្រាកដ<br>- បង្ហាញសមត្ថភាពតាមរយៈការនិយាយខ្លីៗអំពីរបៀបដែលចំណេះដឹង និងអាកប្បកិរិយារបស់ពួកគេស្តីពីអក្ខរកម្មហិរញ្ញវត្ថុមានភាពប្រសើរឡើង។ |

### តេស្តក្រោយវគ្គទាក់ទងនឹងអក្ខរកម្មហិរញ្ញវត្ថុ ( ១៥នាទី )

គ្រូអាចចាប់ផ្តើមមេរៀននេះដោយជូនដំណឹងដល់សិស្សថាប្អូននឹងបំពេញ សន្លឹកកិច្ចការ២.១៖ តេស្តមុន ឬក្រោយវគ្គ ដើម្បីវាយតម្លៃថាតើសិស្សទទួលបានចំណេះដឹងកម្រិតណាក្នុងអំឡុងពេលវគ្គសិក្សាអក្ខរកម្មហិរញ្ញវត្ថុ។ មុនពេលចាប់ផ្តើម សូមយករបស់របរផ្ទាល់ខ្លួនទាំងអស់ចេញពីតុ ហើយដាក់វានៅក្រោមតុរបស់ប្អូន ឬនៅផ្នែកខាងក្រោយនៃថ្នាក់រៀន។

នៅពេលតេស្តចាប់ផ្តើម សិស្សនឹងមិនត្រូវបានអនុញ្ញាតឱ្យជជែកជាមួយសិស្សផ្សេងទៀតឡើយ។ ប្រសិនបើពួកគេមានសំណួរទាក់ទងនឹងតេស្ត ពួកគេត្រូវលើកដៃដើម្បីសួរគ្រូ។ ពួកគេមិនអាចសួរមិត្តភក្តិបានទេ។ សិស្សមានពេល១៥នាទីដើម្បីបញ្ចប់តេស្ត។ គ្រូសរសេរនៅលើក្តារខៀន នៅពេលសល់ពេលវេលា ៥នាទី។ ប្រសិនបើសិស្សធ្វើចប់មុនម៉ោង ពួកគេអាចប្រគល់តេស្ត ហើយទៅរង់ចាំនៅខាងក្រៅថ្នាក់។ ឥឡូវនេះសិស្សអាចចាប់ផ្តើមធ្វើតេស្ត។

ដំណើរវិចិត្រសាល (បន្ទប់ ឬអគារតាំងស្នាដៃ) (Gallery Walk) បង្ហាញសម្ភារៈទាក់ទងនឹងការសិក្សាហិរញ្ញវត្ថុ (២៥ នាទី)។

បន្ទាប់ពីការធ្វើតេស្ត គ្រូអាចពន្យល់សិស្សដូចតទៅ៖ ពិតជាមិនគួរឱ្យជឿទេ ដំណើរការសិក្សាអក្ខរកម្មហិរញ្ញវត្ថុរបស់យើងបានឈានមកដល់ទីបញ្ចប់ហើយ។ យើងបានរៀនសូត្រចំណេះដឹងជាច្រើនដូចជា របៀបរៀបចំផែនការ ចាត់ចែងថវិកា សន្សំ និងចំណាយប្រាក់ដោយឆ្លាតវៃ។ យើងក៏បានរៀនពីរបៀបជួយមនុស្សដែលត្រូវការជំនួយ ជាផ្នែកនៃសហគមន៍របស់យើង។ មេរៀនសំខាន់បំផុតគឺ យើងអាចចែករំលែកអ្វីដែលយើងបានរៀនជាមួយឪពុកម្តាយ និងកុមារផ្សេងទៀត។

បន្ទាប់មក គ្រូឱ្យសិស្សបង្កើតក្រុមចំនួន៥ ហើយចាត់ចែងប្រធានបទមួយក្នុងចំណោមប្រធានបទខាងក្រោមឱ្យក្រុមនីមួយៗ៖ (ក)ការសន្សំ (ខ)ការរកប្រាក់ (គ)ការចំណាយ (ឃ)ការបរិច្ចាគ និង (ង)ប្រវត្តិរបស់ប្រាក់នៅប្រទេសកម្ពុជា។ ក្រុមនីមួយៗនឹងប្រើប្រាស់ឡើងវិញនូវឯកសារដែលយើងបានបង្កើតដើម្បីបង្ហាញដល់ថ្នាក់រៀនលើប្រធានបទរបស់ខ្លួន។ ប្រើគំនិតច្នៃប្រឌិតរបស់អ្នកដើម្បីរចនាផ្ទាំងក្រដាសធំដ៏ស្រស់ស្អាតនិងទាក់ទាញ។ ផ្ទាំងក្រដាសធំទាំងនេះនឹងត្រូវបានបង្ហាញនៅក្នុងថ្នាក់រៀន ឬនៅក្នុងសាលប្រជុំ។

**ព័ត៌មានជំនួយ៖** បច្ចេកទេសដំណើរវិចិត្រសាល (បន្ទប់ឬអគារតាំងស្នាដៃ)

១- **ក្រុម៖** បែងចែកសិស្សជា៥ក្រុម ដើម្បីបង្ហាញផលិតកម្មរបស់ពួកគេ (ឧទាហរណ៍៖ ការសន្សំ ការចំណាយ ប្រវត្តិរបស់ប្រាក់ ការរកប្រាក់។) នឹងមានមនុស្សម្នាក់ ឬពីរនាក់ឈរនៅតាមទីតាំង ជាអ្នកដឹកនាំដើម្បីធ្វើបទបង្ហាញ និងចែករំលែកធនធាននៅលើជញ្ជាំងដែលបានបង្ហាញ។ ចំណែកសមាជិកក្រុមដែលនៅសល់នឹងដើរទៅទីតាំងផ្សេងទៀតដើម្បីរៀនសូត្រពីប្រធានបទផ្សេងទៀត។

២- **ដើរ៖** ចាប់ផ្ដើមសកម្មភាព និងវិលជុំទៅកាន់ទីតាំងនីមួយៗ។ ទុកពេល៣នាទីសម្រាប់មួយទីតាំងដើម្បីឱ្យសិស្សសួរសំណួរទៅកាន់អ្នកដឹកនាំ។ អ្នកទស្សនាអាចសួរសំណួរទៅកាន់អ្នកដឹកនាំដើម្បីទទួលបានព័ត៌មានបន្ថែម។ សមាជិកក្រុមទាំងអស់ត្រូវដើរគ្រប់ទីតាំង ដែលរៀបចំដោយគ្រូ។

៣- **សេចក្ដីសន្និដ្ឋាន៖** នៅពេលអស់ម៉ោង គ្រូធ្វើសេចក្ដីសន្និដ្ឋាន ឬសង្ខេបសកម្មភាពនៃមេរៀនថ្ងៃនេះ។ សិស្សទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យចែករំលែកអ្វីដែលពួកគេបានរៀនសូត្រ និងអ្វីដែលពួកគេអាចចេះពេលត្រឡប់ទៅផ្ទះវិញ។ សូមសរសើរសិស្សចំពោះការចូលរួមយ៉ាងសកម្ម។

**ព័ត៌មានជំនួយ៖** សាលាអាចអញ្ជើញមាតាបិតា ឬគណៈកម្មាធិការគ្រប់គ្រងសាលាមកទស្សនាសកម្មភាពដំណើរវិចិត្រសាល (បន្ទប់ ឬអគារតាំងស្នាដៃ)។

**សេចក្តីបញ្ចប់៖** ការចែកវិញ្ញាបនបត្រ

គ្រូអាចបញ្ចប់មេរៀនដោយនិយាយថា សូមអរគុណច្រើនចំពោះការចូលរួមរបស់ប្អូនក្នុងដំណើររបស់យើងយើងពាក់ព័ន្ធនឹងអក្ខរកម្មហិរញ្ញវត្ថុ! ខ្ញុំសង្ឃឹមថាប្អូននឹងប្រើប្រាស់អ្វីៗដែលយើងបានរៀនសូត្រជាមួយគ្នា ហើយចែករំលែកគន្លឹះ និងទម្លាប់ល្អៗក្នុងការគ្រប់គ្រងប្រាក់។ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការផ្តល់ឱ្យប្អូនគ្រប់គ្នានូវវិញ្ញាបនបត្រដែលជាភស្តុតាងបង្ហាញថា ប្អូនបានចូលរួមក្នុងកម្មវិធីសិក្សាហិរញ្ញវត្ថុដោយជោគជ័យ។

ទោះបីជាថ្នាក់រៀននេះបានបញ្ចប់ទៅហើយក្តី យើងជឿជាក់យ៉ាងមុតមាំថា ប្អូនអាចបន្តបង្កើនចំណេះដឹងនិងជំនាញរបស់ខ្លួនលើអក្ខរកម្មផ្នែកហិរញ្ញវត្ថុ។ ខ្ញុំលើកទឹកចិត្តប្អូនឱ្យបន្តបំពេញផែនការសន្សំ ផែនការរយៈពេលវែង ឬខ្លី ជាដើម រហូតដល់ដំណាច់ឆ្នាំ ដើម្បីធ្វើឱ្យមានការកែប្រែ និងផ្លាស់ប្តូរជីវិតរបស់ប្អូន។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ការិយាល័យអប់រំ យុវជន និងកីឡាស្រុក
ឈ្មោះសាលារៀន ……………………………..
លេខ ………………..

# វិញ្ញាបនបត្របញ្ជាក់ការសិក្សា

**ការិយាល័យអប់រំ យុវជន និងកីឡា ស្រុក** ……………………………………..

សូមបញ្ជាក់ថា

**ឈ្មោះ**………………………………………………… **ថ្នាក់ទី**……………

បានចូលរួម និងបញ្ចប់ដោយជោគជ័យនូវកម្មវិធីសិក្សាអក្ខរកម្មហិរញ្ញវត្ថុសម្រាប់កម្រិតបឋមសិក្សា។

………………………. ថ្ងៃទី…… ខែ…… ឆ្នាំ២០២…

**នាយកសាលា**

# ទម្រង់វាយតម្លៃឥរិយាបថសិស្ស

ឈ្មោះ៖ ______________________ ថ្នាក់ទី៖______________

សាលារៀន៖______________________ ស្រុក៖______________

| ធាតុដែលត្រូវដាក់ពិន្ទុ | | ពិន្ទុ (១-៥) | មតិយោបល់ |
|---|---|---|---|
| ១ | **ការប្រាស្រ័យទាក់ទង និងសហការ៖** ការពិភាក្សា និងសហការយ៉ាងសកម្មជាមួយសមាជិកទាំងអស់ក្នុងក្រុម។ សិស្សអាចស្ដាប់ និងប្រតិកម្មលើពាក្យរបស់ពួកគេ។ | | |
| ២ | **ការវិភាគ និងដោះស្រាយបញ្ហា៖** ផ្ដល់ចម្លើយដោយមានហេតុផល និងអំណះអំណាងច្បាស់លាស់ ហើយអាចកំណត់ដំណោះស្រាយចំពោះបញ្ហាសាមញ្ញៗដែលបានជួបប្រទះ។ | | |
| ៣ | **ការសម្រេចចិត្តដោយខ្លួនឯង៖** មានភាពរហ័សរហួនក្នុងការសម្រេចចិត្តលក្ខណៈបុគ្គល ហើយដឹងយ៉ាងច្បាស់អំពីអ្វីដែលនាង ឬគាត់កំពុងនិយាយ។ | | |
| ៤ | **ទំនុកចិត្ត៖** អំឡុងពេលធ្វើបទបង្ហាញ ឬការពិភាក្សា សិស្សមានទំនុកចិត្តក្នុងការនិយាយ និងចូលរួម។ | | |
| ៥ | **ការលើកទឹកចិត្ត និងការយល់ដឹង៖** សិស្សបង្ហាញពីការលើកទឹកចិត្តក្នុងការចូលរួមក្នុងប្រធានបទ។ គាត់ឬនាងបង្ហាញការយល់ដឹងយ៉ាងច្បាស់អំពីប្រធានបទនៅក្នុងមេរៀន និងអំឡុងពេលអនុវត្ត។ | | |
| ៦ | **ចរិតលក្ខណៈ៖** សិស្សមានភាពអត់ធ្មត់ និងមានអាកប្បកិរិយាវិជ្ជមានក្នុងថ្នាក់។ | | |
| ៧ | **ភាពច្នៃប្រឌិត៖** សិស្សបង្ហាញពីភាពច្នៃប្រឌិតក្នុងការធ្វើបទបង្ហាញ ផលិតផល និងអំឡុងពេលមេរៀន។ គាត់ឬនាងបង្កើតជាគំនិតជាច្រើន។ | | |
| ពិន្ទុសរុបការសង្កេតអាកប្បកិរិយារបស់សិស្ស។ មាន ៣៥ ពិន្ទុដែលត្រូវផ្ដល់ឱ្យ។( ០-១៧: មិនល្អ / ១៨-២៣: មធ្យម / ២៤-៣៥: ល្អ ) | | | |

# តារាងពិន្ទុវាយតម្លៃឥរិយាបថសិស្ស

សាលារៀន៖_______________________ ថ្នាក់៖__________

| ល.រ | ឈ្មោះសិស្ស | ភេទ | តេស្តសរសេរ | | ពិន្ទុវាយតម្លៃឥរិយាបថសិស្ស | ពិន្ទុសរុប |
|---|---|---|---|---|---|---|
| | | | ពិន្ទុតេស្តមុនវគ្គ | ពិន្ទុតេស្តក្រោយវគ្គ | | |
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |
| ១០ | | | | | | |
| ១១ | | | | | | |
| ១២ | | | | | | |
| ១៣ | | | | | | |
| ១៤ | | | | | | |
| ១៥ | | | | | | |
| ១៦ | | | | | | |
| ១៧ | | | | | | |
| ១៨ | | | | | | |
| ១៩ | | | | | | |
| ២០ | | | | | | |
| ២១ | | | | | | |
| ២២ | | | | | | |
| ២៣ | | | | | | |

រៀបចំដោយ៖ ____________________

កាលបរិច្ឆេទ៖ ____________________

# ការសង្កេតថ្នាក់រៀន - ស្វ័យវាយតម្លៃគ្រូបង្រៀន

| សាលារៀន | | គ្រូបង្រៀន | | អ្នកសង្កេត |
|---|---|---|---|---|
| | | | | |
| **កាលបរិច្ឆេទ** | **មេរៀនចាប់ផ្តើម** | **មេរៀនបញ្ចប់** | **ថ្នាក់ទី** | **ចំនួនសិស្សចុះឈ្មោះ/វត្តមាន** |
| | | | | |
| **តើមេរៀននិយាយអំពីអ្វី ?** | | | | |
| | | | | |
| **លក្ខណៈវិនិច្ឆ័យ - ការត្រៀមខ្លួន - *តើថ្នាក់រៀន*** | | | **ពិន្ទុ** | **កំណត់ចំណាំពីភស្តុតាង** |
| មានសម្ភារៈត្រៀមរួចសម្រាប់ប្រើក្នុងមេរៀននេះដែរឬទេ? | | | ១-២-៣-៤-៥ | |
| បង្ហាញដល់សិស្សនូវសម្ភារៈដែលបានបង្កើតពីមេរៀនមុនៗ? | | | ១-២-៣-៤-៥ | |
| **លក្ខណៈវិនិច្ឆ័យ - ការសិក្សា - *តើសិស្ស...*** | | | **ពិន្ទុ** | **កំណត់ចំណាំពីភស្តុតាង** |
| មើលទៅចាប់អារម្មណ៍ និងចូលរួមសកម្មក្នុងការងាររបស់ពួកគេដែរឬទេ? | | | ១-២-៣-៤-៥ | |
| ធ្វើការជាមួយក្រុមចម្រុះដែលមានក្មេងប្រុស និងក្មេងស្រីក្នុងអំឡុងពេលផ្នែកមួយនៃមេរៀនដែលមានតួនាទីក្នុងក្រុមច្បាស់លាស់? | | | ១-២-៣-៤-៥ | |
| បង្ហាញចំណេះដឹង ឬជំនាញពីមេរៀនមុនៗ? | | | ១-២-៣-៤-៥ | |
| **លក្ខណៈវិនិច្ឆ័យ - ការបង្រៀន - តើគ្រូ** | | | **ពិន្ទុ** | **កំណត់ចំណាំពីភស្តុតាង** |
| អនុវត្តតាមផែនការជាគោលការណ៍ណែនាំដែរឬទេ? | | | ១-២-៣-៤-៥ | |
| ប្រើប្រាស់ធនធានសហគមន៍ក្នុងមេរៀនឬវដ្តមេរៀន? | | | ១-២-៣-៤-៥ | |
| ប្រើយុទ្ធសាស្ត្របង្រៀនបែបអន្តរកម្ម? ឧ. ផែនទីគំនិត ករណីសិក្សា ដើរតួសម្តែង ល្បែងសិក្សា។ | | | ១-២-៣-៤-៥ | |
| ប្រើសំណួរប្រភេទផ្សេងៗ? | | | ១-២-៣-៤-៥ | |
| ប្រើធនធានដែលបង្កើតដោយខ្លួនឯង ឬធនធានបន្ថែមដើម្បីពន្យល់មេរៀន? | | | ១-២-៣-៤-៥ | |
| ចាប់ផ្តើមទាន់ពេល និងប្រើប្រាស់ពេលវេលាប្រកបដោយប្រសិទ្ធភាព? | | | ១-២-៣-៤-៥ | |

| | | | |
|---|---|---|---|
| បញ្ចេញយោបល់វិជ្ជមាន ដើម្បីជំរុញការសិក្សា និងទំនុកចិត្តរបស់សិស្ស? | ១-២-៣-៤-៥ | | |
| ជួយសិស្សម្នាក់ៗដែលមានការលំបាក? | ១-២-៣-៤-៥ | | |
| ដាក់បញ្ចូលវឌ្ឍនភាពនៃអាកប្បកិរិយាទៅក្នុងសន្លឹកវាយតម្លៃការសិក្សា? | ១-២-៣-៤-៥ | | |
| តាមដានត្រួតពិនិត្យឥរិយាបថក្នុងថ្នាក់រៀនរបស់ខ្លួន ភាសា កម្រិតសំឡេង និងការយល់ឃើញទូទៅដែលរើសអើងភេទ | ១-២-៣-៤-៥ | | |
| គ្រូធានាឱ្យមានការចូលរួមស្មើៗគ្នារបស់សិស្សប្រុស និងសិស្សស្រីនៅគ្រប់ដំណាក់កាលនៃសកម្មភាព។ | ១-២-៣-៤-៥ | | |

សុំឱ្យគ្រូកំណត់ចំណុចល្អនៃមេរៀន និងផ្តល់យោបល់សម្រាប់ការផ្លាស់ប្តូរ ឬកែលម្អ។ សូមផ្តល់យោបល់អំពីគំនិតសម្រាប់អភិវឌ្ឍន៍។

| ចំណុចខ្លាំង | ចំណុចកែលម្អ |
|---|---|
| | |



១0000
10000
ក៨ 5309620
ជធ 4501736
ចថ 2490024
១000
40017546 A
UNITED STATES OF AMERICA